# រឿងជីវិតរបស់ខ្ញុំ

ចូរអោយយើងអោនក្បាលមួយភ្លែតសម្រាប់សេចក្ដីអធិស្ឋាន។

ឱព្រះវរបិតាសួគ៌ដ៏ព្រះគុណអើយ វាជាការពិតណាស់ដោយព្រម ឲ្យឯកសិទ្ធដែលទូលបង្គំ ទាំងអស់បានចូលមកចំពោះទ្រង់ ដែលជាព្រះនិងជាអង្គសង្គ្រោះ។ ដោយបានស្ដាប់ចម្រៀងដ៏ស្ទើចសរសើរ គឺបទ *ទ្រង់ ធំអស្ចារ្យ* វាបានធ្វើអោយទូលបង្គំ រាល់គ្នាមានសេចក្ដីអំណរ ដោយព្រោះទូលបង្គំទាំងអស់បានដឹងថា ទ្រង់ធំអស្ចារ្យ។ ហើយទូលបង្គំទាំងអស់គ្នាសូម អធិស្ឋាន ដើម្បីអោយភាពធំអស្ចារ្យរបស់ទ្រង់នឹងសម្ដែង មកចំពោះទូលបង្គំជាថ្មីនៅរសៀលនេះ ពេល ដែលទូលបង្គំនិយាយ។ ហើយវាជាការធ្លាក់ចុះរបស់ទូលបង្គំ ជាលើកដំបូង ក្នុង កំឡុងពេលជាច្រើនឆ្នាំមកដែលទូលបង្គំព្យាយាមត្រឡប់ ទៅរកជីវិតចាស់ កន្លង ហើយទូលបង្គំគ្រប់គ្នាសូមអធិស្ឋាន ដែលទ្រង់នឹងប្រទានកម្លាំងដល់ទូល បង្គំនិង—និងអ្វីដែលទូលបង្គំត្រូវការ ឱព្រះអម្ចាស់គឺនៅក្នុងម៉ោងនេះ។ ហើយសូមអោយកំហុសនៃជីវិតទូលបង្គំនឹងត្រឹមតែជាថ្មជាន់ សំរាប់អ្នកផ្សេងដែល នឹងអាច នាំពួកគេទៅជិតទ្រង់ថែមទៀត។ សូមទ្រង់អនុញ្ញាតិ ឱព្រះអម្ចាស់អើយ។ សូម អោយ មនុស្សបាបមើលឃើញដានជើងនៅ លើខ្សាច់នៃ ពេលវេលា ហើយសូមអោយពួកគេទទួលបានការដឹកនាំឆ្ពោះទៅរកទ្រង់។ ទូលបង្គំទូលសូមក្នុងព្រះនាម ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។

សូមអង្គុយចុះ។

2 [បងប្រុស ក្លេវី និយាយ "តើអ្នកអាចអធិស្ឋានអោយកន្សែងនេះទេ មុននឹងអ្នកចាប់ផ្ដើម?"—Ed.] ខ្ញុំនឹងសប្បាយចិត្តណាស់។ ["មានរឿងនោះ ឬរឿង នេះដើម្បីអោយយើងអធិស្ឋានអោយ។"] ជាការពិតណាស់ អរគុណលោក។ ក្នុងភាពជាអ្នកបរិសុទ្ធបងប្រុស ក្លេវី ដែលខ្ញុំបានស្គាល់ជាច្រើនឆ្នាំហើយ មានឯកសិទ្ធិបាន ជួបលោក នៅយប់កន្លងទៅ។ ហើយគាត់បានប្រាប់ខ្ញុំពី...លោកបានដួល រយៈពេល មួយរយៈខ្លី ឈប់សម្រាក។ ហើយឥឡូវនេះកាល មានអាយុចិត្ត សិប-ប្រាំឆ្នាំហើយក៏ត្រឡប់ ទៅបម្រើការងាររបស់ព្រះអម្ចាស់វិញ។ ខ្ញុំមិនបាននឿយហត់ស្មើរនឹងពាក់កណ្ដាលពី មុននិងខ្ញុំឮរឿងនោះ។ ខ្ញុំបានគិតថាខ្ញុំអស់

កម្លាំងប៉ុន្តែខ្ញុំ—ខ្ញុំមិនជឿថាខ្ញុំគឺដូច្នេះឡើយ។ គាត់បាន ដាក់កូនកន្សែងនៅទីនេះជា—ទ្រង់ទ្រាយរាងស្រោមសំបុត្រហើយដូច្នេះ ដែលវាបាននៅផ្នែកខាងក្នុងនិងត្រឡប់ ខាងខ្នងរួចហើយ។

3 ឥឡូវមាននរណាម្នាក់ ក្នុងចំនោមអ្នករាល់គ្នានៅក្នុងតំបន់វិទ្យុ ឬនៅទីនោះដែល ចង់បានកូនកន្សែងនេះ អ្នកអាចយកបាន...ព្រះវិហារ អិនដែលឡឹសបញ្ជូនពួកវាចេញទៅក្រៅជានិច្ច។ អ្នកអាចសរសេរនៅទីនេះ បញ្ជូលទៅព្រះវិហារ អិនដែលឡឹស ហើយពួកគេនឹងអធិស្ឋានលើវា ព្រោះខ្ញុំបញ្ជាក់អ្នករាល់គ្នាថាវា ជាការធ្វើនៅក្នុងបទគម្ពីរ។ វាជាសេចក្តីសន្យារបស់ព្រះជាម្ចាស់។

4 ហើយបើសិននោះជាការ ដែលអ្នកចង់អោយខ្ញុំអធិស្ឋានលើនរណាម្នាក់ នៃអ្នករាល់គ្នា ហេតុអ្វីមិនបាន ខ្ញុំនឹងរីករាយក្នុងការធ្វើដូច្នេះ។ អ្នកអាច សរសេរសំបុត្រ មកកាន់ខ្ញុំតាមរយៈប៉ុស្តិ៍ការិយាល័យ ប្រអប់ ៣-២-៥, ៣២៥ ជេហ្វឺសាន់វិល ប្រកបថា ជេ—ហ្វឺ—សាន់—វិល អិលពីរដង អ៊ី។ ជេហ្វឺសាន់វិល រដ្ឋអិនឌៀអាយណា។ ឬបើអ្នកមិនចាំលេខប្រអប់សំបុត្រ សូមសរសេរតែ "ជេហ្វឺសាន់វិល។" វាជាក្រុងតូចមួយ មានប្រជាជនសរុបប្រមាណ៣៥០០០នាក់។ គ្រប់គ្នាស្គាល់ខ្ញុំនៅទីនោះ។ យើងខ្ញុំនឹងរីករាយក្នុងការអធិស្ឋានដល់កូនកន្សែង ហើយផ្ញើរទៅអ្នក វិញ។

5 ហើយឥឡូវយើងមាន ជោគជ័យណាស់ ក្នុងការធ្វើដូច្នេះពីព្រោះ...អ្នកនឹងទទួលបាន សំបុត្រ តូចមួយដាក់ជាមួយ ដែលមនុស្សទូទាំងពិភពលោកអធិស្ឋានរៀងរាល់ ព្រឹកនៅ ម៉ោង៩ ម៉ោង១២ និងម៉ោង៣។ ហើយអ្នកអាចស្រមៃមើល ពីខាងក្រោយនោះ នៅពីក្រោយ ពិភពលោកទាំងមូល ពេលណាជាពេល យប់ដែលពួកគេត្រូវភ្ញាក់ ឡើង ហើយ អធិស្ឋាន សេចក្តីអធិស្ឋាននេះ។ ដូច្នេះបើ រាល់ មួយម៉ឺននាក់គុណនឹងរាប់ពាន់នាក់ទៀត ហើយទាំងអស់គ្នាសុទ្ធ តែបញ្ជូល សេចក្តីអធិស្ឋាន ទៅព្រះជាម្ចាស់ នៅដល់ព័ន្ធកិច្ចនេះពេលដូចគ្នាដូច្នេះ ជំងឺរបស់អ្នកព្រះទ្រង់ មិនអាចនឹងជៀសរំលង បានឡើយ។ ហើយឥឡូវយើងទាំងអស់គ្នា ដូចខ្ញុំបាននិយាយ យើងមិនមានកម្មវិធី យើងមិនចង់បានលុយមួយកាក់ឡើយ។ យើងគ្រាន់តែ...អ្វីដែលយើងអាចជួយអ្នក បាននេះជាអ្វី ដែលយើងនៅ ទីនេះ។ ហើយចូរអោយយើង...

មានអ្នកយកបាច់កូនកន្សែងមកទៀតហើយ។

6 ឥឡូវ បើអ្នកមិនមានកូនកន្សែងដែលអ្នកចង់ផ្ញើរទៅទេល្អអ្នកគ្រាន់តែសរសេរសំបុត្រប្រាប់ចុះ របៀបណាក៏បាន។ បើអ្នកមិនចង់បានឥឡូវ ចូរយក វាដាក់ ក្នុងគម្ពីរកិច្ចការ ក្នុងព្រះគម្ពីរ ជំពូកទី១៩។ ហើយវា ជាទម្រង់ដៃកូនខ្សែបូតូច មួយពណ៌សដែលនឹងបញ្ជូនទៅអោយអ្នក ហើយការបង្ហាត់ប្រាប់ដំបូង គឺអោយ អ្នកលន់តួបាប ជាមុនសិន។ ហើយ(អរគុណ) របៀបសារភាពបាបរបស់អ្នក។ អ្នកមិនត្រូវព្យាយាមទទួលយកអ្វីពីព្រះជាម្ចាស់ដោយគ្មានភាពត្រឹមត្រូវនៅចំពោះ ព្រះជាមុននោះឡើយ។ ឃើញទេ? ហើយអ្នកក៏ត្រូវបានបង្គាប់ក្នុងរឿងនេះដើម្បី អោយហៅអ្នកជិតខាងអោយ មក និងគ្រូគង្វាលរបស់អ្នកដែរ។ បើអ្នកមានអ្វីនៅក្នុងចិត្តដែលទាស់នឹងនរណាម្នាក់ ទៅដោះស្រាយជាមុនសិន រួចចូលមកវិញចុះ។ ហើយអធិស្ឋាន បើមានក្រុមអធិស្ឋាន ក្នុងផ្ទះរបស់អ្នកចូរដោយកូន កន្សែង នេះនៅក្រោមក្រណាត់ ហើយជឿដល់ព្រះជាម្ចាស់ចុះ។ ហើយនៅរៀងរាល់៣ ម៉ោងម្តងជារៀងរាល់ថ្ងៃ នឹងមានមនុស្សជុំវិញពិលោកកំពុងអធិស្ឋានគឺជាច្រវ៉ាក់ បណ្តាញទូទាំពិភពលោក។

7 ហើយឥឡូវវាជារបស់អ្នក មិនបានគិតលុយទេ គឺគ្រាន់តែបញ្ជូនទៅ អោយប៉ុណ្ណោះ។ ហើយ—ហើយឥឡូវយើងនឹងមិនសរសេរសំបុត្រទៅអ្នករាល់គ្នាដើម្បីរំលឹក ប្រាប់ពីកម្មវិធីដែលយើងមាននោះឡើយ។ យើងចង់អោយ អ្នកគាំទ្រកម្មវិធីនេះ ប៉ុន្តែយើងមិន—មិនមានអ្វីអោយអ្នកជួយទ្រទ្រង់ឡើយ។ ឃើញទេ? ដូច្នេះអ្នក...វាមិនមែន ជាការយកអាសយដ្ឋានរបស់អ្នកឡើយ វាគ្រាន់តែជា ការស្នាក់ នៅ និង ជាព័ន្ធកិច្ច របស់ព្រះអម្ចាស់ ដែលយើងកំពុងស្ពាយ។

8 ឥឡូវចូរអោយយើងអោនក្បាល។ បើអ្នកនៅក្នុងតំបន់វិទ្យុ ចូរដាក់កូន កន្សែងរបស់អ្នកនៅទីនោះ ចូរដាក់ដៃរបស់អ្នកនៅលើវា កាលពួកយើងកំពុង អធិស្ឋាន។

9 ព្រះអម្ចាស់ដ៏មានព្រះគុណ ទូលបង្គំរាល់គ្នានាំយកកញ្ចប់តូចនេះ ហើយប្រហែលជាខ្លះជាអាវកាក់ទារក ឬ—ឬជាអាវក្នុងឬក៏ជាគូនៃវត្ថុយកពីគេមក ឬ—ឬក៏ជាកូនកន្សែងតូច វាជារបស់អ្នកជំងឺឬជាអ្នកដែលមានក្តីវេទនា។ ព្រះអម្ចាស់អាស្រ័យតាមព្រះបន្ទូលរបស់ទ្រង់ ទូលបង្គំរាល់គ្នាសូមធ្វើការនេះ។ ទូលបង្គំទាំងអស់បានអាន ក្នុងគម្ពីរកិច្ចការ ដែលគេបានទាញយកវត្ថុពីប៉ុលអ្នកបម្រើទ្រង់ គឺជាកន្សែង និងក្រណាត់ ដោយព្រោះគេជឿថាវិញ្ញាណរបស់ ទ្រង់គឺគង់នៅ លើមនុស្សនោះ។ ហើយវិញ្ញាណអាក្រក់បានចេញពីមនុស្សទៅ ការឈឺចាប់និងជំងឺ ផ្សេងៗ

បានចេញពីពួកគេ ព្រោះដោយគេជឿ។ ហើយឥឡូវ ទូលបង្គំបានដឹង ព្រះអម្ចាស់ ទូលបង្គំទាំងអស់គ្នាមិនមែនជាប៉ុលជាអ្នកបរិសុទ្ធទូលបង្គំទាំងអស់គ្នាដឹងថា ទ្រង់នៅតែ ជាអង្គព្រះយេស៊ូវដដែល។ ហើយទូលបង្គំរាល់គ្នាសូមអធិស្ឋានដើម្បីអោយទ្រង់តម្កើង សេចក្តីស្មោះត្រង់របស់មនុស្សទាំងនេះ។

10 ហើយនៅពេលមួយមានអ្នកនិយាយទៅកាន់ជនជាតិអ៊ីស្រាអែលថា ចូរព្យាយាមគោរពតាមព្រះជាម្ចាស់ ត្រូវបានជាប់ក្នុងអន្ទាក់នៃសមុទ្រនៅខាងមុខគេ ភ្នំនៅខាងជ្រុងម្ខាង កងទ័ពរបស់ស្តេចផារ៉ោនដេញតាម។ ហើយមានម្នាក់ទៀតពោលថា "ព្រះជាម្ចាស់ទតមើលមកពីសសរភ្លើង ជាមួយព្រះនេត្រនៃព្រះពិរោធ ហើយសមុទ្រញាប់ញ័រ និងរលកញែកទឹកជាផ្លូវ សម្រាប់អ៊ីស្រាអែលឆ្លងកាត់ទៅទឹកដីសន្យា។"

11 ឱព្រះអម្ចាស់សូមទ្រង់ទតមើលម្តងទៀត ពេលដែលកញ្ចប់ទាំងនេះដាក់ លើរាងកាយ អ្នកជំងឺ ក្នុងការរំលឹកដល់ព្រះបន្ទូលរបស់ទ្រង់។ ហើយសូមអោយជំងឺទាំងនោះមានភាពភ័យខ្លាច តាមរយៈការមើលឃើញ ព្រះលោហិត របស់ព្រះ បុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទជាអង្គដែលសុគត់សម្រាប់ទុក្ខវេទនានេះ។ ហើយសូមអោយពួកសត្រូវទាំងមានការភ័យញ័រ និងចេញទៅឆ្ងាយ ដែលមនុស្សទាំងនោះ នឹងបានធ្វើដំនើរទៅក្នុងសេចក្តីសន្យាដែល "លើសអ្វីទាំងអស់" ដែលវា ជាព្រះហរទ័យទ្រង់ "អោយទូលបង្គំរាល់គ្នាមានភាព ចម្រើនល្អនៃសុខភាព។" សូមអនុញ្ញាតិផង ឱព្រះបិតា ព្រោះទូលបង្គំទាំងអស់នឹងបញ្ជូនជាមួយសេចក្តីទាំងនោះ—ជាមួយឥរិយាបថនៅក្នុងចិត្តរបស់ទូលបង្គំ។ ហើយនោះជាទិសដៅរបស់ទូលបង្គំរាល់គ្នា។ ទូលបង្គំសូមបញ្ជូនដោយព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។

អរគុណបងប្រុស ក្លេរី។ សូមអរគុណ លោក។

12 ដូច្នេះនៅយប់នេះជាការបិទនៃកម្មវិធីការរីកផុសផុលនេះ ខ្ញុំមិនដឹងទេថា វាត្រូវ បានចាក់ផ្សាយឬក៏អត់ ប៉ុន្តែខ្ញុំចង់និយាយ(បើមិន)ទៅកាន់ទស្សនិកជនវិទ្យុថា នេះជាការជួបជុំដ៏ល្អបំផុតក្នុងចំនោមការប្រជុំខ្ញុំធ្លាប់មានជាច្រើន ច្រើនឆ្នាំ។ វាមាន មានលក្ខណៈមុតមាំ រំពងគួរអោយពេញចិត្តបំផុត ជាការប្រជុំគ្នាពេញដោយការ ស្រុះស្រួលដែលខ្ញុំអាចនៅបានយ៉ាងយូរ។

13 ប្រុសម្នាក់និយាយថា "យើងនៅតាមរលកធាតុអាកាសរហូតដល់ម៉ោង៤:១៥នាទី បងប្រុស។ ហើយពួកគេកំពុងតែស្តាប់អ្នក ទូទាំង កាលីហ្វញ៉ាខាងត្បូង ចេញទៅដល់តំបន់កោះ និងកប៉ាល់។ យើងបានទទួល សារពីពួកគេមក។ ដូច្នេះអ្នកមានទស្សនិកជនដ៏ច្រើនរាប់ម៉ឺននិងរាប់លាន"—Ed.]។ អរគុណលោក។ នោះជាការល្អណាស់។ រីករាយណាស់ដោយបានឮពីដំណឹងនេះ។ សូមព្រះប្រទានពរទាំងអស់គ្នា។

14 ហើយ វាជាប្រាកដណាស់ ខ្ញុំមានទឹកក់ក្តៅមួយនៅក្នុងចិត្ត ចំពោះព្រះវិហារអ៊ិនជែលឡឹស ព្រោះវា បានឈរពេញជំហសម្រាប់ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។ ហើយ ឥឡូវវា—វាហាក់ដូចជាមានលក្ខណៈផ្ទាល់ខ្លួនសម្រាប់ខ្ញុំ។ វាហាក់ដូចជាថា បន្ទាប់ពីប្រជុំគ្នាគ្រប់គ្នានឹងមើលឃើញវិញ្ញាណដ៏ល្អ ខ្ញុំហាក់ដូចជា ខ្ញុំគឺជាម្នាក់ក្នុងចំណោមអ្នករាល់គ្នា ដែលខ្ញុំមិនធ្លាប់ធ្វើបែបនេះពីមុនមក។ ការអធិស្ឋានរបស់ខ្ញុំគឺសូមអោយព្រះប្រទានពរដល់អ្នក។ ហើយ...[សម្លេងទះដៃរបស់ទស្សនិកជន—Ed។] សូមអរគុណដ៏ស្មោះស្ម័គ្រ។

15 ឥឡូវ វាត្រូវបានបញ្ជូនអោយនៅថ្ងៃនេះ ខ្ញុំនឹងពីរឿងមួយប្រាប់អ្នកមួយ សន្ទុះរឿងជីវិតរបស់ខ្ញុំ។ នោះជាការ—ការលំបាកសម្រាប់ខ្ញុំ។ នេះជាលើក ដំបូងដែលខ្ញុំព្យាយាមចូលទៅចំពោះវារយៈពេលជាច្រើនឆ្នាំនេះ។ ហើយខ្ញុំក៏មិន មានពេលទៅលម្អិតដែរ ប៉ុន្តែនឹងនិយាយខ្លះៗ។ ហើយនៅចំនុចនេះ ខ្ញុំបានធ្វើ កំហុសយ៉ាងច្រើន។ ហើយខ្ញុំពេញចិត្ត ដែលអ្នកនៅតំបន់វិទ្យុ និងអ្នកដែល មានវត្តមាន អ្នកនឹងមិនយកកំហុសរបស់ខ្ញុំធ្វើជាថ្មដំពប់ឡើយ ប៉ុន្តែជាថ្មជាន់ជើង ដើម្បីនាំអ្នកទៅកៀកនឹងព្រះអម្ចាស់។

16 ដូច្នេះ យប់នេះគាត់អធិស្ឋានត្រូវបានចែកអោយកម្មវិធីប្រោសអោយជា យប់នេះ។ ឥឡូវ ពេលយើងនិយាយពី កម្មវិធីប្រោសអោយជា មិនមែនមាន ន័យថាយើងព្យាបាលនរណាម្នាក់ទេ យើងនឹង "អធិស្ឋានអោយនរណាម្នាក់។" ព្រះនឹងប្រោសអោយជា។ ទ្រង់មានព្រះគុណណាស់ដល់រូបខ្ញុំ កាលដែលទ្រង់ឆ្លើយតបសេចក្តីអធិស្ឋាន។

17 ហើយខ្ញុំបានពិភាក្សាជាមួយនាយកនៃអ្នកផ្សាយដំណឹងល្អដ៏ល្បីល្បាញម្នាក់ នាពេលមួយកន្លងមក ហើយ—ហើយត្រូវបានសួរថា ហេតុអ្វីបានជាអ្នកផ្សាយដំណឹងល្អនេះមិនអធិស្ឋានអោយអ្នកជំងឺ។ ហើយអ្នកផ្សាយដំណឹងល្អនោះ

បាននិយាយតបទៅកាន់នា—នាយក គ្រប់គ្រងរបស់ការជួបជុំខ្ញុំថា "បើសិន... អ្នកផ្សាយដំណឹងល្អនេះជឿលើការប្រោសអោយជាមកពីព្រះជាម្ចាស់។ ប៉ុន្តែបើសិនជាគាត់ចាប់ផ្តើមអធិស្ឋានអោយអ្នកជំងឺ វានឹងចូលមកកាត់មុខរបស់កម្មវិធីគាត់ហើយ ព្រោះគាត់ត្រូវបានក្រុមជំនុំជាអ្នកឧបត្ថម្ភ។ មានក្រុមជំនុំជាច្រើនក្នុងចំនោមពួកគេជាច្រើននោះមិនជឿលើការប្រោសអោយជាមកពីព្រះជាម្ចាស់ឡើយ។"

18 ដូច្នេះខ្ញុំមានការគោរពចំពោះអ្នកផ្សាយដំណឹងល្អ ព្រោះគាត់រក្សាទីតាំងរបស់គាត់ ប៉ុស្តិ៍នៅក្នុងតួនាទីរបស់គាត់។ ប្រហែលជាគាត់អា...ខ្ញុំមិនអាចយកកន្លែងគាត់បានទេ ហើយខ្ញុំសង្ស័យថាតើគាត់អាចជំនួសកន្លែងខ្ញុំបានទេ។ យើងទាំងអស់គ្នាមានកន្លែងនៅក្នុងនគររបស់ព្រះជាម្ចាស់។ យើងនឹងចូលរួមទាំងអស់គ្នា។ អំណោយទានខុសគ្នា ប៉ុន្តែមានវិញ្ញាណដូចគ្នា។ ការសម្តែងចេញខុសគ្នា ខ្ញុំមានន័យតាមការនិយាយ ប៉ុន្តែមានវិញ្ញាណតែមួយ។

19 ហើយ ឥឡូវយប់នេះកម្មវិធីនឹងចាប់ផ្តើម...ខ្ញុំគិតថាពួកគេនិយាយ ខនសឺតចាប់ផ្តើមនៅម៉ោង៦កន្លះ។ ហើយឥឡូវបើអ្នកនៅក្នុងតំបន់វិទ្យុ ចូរចូលទៅស្តាប់ចុះ។ វា...វាល្អណាស់ ល្អជានិច្ច។

20 ហើយ ខ្ញុំចង់និយាយថាកាតអធិស្ឋាននឹងត្រូវបានចែកជូនភ្លាមៗបន្ទាប់កម្មវិធី គឺបន្ទាប់ពីកម្មវិធីនេះត្រូវបញ្ចប់ បើសិនជាអ្នកនៅទីនេះ ហើយចង់បានកាតអធិស្ឋាន។ ខ្ញុំត្រូវបានណែនាំអោយនៅទីនោះកាលកន្លងទៅថ្មីៗ កូនប្រុសខ្ញុំ ឬលោកមឺសស៊ី ឬលោក ហ្គូដ ពួកគាត់នឹងចែកកាតជូន។ ចូរនៅកន្លែងអង្គុយរបស់អ្នកចុះ។ គឺបន្ទាប់ពីកម្មវិធីបានចប់ ចូរនៅកន្លែងអង្គុយ ហើយក្មេងប្រុសៗអាចចុះទៅតាមជួរហើយនាំយកកាតទៅចែកជូនលឿនបំផុតតាមតែអាចធ្វើទៅបាន។ មិនថានៅតាមយ៉រ ឬនៅលើកម្រាល នៅកន្លែងណាក៏ដោយ នៅទីលានខាងក្រោម ឬនៅកន្លែងណាដែលអ្នកនៅក៏ដោយ នៅកន្លែងអង្គុយដដែលដូច្នេះក្មេងប្រុសៗនឹងដឹងអ្នកនៅទីនោះ ដើម្បីយកកាតអធិស្ឋាន។ ហើយបន្ទាប់មកយប់នោះយើងនឹងអធិស្ឋានដល់អ្នកជំងឺ។ ហើយបើព្រះជាម្ចាស់ទ្រង់មិនផ្លាស់ប្តូរគនិតខ្ញុំទេ ខ្ញុំចង់អធិប្បាយលើប្រធានបទដែលខ្ញុំចង់អធិប្បាយនៅយប់នេះគឺ បើទ្រង់បើកសម្តែងឲ្យទូលបង្គំបានឃើញព្រះវរបិតា ទូលបង្គំទាំងឡាយនឹងបានស្កប់ចិត្ត។

21 ឥឡូវខ្ញុំចង់អានអត្ថបទនៅរសៀលនេះ គឺចាប់ផ្ដើមពីប្រធានបទ រឿងជីវិត គឺមាននៅក្នុគម្ពីរហេព្រើរ ជំពូកទី១៣ ហើយចូរចាប់ផ្ដើមពីទីនេះ...ខ្ញុំនិងនិយាយនៅក្នុងខ១២។

*ព្រះយេស៊ូវក៏ដូចច្នោះដែរ ព្រះអង្គរងទុក្ខនៅខាងក្រៅទីក្រុង ដើម្បីប្រោសប្រជាជនអោយបានបរិសុទ្ធ ដោយសារព្រះលោហិតព្រះ អង្គផ្ទាល់។*

*ដូច្នេះយើងត្រូវតែចាកចេញពីជំរុំ...ទៅរកព្រះអង្គទាំងស៊ូទ្រាំអោយគេប្រមាថមើលងាយ*

*រួមជាមួយព្រះអង្គដែរយើងគ្មានក្រុងដែលស្ថិតស្ថេរគង់វង្សរហូតឡើយ យើងខំស្វែងរកក្រុងដែលនឹងមាននៅពេលខាងមុខនោះវិញ។*

22 ឥឡូវមានប្រភេទអត្ថបទ។ សម្រាប់ អ្នកឃើញទេ វាជារឿងជីវិត ឬអ្វីទៀតដែលទាក់ទងនឹងជីវិតមនុស្ស យើងមិនមែនតម្កើងការនោះទេ ហើយជាពិសេសអតីត—អតីតកាលរបស់មនុស្ស តើវាងងឹតដូចជាជីវិតខ្ញុំដែរឬទេ។ ប៉ុន្តែខ្ញុំគិតថាបើយើងអានអត្ថបទគម្ពីរ ព្រះជាម្ចាស់នឹងប្រទានពរដល់អត្ថបទគម្ពីរ។ ហើយគំនិតខ្ញុំគឺៈ

*យើងគ្មានក្រុងដែលស្ថិតស្ថេរគង់វង្សរហូតឡើយ យើងខំស្វែងរកក្រុងដែលនឹងមាននៅពេលខាងមុខនោះវិញ។*

23 ឥឡូវខ្ញុំដឹងថាអ្នកពិតជាស្រឡាញ់ជាប់ចិត្តនឹង ឡូសអេនជីឡេស។ អ្នកមានសិទ្ធិនៅទីនោះ។ វាជាក្រុងធំ ស្អាតអស្ចារ្យ។ ជាមួយនឹងផ្សែងលាយអ័ព្ទ និង អ្វីផ្សេងទៀត តែវានៅតែជាក្រុងដែលស្អាត អាកាសធាតុល្អ។ ប៉ុន្តែក្រុងនេះមិន អាចបន្តគង់នៅទេ។

24 ខ្ញុំបានឈរនៅក្នុងក្រុងរ៉ូម(ជាក្រុងរបស់ចក្រភពធំ) ហើយក្រុងជាច្រើនដែលបានគិតថា ពួកគេនឹងសង់ជាអមតៈ ហើយទោះបីជាជីកជម្រៅ២០ហ្វីតក៏នៅតែឃើញសំណល់បំផ្លាញក្រុងដែរ។

25 ខ្ញុំបានឈរនៅកន្លែងដែលស្ដេច ផារ៉ោនមានរាជាណាចក្រដ៏ធំរបស់គេ ហើយអ្នកនឹងជីកទៅក្នុងដីរកឃើញកន្លែងដែលស្ដេចផារ៉ោន បានគ្រប់គ្រង។

26 យើងទាំងអស់គ្នាចូលចិត្តគិតពីក្រុងនិងកន្លែងរបស់យើង។ ប៉ុន្តែសូមចាំថា វាមិនអាចគង់វង្សរហូតឡើយ។

27 ពេលខ្ញុំនៅជាក្មេងប្រុសម្នាក់ខ្ញុំចូលចិត្តទៅកន្លែងដើមម៉ាប។ នៅតំបន់ជនបទរបស់យើងមានឈើមាំៗជាច្រើន។ ហើយយើងក៏មានដើមម៉ាបនេះ។ ដើមម៉ាបផ្អែម យើងហៅថា "ម៉ាបរឹង" និង "ម៉ាបទន់។" ដើមឈើធំសំបើមនេះជាដើមឈើដែលស្អាតបំផុត។ ហើយពេលខ្ញុំចេញមកពីចំការពីការងារនៅក្នុងការច្រូចកាត់ហើយ—ហើយការប្រមូលផល ខ្ញុំចូលចិត្តទៅកន្លែងមានដើមឈើធំ និង—និងអង្គុយក្រោមនោះ និង—និងសម្លឹងទៅលើ។ ហើយខ្ញុំអាចមើលឃើញ ភាពធំមហិមារបស់វា មែកដ៏មាំដែលយោលតាមខ្យល់ គល់ធំសម្បើម។ ហើយខ្ញុំនិយាយ "អ្នកដឹងទេខ្ញុំជឿថាដើមឈើនេះមាននៅទីនេះរាប់រយនិងរាប់រយ ឆ្នាំមកហើយ" មិនជាយូប៉ុន្មានឡើយ ខ្ញុំបានមើលទៅដើមឈើវ័យចំណាស់ វាក្លាយជាចំរៀកទៅហើយ។

28 "យើងគ្មានក្រុងដែលស្ថិតស្ថេរគង់វង្សរហូតឡើយ។" ទេ គ្មានអ្វីដែលនៅលើផែនដីនេះ ដែលអ្នកអាចមើលឃើញ នៅមានរហូតឡើយ។ វាត្រូវមានទីបញ្ចប់។ អ្វីទាំងអស់ដែលអាចស្លាប់បាន ត្រូវតែប្រាប់អោយដឹងពីភាពអមតៈ។ ដូច្នេះមិនថាយើងសង់ផ្លូវធំរបស់យើងល្អប៉ុណ្ណាទេ ការគូសប្លង់ល្អប៉ុណ្ណា វាទាំងអស់ត្រូវតែរលាយ ទៅ ព្រោះនៅទីនេះគ្មានអ្វីដែលគង់វង្សឡើយ។ មានតែអ្វីដែលមើលមិនឃើញប៉ុណ្ណោះដែលនៅគង់វង្ស។

29 ខ្ញុំចាំពីផ្ទះដែលយើងរស់នៅ តែជាផ្ទះដេកដួល វាជាផ្ទះចាស់ដួលមួយ ហើយមានស្នាមប្រេះភក់។ ខ្ញុំ...ប្រហែលមនុស្សជាច្រើនមិនដែលឃើញផ្ទះចាក់បំពេញដោយភក់ឡើយ។ ប៉ុន្តែវាត្រូវបានចាក់បង្គរដោយភក់ និងគល់ឈើធំដែលនៅក្នុងផ្ទះចាស់ខ្ញុំគិតថាផ្ទះអាចឈរនៅរាប់រយឆ្នាំ។ ប៉ុន្តែអ្នកដឹងទេ សព្វថ្ងៃនៅឯណាដែលផ្ទះឈរនៅក្នុងគម្រោងផ្ទះ។ វាមានភាពខុសគ្នាខ្លាំងណាស់។ គ្រប់យ៉ាងមានការប្រែប្រួល។ ប៉ុន្តែ...

30 ហើយខ្ញុំធ្លាប់ឃើញឪពុករបស់ខ្ញុំ គាត់រាងទាបបន្តិច ធាត់កន្លឿ កម្លាំងខ្លាំងហើយគាត់ជាបុរសតូចខ្លាំងបំផុតម្នាក់ដែលខ្ញុំស្គាល់។ ខ្ញុំជួបលោក ខូត ជាដៃគូការងាររបស់គាត់ ធ្លាប់ធ្វើការជាមួយនៅកន្លែងកាប់ឈើ គាត់ជាអ្នកកាប់ឈើហើយជាងមួយឆ្នាំកន្លងមកហើយនេះ លោកខូតបានក្លាយជាមិត្តល្អម្នាក់របស់ខ្ញុំ

ហើយជាសង្ឃនៅក្នុងព្រះវិហារ ហ្វឹសបាបទីស្ទ ហើយគាត់និយាយថា "ប៊ីលលីអ្នកគួរតែក្លាយជាបុរសមានអំនាចម្នាក់។"

ហើយខ្ញុំនិយាយថា "ទេ ខ្ញុំមិនអាចទេ លោក ខូត។"

31 គាត់និយាយ "បើអ្នកធ្វើតាមឪពុករបស់អ្នក អ្នកនឹងអាច។" និយាយ "ខ្ញុំបានឃើញថាបុរសម្នាក់ មានទំងន់១៤០ផោន លើកឈើលើរទេះតែម្នាក់ឯង ហើយ ទម្ងន់គល់ឈើនោះគឺ៩០០ផោន។" គាត់ដឹងពីរបៀបធ្វើ។ គាត់ជាបុរសខ្លាំងម្នាក់។ ខ្ញុំតែងឃើញគាត់មកដល់កន្លែងសម្អាតខ្លួន និងត្រៀមជាស្រេចសម្រាប់អាហារ ពេលល្ងាច ពេលដែលម៉ែហៅគាត់មក។

32 ហើយយើងមានដើមម៉ាបចាស់មួយនៅមុខចំការ ហើយហើយមានពីរបីដើមនៅក្រោយចំការ។ ហើយនៅកណ្តាលដើមឈើ នោះមានកញ្ចក់រាងចាស់មួយកញ្ចក់បែក ជាកញ្ចក់ ធំមួយ។ ហើយវាត្រូវបានសៀតជាប់នៅចំហៀងដើមឈើដែលមានដែកគោលបត់ចូលក្នុង។ ជារបៀបនៃអ្នកដែលជាងឈើ ស្គាប់ទៅហៅថា "ទំពក់ព្យួរអាវធំ។" វាត្រូវបានបត់ចូលក្នុងដើម្បី ព្យួរកញ្ចក់អោយជាប់នៅទីនោះ។ ហើយមានក្រាស់សំណចាស់មួយ។ តើមានប៉ុន្មានអ្នកដែលធ្លាប់ឃើញក្រាស់សំណ...ជាក្រាស់សំណម៉ូដចាស់? ខ្ញុំធ្លាប់ឃើញវា។

33 ហើយមានជើងម៉ាសម្អាតតូចមួយ ជាក្តារតូចមួយមាន ជើងរាងទ្រេតនៅពីក្រោមហើយវាក៏ជាប់ជាមួយដើមឈើដែរ។ មានបំពង់ទឹកស្ពាន់ចាស់ពាក់កណ្តាល ហើយយើងបូមទឹកចេញ ហើយយើងលាងសម្អាតអ្វីៗ នៅកន្លែងដើមឈើចាស់នេះ។ ហើយលោកយាយធ្លាប់ធ្វើ ថង់ច្រកអាហារនិងធ្វើកន្សែងនៅទីនេះដែរ។ មានអ្នកធ្លាប់ប្រើកន្សែងពោះគោធ្វើពីបាវច្រកអាហារទេ? ខ្ញុំពិតជាមានអារម្មណ៍ថាដូចនៅផ្ទះពេលនេះ។ ហើយកន្សែងពោះគោនោះធំ ចាស់ហើយគ្រើម! ហើយពេលគាត់គាត់ងូតទឹកអោយយើងជាក្មេងតូចៗ គាត់នឹង...មានអារម្មណ៍ថាដូចជាគាត់ដុសអ្វីៗដែលកប់ ចេញអោយអស់ គឺធ្វើយ៉ាងនេះគ្រប់ពេលដែលគាត់ត្រដុស។ ហើយខ្ញុំចងចាំពីបាវដាក់អាហារចាស់នោះ។ ហើយគាត់ទាញខ្សែរ ចេញមក ធ្វើជារំយោលផ្កាតូចមួយ ជារបៀបតុបតែងឡើង។

34 តើមានប៉ុន្មាននាក់ដែលធ្លាប់ដេកលើ កម្រាលចំបើង? ល្អ ខ្ញុំនឹង—ខ្ញុំនឹងនិយាយ! តើប៉ុន្មាននាក់ដែលស្គាល់ខ្មើយញាត់? ល្អ បងប្រុសក្លេវី ឥឡូវខ្ញុំនៅផ្ទះហើយ ប្រាកដណាស់! កម្រាលចំបើង ល្អ វាមិនយូប៉ុន្មានទេ ព្រោះខ្ញុំជាម្នាក់

ដែលចេញពីរបៀបនោះដែរ ហើយវាគឺ...អូ វា—វាស្រួលដេកណាស់ ល្អណាស់។ ពេល រដូវរងា ពួកគេយកគ្រែស្លាបសត្វមកដេក អ្នកដឹងទេ គឺត្រូវដាក់បំណែក ខ្លះទាញពង្រីកខាងចុងព្រោះព្រិលបក់មកចូលក្នុងស្នាម—ស្នាម—ស្នាមប្រេះ ក្នុង ផ្ទះ អ្នកដឹង ទេ នៅកន្លែងដែលបន្ទះឈើបាំងជញ្ជាំងបានបាស់ឡើង អ្នកដឹងទេ ហើយព្រិលនឹងត្រូវសម្អាតតាមរយៈវាដែរ។ ហើយ អូ ខ្ញុំអាចចងចាំវាបានល្អណាស់។

35 ហើយផប់ ធ្លាប់មានច្រាសកោរ។ ខ្ញុំ...ឥឡូវនេះអ្នកនឹងយល់។ វាធ្វើពីសក់ពោត ជាច្រាសកោរ ធ្វើពីសក់ពោត។ គាត់យកសាប៊ូទឹកក្បុងចាស់របស់អ្នកម៉ាក់ ដែលគាត់បានលាយ លាយវាហើយក៏យកមកលាបលើមុខដោយប្រើប្រាស់សក់ពោត ហើយក៏កោរដោយកាំបិតកោរត្រង់ធំចាស់មួយ។ ហើយថ្ងៃអាទិត្យគាត់យក ចំ—ចំរៀកក្រដាស មកសៀតជុំវិញកអាវ ពួកគេពាក់ក្រដាសកែវក្រាស់នៅជុំវិញកដូចនេះដើម្បីការ—ពារ—មិនអោយពពុះសាប៊ូធ្លាក់លើកអាវរបស់គាត់។ តើអ្នកធ្លាប់ធ្វើដូច្នោះទេ? ហេតុអ្វី ខ្ញុំអើយ ខ្ញុំអើយ!

36 ខ្ញុំចងចាំបាន ពីរន្ធទឹកចាស់តូចមួយនៅពីក្រោម ដែលយើងធ្លាប់ផឹកទឹកហើយ ដួសទឹករបស់ពួកយើងពីបោយផ្លែឃ្លោកចាស់មួយ។ តើមានប៉ុន្មាននាក់ដែលធ្លាប់ឃើញបោយផ្លែឃ្លោក? ល្អ តើអ្នករាល់គ្នាប៉ុន្មានអ្នកដែលមកពីកេនតាក់គី ដោយរបៀបណាក៏បាន? យេ ល្អ សូមមើលទីនេះ ជាអ្នកកេនតាក់គី។ ល្អ ខ្ញុំនៅ—ខ្ញុំនៅឯ...ខ្ញុំគិតវាជាអូគីឬអាគីនៅខាងក្រៅនោះតែមើលទៅកេនតាក់គី កំពុងចូលមកហើយ។ ជាការពិតពួកគេវាយចូលកេនតាក់គីពីរបីខែកន្លងទៅ អ្នកដឹងទេ ដូច្នេះប្រហែលមានខ្លះក្នុងចំនោមពួកគេមកតាមរបៀបនេះ។

37 ហើយខ្ញុំចងចាំពីលោកពុក ធ្លាប់ចូលមកលាងសម្អាតខ្លួន របស់គាត់ដើម្បីទទួលទានអាហារល្ងាច គាត់មួរដៃអាវឡើង ហើយដៃរបស់គាត់ខ្ចីកន្ដាញ។ ហើយពេលគាត់លូកដៃសម្អាត ជះទឹកមកលើមុខ សាច់ដុំពួនឡើងលើដៃតូចរបស់គាត់។ រួចខ្ញុំនិយាយ "អ្នកដឹងទេ ឪពុករបស់ខ្ញុំនឹងរស់ដល់អាយុមួយរយហាសិបឆ្នាំ។" គាត់ជាមនុស្សខ្លាំងណាស់! តែគាត់ស្លាប់នៅអាយុហាសិប-ពីរឆ្នាំប៉ុណ្ណោះ។ ឃើញទេ? "នេះគឺយើងគ្មានក្រុងដែលគង់វង្សឡើយ។" ជាការពិត។ យើងមិនអាចនៅជាប់បានឡើយ។

38 ឥឡូវ ចូរធ្វើដំណើរបន្តិច គឺយើងទាំងអស់គ្នា។ អ្នកគ្រប់គ្នានៅទីនេះសុទ្ធតែមានរឿងជីវិត ដូចខ្ញុំដែរ ហើយវាជាការល្អដែលលំហែរជាមួយខ្សែផ្លូវនៃការចង

ចាំយូៗម្តង។ តើអ្នកគិតអញ្ចឹងទេ? ចូរត្រឡប់ទៅវិញ ហើយត្រឡប់ទៅមួយភ្លែត ត្រឡប់ ទៅរកបទពិសោធន៍ស្រដៀងគ្នាកាលពីនៅតូចៗ។

39 ហើយឥឡូវផ្នែកដំបូងនៃរឿងជីវិត។ ខ្ញុំនឹងអោយអ្នកនូវការប៉ះពាល់តូចមួយ ព្រោះ វានៅក្នុងសៀវភៅហើយមានគ្នាជាច្រើនក្នុងចំណោមអ្នករាល់គ្នាមាន សៀវភៅ។

40 ខ្ញុំបានកើតនៅក្នុងខ្ទមភ្នំតូចមួយ តាមផ្លូវនៅភ្នំទៅកេនតាក់គី។ គេមាន បន្ទប់មួយដែលយើងរស់នៅ គ្មានព្រំលើកម្រាល មិនមានសូម្បីតែឈើក្រាលផង វាជាផ្នែកម្រាលទទេធម្មតា។ ហើយមានគល់មួយ គល់នោះដាច់ជើងមួយហើយ សល់ជើងតែបីប៉ុណ្ណោះ នោះគឺជាតុរបស់យើង។ ហើយឥវ៉ាន់ទាំងអស់របស់ក្មេងតូចប្រាណហាំ គួរតែត្រូវបានទុកគរនៅជុំវិញនោះ ហើយនៅពីមុខខ្ទមចាស់ ហើយដែលត្រាំនៅ មើលទៅដូចជាបាច់ ដែលដាក់ត្រាំចោលនៅក្នុងធូលី អ្នកដឹងទេ បងប្អូនប្រុសតូចៗទាំងអស់គ្នា។ ពួកយើងមានគ្នា៩នាក់ និងស្រីតូចម្នាក់ហើយ នាងពិតជាមានពេលវេលាគ្រោតគ្រាតណាស់ជាមួយក្រុមក្មេងប្រុសនោះ។ យើង ត្រូវតែ គោរពនាង រហូតដល់សព្វថ្ងៃនេះ គឺដូចអ្វីដែលយើងបាន ធ្វើនៅថ្ងៃទាំង នោះ។ នាងមិនអាចទៅឯណាជាមួយយើងគ្រប់កន្លែងបានទេ យើងរត់នៅក្រោយនាងព្រោះនាងជាក្មេងស្រី។ ដូច្នេះយើងមិនអាចធ្វើវាបានទេ អ្នកដឹងទេ។ ដូច្នេះ យើងបាន...ហើយទាំងអស់...

41 ចងចាំអ្វីដែលនៅពីក្រោយតុ យើងមានកៅអីពីរប៉ុណ្ណោះ វាធ្វើពីសំបកមែកឈើ។ កូនឈើហ៊ីកខរីដាក់ផ្គុំគ្នា ហើយនៅពីក្រោមចងរឹត ដោយសំបកឈើហ៊ីកខរី។ មានអ្នកណាធ្លាប់ឃើញកៅអីសំបកហ៊ីកខរីទេ? បាទ។ ហើយខ្ញុំនៅឮ អ្នកម៉ែនៅឡើយ។ អូ ពេលក្រោយពេលយើងទៅដល់កន្លែងដែលគាត់មានកម្រាលឈើ ជាមួយនឹងទារកនៅលើភ្លៅរបស់គាត់*ដូច*នេះ ហើយយោកកៅអីចាស់ដូចជា ឡាន ដូចជាឡាន ឮសូរអុកកម្រាលខ្លាំងៗ។ ហើយខ្ញុំចាំបានពីរបៀបមើលថែ ក្មេងតូចមិនអោយចេញ ទៅក្រៅ ពេលដែលគាត់នៅធ្វើការឬធ្វើអ្វីមួយ គាត់ដាក់ កៅអីផ្តេក ឬដាក់អ្វីអោយតែបានបាំងមាត់ទ្វា ដើម្បីការពាកូនតូចមិនអោយចេញ ក្រៅពេលដែលគាត់ទៅរន្ធទឹកដងទឹក ឬធ្វើអ្វីៗផ្សេងទៀត។

42 ហើយអ្នកម្ដាយគាត់មានអាយុ១៥ឆ្នាំពេលដែលខ្ញុំកើតមក លោកពុកគាត់មាន អាយុ១៨ឆ្នាំ។ ហើយខ្ញុំជាកូនទីមួយក្នុងចំនោមកូន៩នាក់។ ហើយពួកគេក៏បានប្រាប់ពីរបៀបដែលខ្ញុំកើតមក...

43 ឥឡូវ យើងពីមុនក្រណាស់ គឺជាអ្នកក្របំផុតក្នុងចំនោមអ្នកក្រ។ យើង មិនមានសូម្បីតែបង្អួចនៅក្នុងបន្ទប់តូចមួយ។ វាដូចជាទ្វាតូចមួយដែលអ្នកបើក។ ខ្ញុំសង្ស័យថាតើអ្នកធ្លាប់ ឃើញអ្វីដូចនោះឬអត់។ គឺជាទ្វាឈើតូចមួយដែលបើកជំនួស បង្អួច អ្នកបើកវាពេលថ្ងៃហើយបិទពេលយប់។ យើងមិនមានអគ្គិសនី បើក ឬ ប្រេងកាតដុតនៅថ្ងៃទាំងនោះទេ យើងមានរបស់មួយដែលហៅថា "ចង្កៀង ដុំខ្លាញ់។" ឥឡូវខ្ញុំមិនដឹងថាអ្នកធ្លាប់ស្គាល់ចង្កៀងដុំខ្លាញ់រឺអត់។ ល្អតើអ្នក...ហើយតើអ្នកធ្លាប់ទិញទេ...ដុតចំណាងស្រល់? គឺយកចំណាងស្រល់ ហើយដុតវា ហើយដាក់វាទៅក្នុងគម្រប វានឹងឆេះ។ ហើយ វាមាន...ផ្សែងហុយបន្តិច ប៉ុន្តែ ពួកគេមិនមាន គ្រឿង សង្ហារឹម របៀបណាក៏ដោយ ផ្សែងហុយ។ ដូច្នេះវាគ្រាន់តែ...បន្ទប់តូចមួយមាន ផ្សែង។ វាស្រូបផ្សែងហុយ បានល្អណាស់ព្រោះមានដំបូលនៅទីនោះ វាត្រូវ បានស្រូបទៅតាមប្រហោង។ ដូច្នេះវា...

44 ហើយខ្ញុំកើតនៅខែមេសា—ទី៦ ឆ្នាំ១៩០៩។ ពិតណាស់ អ្នកដឹងទេ ឥឡូវធ្វើអោយខ្ញុំមានអាយុទើបតែលើស២៥ឆ្នាំបន្តិចបន្តួចទេ។ ដូច្នេះ ព្រឹកដែលខ្ញុំកើតមក អ្នកម៉ែនិយាយថា ពួកគាត់បើកបង្អួច។ ឥឡូវ យើងមិនមានដុកទ័រមានតែឆ្មប។ គឺត្រឹមតែ...ឆ្មបនោះជាលោកយាយរបស់ខ្ញុំ។ ហើយដូច្នេះពេលខ្ញុំកើតលើកដំបូងគឺចាប់ផ្ដើមយំ ហើយ—ហើយអ្នកម្ដាយចង់ឃើញកូនរបស់គាត់។ ហើយ—ហើយ គ្មានអ្វីដែលជាសជាងកូនរបស់គាត់នោះទេ។ ហើយពេលពួកគាត់បើក បង្អួច គឺពេលព្រឹកប្រហែលជាម៉ោង៥ព្រឹក។ ហើយ...មានបក្សីរ៉ូប៊ីនមួយទុំនៅជិត គម្លោត ព្រៃ។ តើអ្នកធ្លាប់ឃើញរូបភាពវានៅក្នុង—ក្នុងសៀវភៅរបស់ខ្ញុំចំណងជើងរឿង ជីវិតរបស់ខ្ញុំ។ បក្សីរ៉ូប៊ីនចាស់នោះអង្គុយហើយច្រៀងខ្លាំងៗអស់ពីខ្លួន។

45 ខ្ញុំក៏បានស្រឡាញ់បក្សីរ៉ូប៊ីនរហូត។ ឥឡូវក្មេងប្រុសដែលនៅតំបន់វិទ្យុ កុំបាញ់បក្សីរបស់ខ្ញុំ។ អ្នកឃើញទេ ពួកគេ—ពួកគេ—ពួកគេជា...បក្សីរបស់ខ្ញុំ។ តើ អ្នកធ្លាប់ស្ដាប់រឿងព្រេងពីបក្សីរ៉ូប៊ីនទេ របៀបដែលវាមានទ្រូងក្រហម? ខ្ញុំនឹងឈប់ត្រង់នេះបន្តិច។ តើវាមានទ្រូងក្រហមរបៀបណា...មានស្ដេចលើអស់ទាំងស្ដេច

មួយអង្គ សុគតនៅលើឈើឆ្កាង ហើយទ្រង់រងសេចក្តីវេទនាក៏គ្មាននរណាមក ឯទ្រង់ដែរ។ ទ្រង់គ្មាននរណាមកជួយឡើយ។ ហើយមានបក្សីពណ៌ត្នោតមួយចង់ យកដែកគោលចេញពីឈើឆ្កាង ព្យាយាមហើរទៅឈើឆ្កាង ហើយទាញដែកគោល នោះ។ បក្សីនោះខ្លួនតូចពេកក្នុងការ ដែលខ្លួនប្រឹងទាញដែកគោលចេញ ដូច្នេះក៏ ប្រឡាក់ឈាមជាប់នឹងទ្រូងរបស់វាទៅ។ ហើយតាំងពីពេលនោះមកវាក៏មានទ្រូង ពណ៌ក្រហម។ កុំបាញ់វាណាក្មេងប្រុសៗ។ អោយវានៅតែវាទៅ។

46 វាទុំនៅក្បែរបង្អួច ស្រែកចចេចចាចដូចរបៀបសត្វរ៉ូប៊ីនច្រៀង។ ហើយ —ហើយលោកពុកក៏បិទបង្អួចវិញ។ ហើយគាត់ក៏បើកបង្អួចតូចខាងក្រោយ ពន្លឺ នោះដែលអ្នកឃើញក្នុងរូបភាពវិលនៅក្នុងបង្អួច អ្នកម៉ែគាត់និយាយដូច្នេះ ហើយក៏ មានពន្លឺចូលមកដល់គ្រែ។ លោកយាយមិនដឹងថានិយាយយ៉ាងណាទេ។

47 ឥឡូវយើងមិនមែនជា...គ្រួសារជឿសាសនាអ្វីទេ។ អ្នកស្រុកជាអ្នកជឿបែប កាតូលិក។ ហើយខ្ញុំជាសញ្ជាតិអៀឡង់ទាំងសងខាង។ ឪពុករបស់ខ្ញុំជាជនជាតិ អៀឡង់យ៉ាងតឹងរឹង ប្រាណហាំ។ ម្តាយរបស់ខ្ញុំ ហារី លើកលែងតែឪពុករបស់ គាត់ដែលរៀបការជាមួយជនជាតិ ឆេរ៉ូគី អិនឌាន នោះជាការបំបែកតិចតួចនៃ ខ្សែរ ស្រលាយឈាមអៀឡង់។ លោកពុក និងអ្នកម៉ែគាត់មិនទៅព្រះវិហារទេ ហើយក៏មិនបានរៀបការក្នុងព្រះវិហារដែរ ហើយពួកគាត់ មិនមានជឿសាសនា អ្វីឡើយ។ ហើយត្រឡប់ទៅពេលនោះ នៅតំបន់ភ្នំគ្មានវិហារកាតូលិកអ្វីឡើយ។ ដូច្នេះពួកគាត់បានចូលមកជាអ្នកតាំងលំនៅមុនគេគ្រួសារប្រាណហាំ២នាក់ចូល មក ហើយពីការរីកសាយនៃជំនាន់ទាំងមូលរបស់គ្រួសារប្រាណហាំ នេះជាខ្សែរ វង្សត្រកូល។

48 ហើយគាត់ក៏បើក...ពេលពួកគាត់បើកបង្អួចហើយឃើញពន្លឺនៅទីនោះ ពួកគេ មិនដឹងត្រូវធ្វើអ្វីឡើយ។ លោកពុកបានទិញ (អ្នកម៉ែនិយាយ) ទិញមួយគូសម្រាប់ ព្រឹត្តិការណ៍ទាំងមូលនោះ។ គាត់កំពុងឈរជាមួយ...ដៃគាត់នៅក្នុងក្រណាត់ ការពារទារកដែលចាស់ ប្រៀបដូចជាមនុស្សក្នុងព្រៃនិងអ្នកកាប់ឈើប្រើនៅ សម័យនោះ។ ហើយវាធ្វើអោយពួកគាត់ខ្លាច។

49 ល្អ បន្ទាប់ពីខ្ញុំធំឡើងប្រហែលដប់ថ្ងៃ ឬ អ្វីៗ ពួកគាត់បាននាំខ្ញុំទៅព្រះវិហារ បាបទីស្ទតូចមួយហៅថា "ផូសូម ឃីងដុម" ព្រះវិហារ ផូសូម ឃីងដុម បាបទី ស្ទ។ ឈ្មោះនោះគឺដូច្នោះ។ កាលនោះមានអ្នកអធិប្បាយផ្លាស់វេន អ្នកបាបទីស្ទ

អធិប្បាយរបៀបបុរាណចូលមករាល់ពីរខែម្តង។ លើ...សមាជិកអាចមាន កម្មវិធីតូចមួយជុំគ្នា ពួកគេច្រៀងប៉ុន្តែពួកគេមិនមានការអធិប្បាយផ្លាស់វេនញឹកញាប់លើពត៌មានវេននោះទេ។ ពួកគេអោយតង្វាយដល់គាត់ជា ល្ពៅមួយបាវនិងអ្វីមួយចំនួនស្រដៀងនោះអ្នកដឹងទេ មនុស្សនៅទីនោះគេផុសផុលក្នុងការអោយណាស់។ ហើយមានអ្នកអធិប្បាយចាស់ចូលមក ហើយគាត់បាន ផ្តល់សេចក្តីអធិស្ឋានដល់ខ្ញុំជាទារកតូច។ នោះជាដំណើរដំបូងទៅព្រះវិហាររបស់ខ្ញុំ។

50 នៅពេលមួយឆ្នាំកន្លង...ក៏ប្រហែលជាជាងពីរឆ្នាំបន្តិច និមិត្តដំបូងបានកើតមាន។

51 ល្អ ពួកគេបានប្រាប់អ្នកនៅជុំវិញភ្នំថា "ពន្លឺនេះបានចូលមកៗ។" ដូច្នេះពួកគេក៏ព្យាយាមរកវា។ ពួកគាត់ខ្លះបាននិយាយថាវាជាពន្លឺព្រះអាទិត្យដែលចាំង ជាមួយកញ្ចក់នៅក្នុងផ្ទះ។ ប៉ុន្តែគ្មានកញ្ចក់នៅទីនោះទេ។ ហើយព្រះអាទិត្យក៏ មិនទាន់រះដែរ វាលឿនពេកបើរះនៅម៉ោង៥ព្រឹក។ ដូច្នេះ អូ ពួកគេក៏រំលងចោលទៅ។ ហើយនៅពេលនោះខ្ញុំប្រហែល...អាយុជិត៣ឆ្នាំ...

52 ឥឡូវខ្ញុំត្រូវតែស្មោះត្រង់។ មានអ្វីដែលខ្ញុំមិនចង់និយាយ ហើយខ្ញុំ ចង់រំលងចោលនិងមិនត្រូវនិយាយឡើយ។ ប៉ុន្តែប្រាប់ការពិតទៅចុះអ្នកត្រូវតែ និយាយការពិតមិនថាជាមួយខ្លួនផ្ទាល់ឬជាមួយមនុស្សរបស់អ្នក។ ត្រូវតែស្មោះត្រង់ ហើយនៅតែស្មោះត្រង់។

53 ឪពុកខ្ញុំ គាត់នៅឆ្ងាយពីអ្នកជឿសាសនាណាស់។ គាត់ជាក្មេងប្រុស ជំពូកអ្នកភ្នំហើយផឹកស្រាជានិច្ច គ្រប់ពេល។ គាត់ក៏មានបញ្ហាខ្លះពីរឿងវាយគ្នា ហើយមានមនុស្សពីរបីនាក់ស្ទើរតែស្លាប់ទៅហើយពេលវាយគ្នា បាញ់គ្នា កាប់គ្នា ដោយកាំបិត នៅក្នុងពិធីជប់លៀងនៅតំបន់ភ្នំអញ្ចឹង។ ហើយលោកពុកគាត់ជាមេដឹកនាំម្នាក់ក្នុងរង្វង់ការវាយតប់នេះ ព្រោះមានមិត្តភក្តិរបស់គាត់ម្នាក់ត្រូវបានទទួលការឈឺចាប់ ហើយក៏បានវាយគេ ម្នាក់នឹងកៅអី។ ហើយមាន...បុរសម្នាក់ នោះទាញកាំបិតចេញមក ហើយប្រុងនឹងកាប់មិត្តភក្តិរបស់លោកពុកនៅលើដីដោយកាំបិទនោះក្នុងចិត្តរបស់គាត់ លោកពុកក៏សម្តែងចំណែករបស់គាត់។ ដូច្នេះវាជាការ វាយដ៏ខ្លាំងក្លាមួយព្រោះពួកគេបានបញ្ជូនតម្រួតពីបឹកវីលមានចម្ងាយរាប់ម៉ាយជិះ សេះដេញតាមពុក។

54 ដូច្នេះបុរសនោះក៏ដេកនៅស្ថានភាពចំនុចស្លាប់។ ប្រហែលមានមនុស្ស ខ្លះកំពុងស្តាប់។ ខ្ញុំនឹងហៅឈ្មោះគាត់ វីល យ៉ាប័ទ ជាឈ្មោះរបស់គាត់។ ពួកគេប្រហែលជា...ខ្ញុំគិតថាមានពួកគាត់ខ្លះនៅឯកាលីហ្វញ៉ា ក្មេងប្រុសៗរបស់គាត់។ ប៉ុន្តែគាត់ជាមនុស្សចូលចិត្តសម្លុតគេ មានកម្លាំង សម្លាប់ក្មេងប្រុសរបស់គាត់ដោយផ្លូវរថភ្លើងមានរបង។ ដូច្នេះគាត់—គាត់ជាមនុស្សមានអំនាចនិងឃោរឃៅ។ ដូច្នេះមានការវាយដោយកាំបិតមួយដ៏សម្បើមរវាងគាត់នឹងលោកពុក។ ហើយឪពុកខ្ញុំស្ទើរតែសម្លាប់បុរសនោះ ដូច្នេះគាត់ត្រូវរត់ចាកចេញពី កេនតាក់គីឆ្លងទៅអិនឌៀអាយណា។

55 ហើយនៅពេលនោះគាត់មានបងប្រុសដែលរស់នៅ នៅឡូវីសវិល កេនតាក់គី ហើយជាអ្នកចាត់ចែងជំនួយការអគ្គនាយក របស់ រូតម៉ូសាកស័រមីល នៅក្នុងកេនតាក់គី នៅក្នុងឡូវីសវីល។ ដូច្នេះលោកពុកក៏ចូលទៅរកបងប្រុសរបស់ គាត់។ លោកពុកជាកូនពៅគេ ក្នុងចំនោមបងប្អូនទាំងអស់ ចំនួន១៧នាក់។ ដូច្នេះគាត់ទៅរកបងប្រុសរបស់គាត់ ហើយពេលគាត់ចេញទៅ ស្ទើរតែមួយឆ្នាំ។ គាត់មិនអាចត្រឡប់មកវិញ ព្រោះច្បាប់កំពុងស្វែងរកគាត់។ ហើយពេលយើងបានឮពីគាត់តាមរយៈសំបុត្រ គឺ ឈ្មោះត្រូវបានសរសេរជាឈ្មោះ មនុស្សផ្សេងទៀត ប៉ុន្តែនោះជារបៀបគាត់ប្រាប់ដល់អ្នកម៉ែ ដែលគាត់អាចឮ បាន ពីគាត់។

56 ហើយខ្ញុំចងចាំថ្ងៃមួយនៅរន្ធទឹក (ខ្ទមតូចនេះ) នៅពីក្រោយផ្ទះ។ ហើយ—ហើយបន្ទាប់ពីពេលនោះ...មាន៩...រយៈពេល១១ខែ ខុសគ្នារវាងខ្ញុំនិងប្អូនប្រុស បន្ទាប់ព្រោះគាត់តែងវារ។ ហើយខ្ញុំកំពុងតែមានថ្មធំមួយនៅក្នុងដៃហើយខ្ញុំព្យាយាមប្រាប់គាត់ថា តើខ្ញុំអាចគប់ថ្មនេះចូលទៅក្នុងភក់បានខ្លាំងប៉ុណ្ណា គឺនៅកន្លែងរន្ធទឹកចេញពីដីហើយធ្វើឲ្យមានដីភក់។ ហើយខ្ញុំឮបក្សីមួយកំពុងច្រៀងនៅលើ ដើមឈើ។ ខ្ញុំមើលទៅដើមឈើនោះហើយបក្សីក៏ហើរចេញទៅ ហើយជាពេល ដែលវាបានធ្វើសម្លេងនិយាយមកកាន់ខ្ញុំ។

57 ឥឡូវខ្ញុំដឹងថា អ្នកយល់ថា ខ្ញុំមិនអាចគិតនិងចងចាំរឿងនោះទេ។ ប៉ុន្តែព្រះអម្ចាស់ជាព្រះដែលកាត់ទោសលើផែនដីនិងស្ថានសួគ៌ហើយអ្វីៗដែលនៅក្នុងនោះ ទ្រង់ជ្រាបថាខ្ញុំបានប្រាប់អ្វីដែលជាសេចក្តីពិត។

58 បក្សីនោះ ពេលដែលវាហើរចេញទៅ សម្លេងរបស់វាបានចេញពីកន្លែងដែលបក្សីនោះទុំ ប្រៀបដូចជាខ្យល់ប៉ះនិងគម្ពោតព្រៃហើយវានិយាយថា "អ្នកនឹង

រស់នៅក្បែរក្រុងមួយហៅថា ញូអាល់បាល់នី។" ហើយខ្ញុំបានរស់នៅ ពីពេលនោះមកពេលដែលខ្ញុំមានអាយុ៣ឆ្នាំ ហើយបន្តរហូតមកដល់បច្ចុប្បន្ន គឺនៅឆ្ងាយពីក្រុងរដ្ឋអិនឌៀអាយណា ប្រមាណតែ៣គីឡូម៉ែត្រ។

59 ខ្ញុំបានប្រាប់ម្ដាយរបស់ខ្ញុំពីរឿងនោះ។ ល្អ គាត់គិតថាខ្ញុំគ្រាន់តែស្រមៃ ឬអ្វីមួយតែប៉ុណ្ណោះ។

60 ក្រោយមកយើងបានផ្លាស់ទៅរស់នៅ អិនឌៀអាយណា ហើយលោកពុកទៅធ្វើការអោយមនុស្សម្នាក់ គឺលោកវ៉តថេន ជាអ្នកមាន។ គាត់មាន វ៉តថេនឌីសស្ទីលឡើរី ជាកម្មសិទ្ធរបស់គាត់។ ហើយគាត់មានភាគហ៊ុនដ៏ធំ គាត់ជាមហាសេដ្ឋី ហើយក៏ជាវរសេនីយឯក នៅឡូវីសវីលដែរ និង—និងជាកីឡាបាល់បោះជាដើម។ ហើយយើងរស់នៅក្បែរនោះ។ ហើយលោកពុកគាត់ជាមនុស្សក្រម្នាក់ តែគាត់នៅតែមិនអាចធ្វើការដោយមិនបានផឹកស្រាដដែល ដូច្នេះគាត់—គាត់ធ្វើ ស្រាវិស្គីនៅក្នុង—ក្នុងគ្រឿងប្រដាប់ផលិតស្រា។

61 ហើយ វាជាការលំបាកសម្រាប់ខ្ញុំ ព្រោះខ្ញុំជាកូនច្បងក្នុងចំណោមកូនទាំងអស់។ ខ្ញុំត្រូវតែទៅហើយដងទឹកទៅចាក់នៅក្នុងគ្រឿងប្រដាប់បិតស្រានេះ ដើម្បីរក្សាអោយធុងវណ្ណនោះត្រជាក់ពេលគេកំពុងបិតស្រាវីស្គី។ ហើយគាត់នឹងលក់វា ហើយគាត់នឹងទទួលបានពីរឬបីនៃឧបករណ៍នោះ។ នេះជាផ្នែកដែលខ្ញុំមិនចង់និយាយ ប៉ុន្តែវាជាការពិត។

62 ហើយខ្ញុំចាំបានថាមានពេលមួយ កាត់តាមវាលបោកស្រូវផ្លូវមកផ្ទះ ខ្ញុំយំបណ្ដើរ។ ព្រោះកន្លែងផ្លូវខាងក្រោយឆ្ពោះទៅកាន់ស្រះទឹក...ជាកន្លែងគេបានកាប់ទឹកកកនៅទីនោះ។ មានអ្នករាល់គ្នាជាច្រើនចងចាំពីកាលគេធ្លាប់កាប់ទឹកកកហើយដាក់នៅក្នុងអាចម៍រណា។ ល្អ នេះជារបៀបដែលលោក វ៉តថេន បានរក្សាទុកទឹកកកនៅទីនោះនៅតំបន់ជនបទ។ ហើយលោកពុកជា—ជាអ្នកបើករថយន្តឯកជនអោយគេ។ ហើយពេលដែល...ស្រះនេះពេញដោយត្រី ហើយពេលដែលគេបានទៅកាត់ទឹកកកហើយយកវាមកទុក គឺដាក់ក្នុងអាចម៍រណា បន្ទាប់មកទឹកកកនឹងរលាយក្នុងរដូវក្តៅមកដល់ វាជារបៀបដែលខ្ញុំត្រូវសំអាត ប្រៀបដូចជាបឹងទឹកកកអញ្ចឹងគេអាចប្រើវាបាន មិនមែនសម្រាប់ ផឹកតែសម្រាប់រក្សាទឹកអោយត្រជាក់ ទុកវានៅក្នុងធុងនិងទឹកដោះគោរបស់ពួកគេ និងអ្វីៗទៀត។

63 ហើយថ្ងៃមួយ ពេលកំពុងដងទឹកពីអណ្តូងស្អប់ ជាពេលដែលទីក្រុងកកស្ទះ។ ខ្ញុំមានអារម្មណ៍ពុះកញ្ជ្រោលយ៉ាងខ្លាំងទៅដល់អ្នកមិនបានធ្វើវា គឺខ្ញុំបានមកពីសាលាហើយក្មេងប្រុសទាំងអស់ទៅស្រះទឹកដើម្បីស្ទូចត្រី។ ខ្ញុំចូលចិត្តស្ទូចត្រី។ ដូច្នេះពួកគេបានទៅស្ទូចត្រី តែខ្ញុំមិនបានទៅទេ ព្រោះខ្ញុំត្រូវដងទឹកដាក់គ្រឿងប្រដាប់បិតស្រា។ ជាការពិត ម្តាយរបស់ខ្ញុំ ហាមឃាត់ខ្ញុំ។ ហើយខ្ញុំ...វាជាការលំ បាក។ ហើយខ្ញុំចងចាំពីពេលនោះមក គឺជាពេលដែលមេជើងខ្ញើច ខ្ញុំបានយក ស្នូលពោតចងជាប់នឹងជើងដើម្បីការពារដី។ តើអ្នកធ្លាប់ធ្វើដូច្នេះឬទេ? គឺយកស្នូលពោតមកដាក់ក្រោមជើងអ្នកដូច្នេះ ហើយរុំដោយខ្សែរជុំវិញវា។ វាបានក្តោបមេជើងអ្នកឡើងដូចជាអណ្តើកអើតក្បាល អ្នកដឹងទេ វាដោតជាប់។ អ្នកអាចគូសសម្គាល់គ្រប់កន្លែងដែលខ្ញុំដើរទៅ ដោយសារតែពោតដែលចងនឹងជើងនេះ កន្លែងណាដែលខ្ញុំខ្ញើច អ្នកដឹង។ ខ្ញុំមិនមានស្បែកជើងពាក់ទេ។ ដូច្នេះយើងមិនដែលពាក់ស្បែងជើងឡើយ ជួនកាលពាក់កណ្តាលរដូវរងាផង។ បើសិនជាយើងពាក់ យើង...គឺយើងអាចរើសយកពីអ្នកណា ដែលអោយយើងប៉ុណ្ណោះ។ ហើយ សម្លៀកបំពាក់គឺ អ្វីដែលមានគេអោយយើងជាសប្បុរសធម៌។

64 ហើយខ្ញុំឈប់នៅដើមឈើនេះ ហើយខ្ញុំអង្គុយដោយចិត្តពុះពោរចង់ធ្វើ(វាជាខែកញ្ញា)ព្រោះខ្ញុំចង់ទៅស្ទូចត្រី ខ្ញុំត្រូវតែដងទឹកបីបួនធុងដោយប្រើធុងទឹកអំពៅត្រឹមប្រហែល កំពស់នេះ ពាក់កណ្តាលកាឡុន ព្រោះខ្ញុំនៅជាក្មេងប្រុសតូចអាយុប្រហែល៧ឆ្នាំ។ ហើយខ្ញុំត្រូវចាក់ទឹកក្នុងអាងធំរួចត្រលប់ ទៅដង២ធុងទៀត ហើយត្រឡប់មកវិញ គឺសប់ទឹកឡើង។ នោះជាទឹកដែលយើងមាន។ ហើយវានឹងអស់ចំនួនស្រាវិស្គីដែលដុតម្តងនៅពេលយប់ មនុស្សទាំងអស់ជាមួយលោកពុក ឡើងទៅលើផ្ទះ។

65 ហើយពេលខ្ញុំកំពុងតែយំ មានម្តងនោះខ្ញុំឮអ្វីមួយដូចជាខ្យល់គួច អ្វីដូចនេះ(ឥឡូវខ្ញុំមិនសង្ស័ថា វាឮខ្លាំងពេកនោះទេ) បន្ត "វ៉ូសៗៗៗៗៗ វ៉ូសៗៗៗៗៗៗ" ជាសម្លេងដូច្នោះ។ ល្អ វាជាពេលស្ងាត់គួរអោយធុញទ្រាន់ ហើយខ្ញុំមើលជុំវិញ។ អ្នកដឹងទេមានខ្យល់គួចតូចមួយ ខ្ញុំជឿថាអ្នកហៅវាថា ព្យុះស៊ីក្លូនតូច? ពេញមួយ រដូវស្លឹកឈើជ្រុះ គេបានប្រមូលផលពីចំការពោត អ្នកដឹងទេ ស្លឹកឈើនិងអ្វីទៀតនៅរដូវទឹកកកនៅទីនោះ ស្លឹកឈើទើបតែប្រែពណ៌ប៉ុណ្ណោះ។ ហើយខ្ញុំកំពុងតែនៅ ក្រោមដើមប៉ុបឡាពណ៌សឈរពាក់កណ្តាលផ្លូវចន្លោះ

ជង្រុកស្រូវនិងផ្ទះ—ផ្ទះ។ ហើយខ្ញុំឮសម្លេងនោះ។ ហើយខ្ញុំមើលជុំវិញ វាស្ងាត់ដូចជានៅក្នុងបន្ទប់។ គ្មានស្លឹកឈើណាបក់ទៅណាឡើយ ឬ គ្មានអ្វីសោះ។ ហើយខ្ញុំគិត "តើសម្លេងនោះមកពីណា?" ល្អ ខ្ញុំគិត "ត្រូវតែនៅអោយឆ្ងាយពីទីនេះ។" ជាក្មេងប្រុសម្នាក់។ ហើយវាក៏ឮខ្លាំងឡើងខ្លាំងឡើង។

66 ខ្ញុំលើកធុងតូចឡើងហើយឆេះឆួលក្នុងចិត្តពីរទៅបីដងលើសមុន តម្រង់ផ្លូវទៅមុខ ព្រោះខ្ញុំកំពុងសម្រាក។ ហើយប្រមាណជាចម្ងាយបីបួនហ្វីតពីខ្ញុំ ខ្ញុំបានទទួលរឿងនេះពីមែកដើមឈើធំ ហើយ អូ វាបង្កើតជាសម្លេងបែបនោះ។ ហើយខ្ញុំបែរទៅមើល ពាក់កណ្ដាលដើមឈើនោះមានខ្យល់គួចមួយទៀត នៅជាប់នឹងដើមឈើនោះហើយធ្វើដំនើរជុំវិញជុំវិញ ធ្វើអោយស្លឹកឈើកម្រើក។ ល្អ ខ្ញុំគិតថាមិនមានអ្វីចម្លែកឡើយ ព្រោះវាជាពេលប្រចាំឆ្នាំ ហើយជារដូវស្លឹកឈើជ្រុះ ជាមូលហេតុខ្យល់គួចនោះកើតមាន។ តូច...យើងហៅថា "ខ្យល់គួច" ហើយពួកវា—ពួកវា បានស្រូបដីឡើង។ អ្នកអាចឃើញនៅវាលខ្សាច់ដូច្នោះដែរ។ ដូចគ្នា។ ដូច្នេះខ្ញុំមើល ប៉ុន្តែវាមិនចេញទៅឡើយ។ ជាធម្មតាវាគ្រាន់តែមួយហ្វីតនៃរយៈពេលប៉ុណ្ណោះ រួចវាទៅបាត់ហើយ ប៉ុន្តែវានៅទីនោះ២នាទីជាងផង។

67 ល្អ ខ្ញុំចាប់ផ្ដើមតម្រង់រកផ្លូវម្ដងទៀត។ ហើយខ្ញុំបែរមកមើលវាម្ដងទៀត។ បន្ទាប់មកវាបានធ្វើឡើង ជាសម្លេងមនុស្សដូចសម្លេងស្រដៀងខ្ញុំដែរ និយាយថា "កុំអោយអ្នកផឹកស្រា ជក់បារី ឬបង្ខូចរាងកាយរបស់អ្នកក្នុងរបៀបណាក៏ដោយ។ នឹងមានការងារអោយអ្នកធ្វើពេលអ្នកចាស់ទៅ។" ហេតុអ្វី វាដូចជាបន្លាចខ្ញុំស្ទើរតែស្លាប់! អ្នកមិនអាចស្រមៃឃើញទេថា ក្មេងតូចខ្លាចយ៉ាងណា។ ខ្ញុំទម្លាក់ធុងតូចនោះ ហើយប្រឹងតម្រង់ទៅផ្ទះតាមតែអាចធ្វើទៅបាន ហើយស្រែកអស់សម្លេងតែម្ដង។

68 ហើយមានពស់ពិសម្យ៉ាងនៅតំបន់ជនបទ នោះពស់ហើយវាមានពិសខ្លាំងណាស់។ អ្នកម៉ែគិតថា ដោយរត់ចេញពីសួនចំការមក ប្រហែលជាជើងខ្ញុំមានពស់ពិសផងហើយគាត់រត់មកជួបខ្ញុំ។ ហើយខ្ញុំលោតទៅរកដៃរបស់គាត់ អោបគាត់ ថើបគាត់។ រួចគាត់និយាយថា "មានរឿងអ្វី តើពស់ចឹកកូនឬ?" ពិនិត្យខ្ញុំគ្រប់កន្លែង។

ខ្ញុំនិយាយ "ទេ ម៉ែ! មានមនុស្សនៅដើមឈើនោះ។"

69 ហើយគាត់និយាយ "អូ ប៊ីលលី ប៊ីលលី! មិនអីទេ?" រួចគាត់និយាយ "តើអ្នកឈប់ ហើយទៅដេកឬ?"

70 ខ្ញុំនិយាយ "ទេ ម៉ែ! មានមនុស្សនៅដើមឈើនោះ ហើយគាត់មិនអោយខ្ញុំផឹកស្រានិងជក់បារី។"

71 "ផឹកស្រាវីស្គី និង—និងអ្វីផ្សេង។" ខ្ញុំកំពុងតែយួទឹកទៅប្រដាប់បិទស្រារាងលោកខែ មិនចឹង។ ហើយគាត់និយាយ "កុំអោយអ្នកផឹកស្រានិងបង្ខូចខ្លួនដោយរបៀបណាក៏ដោយ។" វាជារឿងអសីលធម៌ អ្នកដឹងទេ ហើយភាពវ័យក្មេងរបស់ខ្ញុំ... ភាពក្មេងកម្លោះជាមួយស្ត្រី។ ហើយដោយភាពល្អបំផុតរបស់ខ្ញុំ ខ្ញុំមិនដែលធ្វើ ខុសរឿងទាំងនោះម្តងសោះឡើយ។ ព្រះអម្ចាស់បានជួយខ្ញុំចំពោះរឿងនេះហើយដោយមានខ្ញុំយល់ព្រមផង អ្នកដឹងថាពិតជាអាច។ ដូច្នេះ "កុំផឹក កុំជក់បារី ឬក៏បង្ខូចខ្លួនអ្នកព្រោះ និង មានការងារសម្រាប់អ្នកធ្វើនៅពេលអ្នកមានវ័យចំណាស់។"

72 ល្អ ខ្ញុំប្រាប់រឿងនោះទៅអ្នកម៉ែ និង—និងគាត់បានត្រឹមតែសើចខ្ញុំប៉ុណ្ណោះ។ ហើយខ្ញុំបានត្រឹមតែរំជួលចិត្ត។ គាត់ហៅពេទ្យមក ហើយពេទ្យនិយាយថា "ល្អ គាត់គ្រាន់តែភ័យ តែប៉ុណ្ណឹង។" រួចគាត់បានដាក់ខ្ញុំអោយដេក។ ហើយចាប់ពីថ្ងៃនោះមក ខ្ញុំមិនដែលដើរកាត់ក្បែរដើមឈើនោះទៀតឡើយ។ ខ្ញុំខ្លាចហើយ។ ខ្ញុំចេញទៅតាមផ្លូវមួយទៀតព្រោះខ្ញុំគិតថា មានមនុស្សនៅ លើដើមឈើនោះហើយគាត់និយាយជាមួយខ្ញុំដោយសម្លេងដែលធ្ងន់។

73 ហើយប្រហែលជាមួយខែកន្លងពីនោះមក ខ្ញុំកំពុងតែលេងថ្មម៉ាបជាមួយប្អូនប្រុសតូចរបស់ខ្ញុំ នៅពីមុខចំការ។ ហើយខ្ញុំចាប់កើតមានអារម្មណ៍ចម្លែក។ រួចខ្ញុំក៏ឈប់សម្រាកនៅក្បែរដើមឈើមួយ។ ហើយយើងក៏បានចេញទៅឆ្នេរទន្លេអូហៃយ៉ូ។ ហើយខ្ញុំមើលមកជេហ្វឺសាន់វីល ហើយខ្ញុំឃើញស្ពានមួយលេចឡើង ហើយឆ្លងកាត់ទីនោះ កាត់ទន្លេ ទទឹងទន្លេ។ ហើយខ្ញុំឃើញមនុស្ស១៦នាក់(ខ្ញុំអាចរាប់ពួកគេ) ធ្លាក់ចុះពីទីនោះ ហើយបាត់បង់ជីវិតរបស់ពួកគេនៅលើស្ពាននោះ។ ខ្ញុំរត់ យ៉ាងលឿនហើយប្រាប់អ្នកម៉ែ ហើយគាត់គិតថាខ្ញុំដេកលក់ប៉ុណ្ណោះ។ ប៉ុន្តែពួកគេ បានទុកតែក្នុងចិត្ត ហើយរយៈពេល២២ឆ្នាំពីពេលនោះមក ស្ពានក្រុងបច្ចុប្បន្ន (មានមនុស្សឆ្លងកាត់ច្រើនណាស់ពេលអ្នកឆ្លងនៅទីនោះ)ឆ្លងកាត់ទន្លេនៅ កន្លែងដដែលនោះ មានមនុស្ស១៦នាក់បាត់បង់ជីវិតពេលកំពុងសាងសង់ស្ពានឆ្លងកាត់ទន្លេនោះ។

74 វាមិនដែលខុសឡើយគឺត្រូវតតខ្វោះ។ ដូចអ្នកបានឃើញនៅទីនេះក្នុងសាល ប្រជុំ វាតែងតែកើតដោយរបៀបនោះគ្រប់ពេល។

75 ឥឡូវពួកគេគិតថាខ្ញុំ ជាមនុស្សជ្រួលច្រាល់។ ដែលខ្ញុំមនុស្សជ្រួលច្រាល់ នេះជាការពិត។ ហើយបើអ្នកកត់សម្គាល់ មនុស្សដែល—ដែលបន្ទន់ខ្លួនទៅតាម វិញ្ញាណគឺមានភាពជ្រួលច្រាល់។

76 ចូរសម្លឹងមើលកំណាព្យនិងព្យាការី ហើយចូរមើល វិល្លៀម ខៅភើ ជា អ្នកនិពន្ធចម្រៀងល្បីមួយបទ "មានប្រភពទឹកពេញដោយឈាម ដែលដងចេញពី សរសៃអ៊ីម៉ានូអែល។" អ្នកធ្លាប់ឮទេ...អ្នកស្គាល់ចម្រៀង។ ខ្ញុំឈរក្បែរផ្នូរគាត់មិន យូកន្លងទៅទេ។ បងប្រុសចូលីស ខ្ញុំជឿថាខ្ញុំមិនស្គាល់ ទេ...បាទ ត្រូវហើយនៅជា មួយ យើងនៅកន្លែងផ្នូរនោះដែរ។ ហើយ—ហើយពីនោះ បន្ទាប់ពីគាត់បានតែង ចម្រៀង កម្លាំងជម្រុញបានចេញពីគាត់ គាត់ព្យាយាមរកទន្លេ—ទន្លេ ដើម្បីសម្លាប់ ខ្លួន។ ឃើញទេ វិញ្ញាណបានចេញពីគាត់។ ហើយមនុស្សចូលចិត្តកំណាព្យ និង អ្នកនិពន្ធ...ឬ អត់...ខ្ញុំសំដៅលើព្យាការី។

77 ចូរមើលពី អេលីយ៉ាពេលគាត់ឈរលើភ្នំហើយហៅភ្លើងចុះមកពីស្ថានសួគ៌ រួចហៅភ្លៀងពីលើមេឃ។ រួចមកពេលវិញ្ញាណចេញពីគាត់ទៅ គាត់បានរត់គេច ដោយព្រោះខ្លាចស្ត្រីម្នាក់។ ហើយព្រះជាម្ចាស់បាន រកឃើញគាត់នៅក្នុងល្អាងភ្នំ រយៈ ពេល៤០ថ្ងៃក្រោយមក។

78 ចូរមើល យ៉ូណាស ជាមួយនឹងការជម្រុញគ្រប់គ្រាន់ពេលដែលព្រះជាម្ចាស់ ចាក់ប្រេងតាំងជាមួយគាត់ដើម្បីអោយគាត់ទៅអធិប្បាយនៅ នេនីវេ រហូតដល់ ក្រុង—ក្រុងមានទំហំប៉ុន សេន ឡូវីស មានការប្រែចិត្តដោយស្លៀកបាវ។ ហើយ ពេលដែលវិញ្ញាណចាកចេញពីគាត់មានរឿងអ្វីកើតឡើងចំពោះគាត់? យើងឃើញ គាត់ឡើងទៅលើភ្នំបន្ទាប់ពីវិញ្ញាណចេញពីគាត់ អធិស្ឋានទៅព្រះជាម្ចាស់អោយ យកជីវិតគាត់ទៅ។ អ្នកឃើញទេ វាជាកម្លាំងជម្រុញ។ ហើយពេលរឿងនេះ កើតឡើង វា—វាធ្វើអ្វីមួយដល់អ្នក។

79 រួចខ្ញុំចងចាំពីការធំឡើង។ ខ្ញុំធំឡើងជាបុរសក្មេងម្នាក់។(ខ្ញុំប្រញាប់និយាយ ដើម្បីរឿងតូចបន្ទាប់។) ពេលខ្ញុំធំឡើងជាបុរសក្មេងម្នាក់ ខ្ញុំមានគំនិតដូចក្មេងប្រុស ដទៃទៀតដែរ។ ខ្ញុំ...ទៅសាលា ខ្ញុំរកឃើញក្មេងស្រីៗចំនោមពួកគេ។ អ្នកដឹងទេ ខ្ញុំមានចិត្តអៀនប្រៀនណាស់ អ្នកដឹងទេ។ ហើយ ខ្ញុំ—ខ្ញុំទីបំផុតរកបានមិត្តស្រី

ម្នាក់ សម្រាប់ខ្លួន។ ខ្ញុំក៏ដូចជាក្មេងប្រុសដទៃទៀតដែរ ប្រហែលជាអាយុ១៥ឆ្នាំ ខ្ញុំ ស្មាន។ ហើយ—ហើយដូច្នេះ អូនាងស្អាតណាស់។ នាងមានភ្នែកដូចជាព្រាប ហើយនាងមានធ្មេញដូចជាគុជ ហើយមានកដូចជាក្ងាន ហើយនាង—នាងស្អាតណាស់។

80 ហើយមានក្មេងប្រុសផ្សេងទៀត គាត់...យើងជាមិត្តភ័ក្ក ដូច្នេះគាត់ក៏មានម៉ូត-ធីហ្វដ ចាស់របស់ឪពុកគាត់ ហើយយើងណាត់ជួបក្មេងស្រីៗរបស់ ពួកយើង។ ហើយយើង យើងដឹកពួកគេចេញទៅក្រៅ ជិះចេញទៅ។ យើងមាន លុយគ្រប់គ្រាន់ក្នុងការទិញសាំង២កាឡូន។ ខ្ញុំត្រូវតែជួយចាប់ផ្ដើមកង់ ក្រោយដើម្បីបញ្ឆេះវា។ ខ្ញុំមិនដឹងទេថាអ្នកចាំឬអត់ អ្នកដឹងទេ ដើម្បីបញ្ឆេះវា។ ប៉ុន្តែយើង—យើងបាន បន្ត យ៉ាងល្អ។

81 ហើយខ្ញុំមានលុយបុន្មាននីកកែលក្នុងហោប៉ៅ ហើយយើងឈប់នៅ កន្លែងតូចមួយមាន...អ្នកអាចញាំសាន់វិចសាច់ជ្រូក ដោយចំណាយតែមួយនីកកែល។ ហើយដូច្នេះ អូ ខ្ញុំជាអ្នកមាន ខ្ញុំអាចទិញដល់ទៅ៤ឯណោះ! ឃើញ? បន្ទាប់ពីយើងបរិភោគសាន់វិចហើយផឹកទឹកក្រូច។ ខ្ញុំចាប់ប្រមូលដបយកទុក។ ហើយខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ពេលខ្ញុំចេញមកក្រៅ(ស្ត្រីបានធ្លាក់ចុះពីសេចក្ដីល្អពីពេលនោះមក ឬចេញពីភាពជាស្ត្រី) ព្រាបតូចរបស់ខ្ញុំកំពុងជក់បារី។

82 ល្អ ខ្ញុំតែងមានគំនិតរបស់ខ្ញុំពីស្ត្រីដែលជក់បារី ហើយខ្ញុំមិនដែលប្ដូគំនិត នេះសូម្បីបន្តិចសោះឡើយពីពេលនោះមក។នោះគឺអញ្ចឹង។ នាងបានធ្វើ ធ្វើអ្វីដែលជាភាពថោកទាបបំផុត។ ហើយនោះត្រឹមត្រូវណាស់។ ហើយខ្ញុំ—ខ្ញុំគិត...ឥឡូវក្រុមហ៊ុនបារីអាចដេញតាមខ្ញុំពីរឿងនេះ ប៉ុន្តែប្រាប់អ្នកថាវាជាការធ្វើអោយវង្វេងរបស់អារក្ខ។ វាជាការសម្លាប់ដ៏ធំនិងជាការបំផ្លាញរបស់ជាតិសាសន៍ដែលមាន។ ខ្ញុំចង់អោយកូនប្រុសខ្ញុំផឹកស្រវឹងជៀសជាងអោយគាត់ក្លាយជាអ្នកជក់បារី។ នេះជាការពិត។ ខ្ញុំចង់អោយប្រពន្ធខ្ញុំដេកលើកម្រាលស្រវឹងស្រា ជៀសជាងឃើញនាងជក់បារី។ នោះជារបៀប...

83 ឥឡូវវិញ្ញាណរបស់ព្រះដែលគង់នៅជាមួយខ្ញុំ នោះជាវិញ្ញាណរបស់ព្រះមែនទេ(អ្នកអាចមានចម្ងល់) អ្នកជក់បារីអាចមានរាងសង្ហានៅពេលនោះ ព្រោះវាជា...គ្រប់ពេល។ អ្នកអាចដាក់វាលើវេទិការ តើទ្រង់កាត់ទោសវាយ៉ាងណា។ វាជា រឿងអាក្រក់។ នៅអោយឆ្ងាយពីវា។ ស្ត្រីអើយ បើអ្នកមានការសោកស្ដាយ ពីរឿងជក់

នោះ សូមមេត្តា ដោយព្រះនាមព្រះយេស៊ូវ នៅអោយឆ្ងាយពីវាទៅ! វាកម្ទេចអ្នក ហើយ។ វាសម្លាប់អ្នក។ ខ្ញុំនឹង...វាមាន—វាមានមហារីកពេញមួយឡាន។

84 គ្រូពេទ្យព្យាយាមហាមអ្នក។ ហើយរបៀបណាដែលពួកគេលក់វត្ថុទាំងនោះ អោយអ្នក! បើសិនជាអ្នកទៅហាងលក់ថ្នាំហើយនិយាយថា "ទិញ...ខ្ញុំចង់ទិញ ជំងឺ មហារីកតម្លៃ៥០សេន" ហេតុអ្វីបានជាគេ បិទចោល។ ប៉ុន្តែអ្នកទិញបារី តម្លៃ៥០-សេន គឺអ្នកទិញដូចគ្នានោះហើយ។ ដុកទ័រនិយាយដូច្នេះ។ អូ នេះជា ជាតិសាសន៍ ឆ្កួតនឹងលុយ។ វាអាក្រក់ពេកណាស់។ វាជាអ្នកសម្លាប់។ វាអាច បង្ហាញ បាន។

85 ល្អ ពេលខ្ញុំឃើញក្មេងស្រីតូចស្អាតប្រទាំងសម្តែងចេញដោយវ័យឆ្លាត ដោយមានបារីនៅនឹងដៃនាង វាដូចជាការសម្លាប់ខ្ញុំអញ្ចឹង ព្រោះខ្ញុំគិតថាខ្ញុំ ស្រឡាញ់ នាង។ ហើយខ្ញុំគិត "ល្អ..."

86 ឥឡូវ ខ្ញុំត្រូវបានហៅថា "ជាអ្នកស្អប់ស្រី" អ្នកដឹងទេដោយព្រោះខ្ញុំ តែងតែ ប្រឆាំងជាមួយស្ត្រីប៉ុន្តែមិនមែនប្រឆាំងនឹងអ្នកទេបងប្អូនស្រីៗ។ ខ្ញុំគ្រាន់តែ ប្រឆាំង ពីអ្វីដែលស្ត្រីសម័យសម្តែងចេញ។ នោះត្រូវណាស់។ ស្ត្រីល្អគួរតែត្រូវបានយក ចេញ។

87 តែ ខ្ញុំនៅចាំថាពេលធុងបិតស្រាឪពុកខ្ញុំនៅដំណើរការនៅឡើយ ខ្ញុំត្រូវ ចេញ ទៅទីនោះជាមួយនឹងទឹកនិងសំភារៈ ឃើញស្ត្រីក្មេងៗដែលមិនមានអាយុ លើស ពី១៧ឆ្នាំផងទៅទីនោះជាមួយបុរសអាយុស្របាលខ្ញុំ បច្ចុប្បន្ននេះហើយផឹកស្រា។ ហើយពួកគេត្រូវតែធ្វើមិនអោយស្រវឹង ហើយពួកគេអោយកាហ្វេខ្មៅទៅពួកគាត់ ត្រឡប់ទៅផ្ទះវិញដើម្បីចំអិនអាហារពេលល្ងាចអោយប្តី។ អូ អ្វីដែលអញ្ចឹង ខ្ញុំ និយាយ "ខ្ញុំ..." នេះជាការគូសសម្គាល់ដូច្នេះ "ពួកនាងមិនមានតម្លៃអោយ សក្តិ សមនឹងស្លាប់ជាមួយគ្រាប់កាំភ្លើងស្អាតផង។" នេះត្រូវណាស់។ ហើយខ្ញុំ ស្អប់ ស្រី ៗ។ នោះត្រូវណាស់។ ឥឡូវខ្ញុំត្រូវសម្លឹងមើលគ្រប់កិរិយា ដើម្បីកុំអោយ គិតនៅ តែ ដូចមុន។

88 ដូច្នេះ ប៉ុន្តែឥឡូវ ស្ត្រីល្អជាគ្រឿងអលង្ការលើមុដបុរស។ នាងត្រូវបាន តម្កើង ឡើង។ នាងជា...ម្តាយខ្ញុំ ជាប្រពន្ធខ្ញុំ ហើយពួកគេគួរអោយស្រឡាញ់។ ហើយខ្ញុំ មានបងប្អូនស្រីគ្រីស្ទានរាប់ពាន់នាក់ដែលគួរជាទីគោរពខ្ពង់ខ្ពស់។ ប៉ុន្តែបើ សិន —បើសិនពួកគេគោរពតាមអ្វីដែលព្រះជាម្ចាស់បានបង្កើតគេមក ភាពជាម្តាយ និង

ម្ចាស់ក្សត្រីយ៍ពិតៗ នោះគឺមិនជាអ្វីឡើយ។ នាងជាអ្វីមួយដែលល្អបំផុតដែលព្រះបានប្រទានអោយមនុស្សប្រុស ជាប្រពន្ធ។ ក្រៅពីសេចក្តីសង្គ្រោះប្រពន្ធជារបស់ល្អបំផុតបើសិនជានាងជាប្រពន្ធល្អ។ ប៉ុន្តែបើនាងមិនមែនល្អទេសាឡូម៉ូននិយាយថា "ស្ត្រីល្អជាអល្ល័ង្កាលើមកុដប្តី ប៉ុន្តែ ស្រីជា—កំណាចឬមិន-ល្អគឺ ជាទឹកក្នុងឈាមប្តីវិញ។" ហើយនោះជាការពិត វាជារឿងអាក្រក់ដែលអាចកើតមាន។ ដូច្នេះស្ត្រីល្អ...បើអ្នកមានប្រពន្ធល្អ បងប្អូន ប្រុសៗ គួរតែគោរពនាងដោយខ្ពស់បំផុត។ នោះត្រូវណាស់អ្នកគួរតែធ្វើដូច្នោះ។ ស្ត្រីពិត! និងកូនៗ បើអ្នកមានម្តាយពិត ដែលស្នាក់នៅក្នុងផ្ទះ ហើយប្រឹងប្រែង មើលថែអ្នក រក្សាសម្លៀកបំពាក់អ្នកអោយស្អាត ជូនអ្នកទៅសាលា ប្រាប់អ្នកពីព្រះយេស៊ូវអ្នកត្រូវគោរពម្តាយដែលផ្អែមល្ហែមនេះអោយអស់ពីក្នុងខ្លួនអ្នក។ អ្នក គួរតែគោរពស្ត្រីបែបនោះ បាទ លោក ព្រោះគាត់ជាម្តាយពិត។

89 ពួកគេនិយាយពីអនក្ខរកម្មនៃភ្នំកេនតាក់គី។ បងប្អូនឃើញទេនេះជាអ្វីនៅដកផាច(dogpatch)។ មានម្តាយខ្លះដែលនៅទីនោះជាម្តាយចាស់ៗ មិនអាចមក ទីនេះ ដើម្បីចូលហូលីវូដហើយបង្រៀនអ្នកពីរបៀបធ្វើជា ម្តាយទំនើប ដែលចិញ្ចឹមកូននោះទេ។ អ្នកព្រមអោយកូនមកមួយយប់ជាមួយសក់បាស់ឡើង និងបបូរមាត់...រអិល(អ្នកហៅថាយ៉ាងម៉េច?)សម្ភារៈតុបតែងផាត់លើមុខ ហើយខោអាវ ទាញទៅម្ខាង ហើយចេញទៅក្រៅរាល់យប់ ផឹកស្រា រាប់អាន នាងបញ្ចេញភ្លៅម្ខាងមកក្រៅ ចំកំពូលចុងដើមឈើហាក់ខឺរី ហើយនាងមិនចេញទៅក្រៅទៀត។ ខ្ញុំប្រាប់អ្នក នាងគួរ...ហើយបើសិនអ្នកបន្តបន្តិចទៀត អ្នកនឹងមានពួកហូលីវូដ នៅទីនេះ ល្អជាង ហើយ មានជាតិសាសន៍មួយល្អឡើង។ នោះជាការត្រឹមត្រូវ។ នោះជាការពិត។ "ចូរព្យាយាមធ្វើជាគំរូ" នោះជា—នោះជាអន្ទាក់មួយរបស់អារក្ខ។

90 ឥឡូវ ក្មេងស្រីតូចនេះ ពេលខ្ញុំមើលទៅនាង បេះដូងរបស់ខ្ញុំហូរចេញ ឈាម។ ហើយខ្ញុំគិត "សហមិត្តជាទីអាណិត។"

ហើយនាងនិយាយ "អូ អ្នកចង់បានបារីទេ ប៊ីលលី?"

ខ្ញុំនិយាយ "ទេ។" ខ្ញុំនិយាយ "ខ្ញុំមិនជក់បារីឡើយ។"

91 នាងនិយាយ "ឥឡូវអ្នកនិយាយថាអ្នកមិនរាំ។" ពួកគេចង់ចេញទៅរាំតែ ខ្ញុំមិនបានទៅឡើយ។ ដូច្នេះពួកគេនិយាយថាពួកគេរាំនៅទីនោះ គេហៅទីនោះថា ស៊ីុខេមម៉័រ ហ្គាដិន។

ហើយខ្ញុំនិយាយ "ទេ ខ្ញុំមិនរាំទេ។"

92 នាងនិយាយ "ឥឡូវអ្នកមិនរាំ អ្នកមិនជក់ អ្នកមិនផឹកស្រា។ តើអ្នកអាចសប្បាយម្តេចកើត?"

93 ខ្ញុំនិយាយ "ល្អ ខ្ញុំចូលចិត្តស្ទូចត្រី និងចូលចិត្តបរបាញ់។" នោះមិនបានធ្វើអោយនាងចាប់អារម្មណ៍ ឡើយ។

ដូច្នេះនាងនិយាយ "ជក់បារីទៅ។"

ខ្ញុំនិយាយ "ទេ អរគុណ។ ខ្ញុំមិនជក់បារីទេ។"

94 ខ្ញុំកំពុងតែឈរនៅក្នុងខែល។ ពួកគេមានក្តារនៅលើហ្វដចាស់ អ្នកចាំទេហើយ ខ្ញុំឈរនៅទីនោះជាខែល អង្គុយនៅកៅអីក្រោយ នាងនិងខ្ញុំ។ ហើយនាងនិយាយថា "អ្នកមានន័យថាអ្នកមិនជក់បារី?" និយាយ "ហើយយើងជាស្រីមានភាពជ្រួលច្រាល់ជាងអ្នកឬ។"

ខ្ញុំនិយាយ "ទេ ខ្ញុំមិនជឿថាខ្ញុំចង់ជក់នោះទេ។"

95 នាងនិយាយ "ហេតុអ្វី អ្នកកំសាកខ្លាំងណាស់!" អូ ខ្ញុំអើយ! ខ្ញុំចង់ក្លាយជាប៊ីលធំ អាក្រក់ ដូច្នេះ ខ្ញុំ—ខ្ញុំ មិនចង់បានអ្វីជាភាពកំសាកនោះទេ។ ឃើញទេខ្ញុំ ចង់ក្លាយជាអ្នកប្រដាល់យករង្វាន់ នោះជាគំនិតពីជីវិតរបស់ខ្ញុំ។ ដូច្នេះខ្ញុំនិយាយ..."កំសាក! កំសាក!"

96 ខ្ញុំមិនអាចនៅជាជំហរបែបនោះឡើយ ដូច្នេះខ្ញុំនិយាយ "អោយវាមកខ្ញុំ!" ដៃខ្ញុំលាចេញ ខ្ញុំនិយាយ "ខ្ញុំនឹងបង្ហាញនាងថាខ្ញុំកំសាកឬអត់។" ទាញយកបារីនោះ ចេញហើយចាប់គូសឈើគូស។ ឥឡូវខ្ញុំដឹងថាអ្នក...ឥឡូវ ខ្ញុំមិនមានទំនួលខុសត្រូវតាមអ្វីដែលអ្នកគិតនោះទេ ខ្ញុំទទួលខុសត្រូវលើអ្វីដែលខ្ញុំប្រាប់ពីសេចក្តីពិត។ ពេលខ្ញុំចាប់ផ្តើមគូសបារីនោះ ខ្ញុំតាំងចិត្តថានឹងជក់ដូចជាតាំងចិត្តកាន់ព្រះគម្ពីរនេះ អញ្ចឹង ឃើញទេ ខ្ញុំបានឮសម្លេងកើតឡើង "វ៉ូសៗៗៗៗ!" ខ្ញុំព្យាយាមម្តងទៀត ខ្ញុំមិនអាចដាក់វាក្នុងមាត់សោះ។ ហើយខ្ញុំក៏យំ ខ្ញុំបោះវត្ថុនេះចោល។ ពួកគេសើច ចំអកខ្ញុំ។ ហើយខ្ញុំដើរមកផ្ទះ ឡើងទៅចំការ អង្គុយនៅទីនោះ យំ។ ហើយ—ហើយវាជាជីវិតមួយធុញថប់។

97 ចងចាំថាមានពេលមួយលោកពុកចុះទៅទន្លេជាមួយក្មេងប្រុសៗ។ ប្អូនប្រុសខ្ញុំនិងខ្ញុំ យើងត្រូវជិះទូកហើយចេញទៅទន្លេ ដបប្រមាញ់ត្រូវដាក់វីស្គី ក្នុងនោះ។

យើងមានមួយឡូតែ១នីកកែល ហើយយកវាទៅតាមទន្លេ។ ហើយពុក នៅជាមួយខ្ញុំ ហើយខ្ញុំមានបន្ទះសំប៉ែតនោះ...ខ្ញុំជឿថាវាមានចំនុះកន្លះលីត្រ។ ហើយមានដើមឈើមួយខ្យល់បក់ទ្រេត លោកពុក...និងបុរសម្នាក់នៅជាមួយគាត់ គឺលោកដនប៊ុស។ ខ្ញុំមានរបស់គាត់...គាត់មានទូកស្អាតមួយ ខ្ញុំចង់បានមុខមាត់ ចំពោះគាត់ព្រោះខ្ញុំចង់ប្រើទូកនោះ។ ទូកនោះមានចង្កូត តែទូកខ្ញុំមិនមានឡើយ។ យើងមានទូកចាស់ចេះតែចែវទៅ។ ហើយបើគាត់អនុញ្ញាតិអោយខ្ញុំប្រើទូក នោះ....ដូច្នេះគាត់បានផ្សានិងធ្វើប្រដាប់បិតស្រាអោយលោកពុក។ ដូច្នេះគាត់...ពួកគេ ទម្លាក់ជើងលើដើមឈើនោះ ហើយលោកពុកលូកហោប៉ៅក្រោយរបស់គាត់ ហើយទាញយកដបសំប៉ែតស្រាវីស្គីតូចចេញ ហុចទៅអោយគាត់ ហើយគាត់ផឹកបន្តិច ហើយហុចទៅអោយពុកវិញ ហើយពុកក៏ផឹកដែរ ហើយគាត់អង្គុយលើ ខ្នែងឈើនៅម្ខាងដើមឈើដែលលៀនចេញមក។ ហើយលោក ដនប៊ុសចាប់លើក វាឡើង និយាយ "នេះរបស់អ្នក ប៊ីលលី។"

ខ្ញុំនិយាយ "អរគុណ ខ្ញុំមិនផឹកស្រាទេ។"

98 គាត់និយាយ "ប្រាណហាំហើយមិនផឹកស្រាទេ?" គ្រប់គ្នាសុទ្ធតែស្លាប់នៅលើស្បែកជើងនោះ នៅក្បែរ។ រួចគាត់និយាយ "ប្រាណហាំហើយមិនផឹកស្រាទេ?"

ខ្ញុំនិយាយ "ទេលោក។"

"ទេ" លោកពុកនិយាយ "ខ្ញុំចិញ្ចឹម អ្នកកំសាកមួយហើយ។"

99 ឳពុករបស់ខ្ញុំហៅខ្ញុំថាកំសាក! ខ្ញុំនិយាយ "ហុចដបមួយមកអោយខ្ញុំ!" ហើយខ្ញុំទាញឆ្នុកចេញកំណត់ក្នុងចិត្តថានឹងផឹកហើយពេលខ្ញុំលើកវាឡើង "វ៉ូសៗៗៗ!" ខ្ញុំចាប់លើកដប ហើយទម្លាក់ទៅលើវាលយ៉ាងខ្លាំងអស់ពីកម្លាំងអាច ធ្វើទៅបានរួចយំ។ មានអ្វីមួយមិនអោយខ្ញុំធ្វើឡើយ។ ឃើញទេ? ខ្ញុំមិននិយាយ ថា ខ្ញុំមានអ្វីល្អឡើយ (ខ្ញុំគិតថាធ្វើវា) ប៉ុន្តែព្រះជាម្ចាស់ព្រះគុណ ព្រះគុណអស្ចារ្យ ដែលរក្សាខ្ញុំមិនអោយធ្វើការនោះ។ ខ្ញុំចង់ធ្វើវាដោយខ្លួនឯង ប៉ុន្តែទ្រង់មិនអនុញ្ញាតអោយខ្ញុំធ្វើឡើយ។

100 ក្រោយមកខ្ញុំរកបានមិត្តស្រីម្នាក់ពេលខ្ញុំមានអាយុ២២ឆ្នាំ នាងជាទីស្រឡាញ់របស់ខ្ញុំ។ នាងជាក្មេងស្រីដែលទៅព្រះវិហារអាឡឺម៉ង់ លូធឺរៀន។ ឈ្មោះរបស់នាង គឺ ប្រាំបាឆ ប្រាំ—បា—ឆ មកពីឈ្មោះប្រាំបត។ ហើយនាងជាក្មេងស្រីដែលល្អ។

នាងមិនជក់បារី មិនផឹកស្រា ឬ—ឬមិនរាំឬអ្វីផ្សេងទៀតជាស្រីល្អ។ ខ្ញុំបានចេញទៅក្រៅជាមួយនាងមួយរយៈ ហើយខ្ញុំ...ដូច្នោះ ប្រហែលអាយុម្ភៃ-ពីរឆ្នាំ ខ្ញុំអាចរកលុយបានខ្លះរហូតដល់ខ្ញុំអាចទិញ ហ្វដចាស់មួយ ហើយ ខ្ញុំ...យើងចេញទៅក្រៅណាត់ជួបគ្នា។ ហើយនៅពេលនោះ ព្រះវិហារ លូធីរៀន មិនទាន់បិទទេ ពួកគេ ប្តូរពីហារ៉េដផាក ទៅទីនោះ។

101 ដូច្នេះពួកគេ...អ្នកដឹកនាំម្នាក់ដែលបំបួសខ្ញុំជាបេសកជន វិហារបាបទីស្ទ ដុកទ័រ រ៉យដេវីស។ បងស្រី អាប់ស ជាម្នាក់ដែលបញ្ជូនបងប្រុស អាប់ស មកអោយខ្ញុំ ឬនិយាយទៅកាន់គាត់អំពីខ្ញុំ ដុកទ័ររ៉យដេវីស។ ដូច្នេះគាត់ក៏ អធិប្បាយហើយមានព្រះវិហារបាបទីស្ទដំបូង ឬជា—ជា...ខ្ញុំមិនជឿថា វាជាព្រះវិហារ បាបទីស្ទ ដំបូងដែរ វាជាបេសកកម្ម-...ហៅថាបេសកកម្ម ព្រះវិហារបាបទីស្ទ នៅជេហ្វឺសាន់វីល។ ហើយគាត់អធិប្បាយនៅទីនោះនៅពេលនោះឯង ហើយយើងទៅវិហារ ពេលយប់ ដូច្នេះ...យើងមកវិញ។ ហើយខ្ញុំមិនដែលបានចូលព្រះវិហារ ប៉ុន្តែ ខ្ញុំចូលចិត្តទៅជាមួយនាង។ ព្រោះគំនិតធំគឺ "ទៅជាមួយនាង" ខ្ញុំសូមនិយាយដោយស្មោះត្រង់។

102 ដូច្នេះទៅជាមួយនាងនៅថ្ងៃមួយ ខ្ញុំ...នាងចេញមកពីគ្រួសារល្អមួយ។ ហើយខ្ញុំចាប់ផ្តើមគិត "អ្នកដឹងទេ អ្នកដឹងទេ ខ្ញុំមិនគួរចំណាយពេលក្មេងស្រីនោះច្រើនពេកទេ។ វាមិនអញ្ជឹង—វាមិនត្រូវអញ្ជឹង ព្រោះនាងជាក្មេងស្រីល្អ ហើយខ្ញុំជាអ្នកក្រហើយ—ហើយខ្ញុំ..." ឪពុកខ្ញុំមានសុខភាពមិនល្អហើយខ្ញុំ—ខ្ញុំ...គ្មានផ្លូវណាអោយខ្ញុំ រកស៊ីចិញ្ចឹមក្មេងស្រីបែបនោះទៀយ ជាអ្នកដែលធ្លាប់រស់នៅផ្ទះស្អាត និងមានកម្រាលព្រំ។

103 ខ្ញុំចាំបានពីកម្រាលព្រំខ្ញុំឃើញដំបូង ខ្ញុំមិនស្គាល់ថាវាជាអ្វីទៀយ។ ខ្ញុំដើរជុំវិញ។ ខ្ញុំគិតថាវាជាវត្ថុល្អមួយដែលខ្ញុំមិនធ្លាប់ឃើញក្នុងជីវិត។ "តើគេអាចដាក់អ្វីបែបនេះលើកម្រាលឥដ្ឋយ៉ាងម៉េច?" វាជាកម្រាលព្រំដំបូងដែលខ្ញុំបានឃើញ។ វាជា—វាជាមួយក្នុងចំនោមនោះ...ខ្ញុំជឿថាវាត្រូវបានគេហៅថា "កន្ទេលព្រំ" ខ្ញុំអាច ថាខុស។ ជាអ្វីដែលដូចជា "បន្ទះត្បាញ" ឬជាអ្វីដែលចងជាមួយគ្នា ហើយដាក់លើកម្រាលឥដ្ឋ។ មានពណ៌បៃតងក្រហមស្អាត និងមានផ្កាកូឡាបដាក់នៅចំកណ្តាលវា អ្នកដឹងទេ។ វាជាវត្ថុស្អាតណាស់។

104 ហើយខ្ញុំក៏ចាំដែរថាខ្ញុំ—ខ្ញុំរៀបចំគំនិតទាំងខ្ញុំនឹងសុំនាងរៀបការជាមួយខ្ញុំ ឬខ្ញុំត្រូវនៅអោយឆ្ងាយ ទុកអោយបុរសផ្សេងទៀតរៀបការជាមួយនាង ជានរណាម្នាក់ដែលល្អសម្រាប់នាង អាចចិញ្ចឹមនាង ហើយចិត្តល្អជាមួយនាង។ ខ្ញុំអាចមានចិត្តល្អចំពោះនាងតែខ្ញុំ—ខ្ញុំ—ខ្ញុំ រកបានតែ២០សេនក្នុងមួយម៉ោងប៉ុណ្ណោះ។ ដូច្នេះខ្ញុំមិន អាចរកកម្រៃបានច្រើន ក្នុងការចិញ្ចឹមនាងឡើយ។ ហើយខ្ញុំ...ជាមួយនឹងគ្រួសារ ទាំងអស់ដែលយើងត្រូវមើលថែ ហើយលោកពុកគាត់មានសុខភាពទ្រុឌទ្រោម ខ្ញុំ ត្រូវមើលថែពួកគេទាំងអស់គ្នា ដូច្នេះខ្ញុំមានពេលវេលាមួយដ៏តានតឹង។

105 ដូច្នេះខ្ញុំគិត "ល្អដូច្នេះ រឿងមួយដែលខ្ញុំអាចធ្វើបានគឺប្រាប់នាងថាខ្ញុំ—ខ្ញុំ...នាង...ខ្ញុំ—ខ្ញុំនឹងមិនត្រឡប់មកវិញ ព្រោះខ្ញុំគិតច្រើនពេកពីនាងលើការបំផ្លាញជីវិតនាងនិងទុកអោយភាពលីលារបស់នាងដែលទៅតាមខ្ញុំ។" រួចខ្ញុំគិតថា "បើសិនមាននរណាម្នាក់អាចកាន់ដៃនាង និងរៀបការជាមួយនាង បង្កើតគ្រួសារដែលពេញដោយក្ដីស្រឡាញ់។ ហើយបើខ្ញុំមិនបាននាង ខ្ញុំអាច—ខ្ញុំអាចក៏ដឹងថានាងសប្បាយចិត្ត។"

106 ហើយដូច្នេះខ្ញុំគិត "ប៉ុន្តែខ្ញុំ—ខ្ញុំ ត្រឹមជា—ខ្ញុំមិនអាចបោះបង់នាងបាន ឡើយ!" ហើយខ្ញុំ—ខ្ញុំនៅក្នុងលក្ខណៈអាក្រក់មួយ។ ហើយពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំគិតពីវា។ ដូច្នេះខ្ញុំមួរមុខក្នុងការដែលសុំនាងរៀបការជាមួយខ្ញុំ។ រៀងរាល់យប់ ខ្ញុំរៀបចំគំនិត "ខ្ញុំនឹងសុំនាង។" ហើយ ពេលខ្ញុំ ហះ នោះគឺជាអ្វី មេអំបៅឬអ្វីដែលអ្នកមាននៅក្នុងរបស់អ្នក...? ហើយបងប្អូនដែលនោះទីនោះ ប្រហែលមានបទពិសោធន៍ដូចគ្នាដែរ។ ហើយជារឿងអស់សំណើចណាស់ មុខខ្ញុំបានឡើងកំដៅ។ ខ្ញុំ—ខ្ញុំមិនដឹងថា។ ខ្ញុំមិនអាចសួរនាងទេ។

107 ដូច្នេះអ្នកអាចឆ្ងល់ថា ខ្ញុំអាចរៀបការយ៉ាងណា។ អ្នកដឹងថាជាអ្វី? ខ្ញុំសរសេរសំបុត្រអោយនាងដើម្បីសុំនាង។ ហើយដូច្នេះនាង...ឥឡូវ វាមិនមែនជា "កញ្ញាស្អាតបំផុត" វាលើសជាងនោះបន្តិច (អ្នកដឹងហើយ) នៅខាងសេចក្ដីស្រឡាញ់ជៀសជាងនោះ។ វាគ្រាន់តែ—តែជាការយល់ព្រមប៉ុណ្ណោះ វាគឺ...ខ្ញុំ—ខ្ញុំសរសេរសំបុត្រមួយឡើងល្អបំផុតដែលខ្ញុំអាចធ្វើបាន។

108 ហើយខ្ញុំខ្លាចម្ដាយរបស់នាងបន្តិច។ ម្ដាយរបស់នាងគឺជា...គាត់ជាអ្នកតឹងតែង។ ប៉ុន្តែឪពុករបស់នាងជាបុរសជនជាតិអាឡឺម៉ង់ សុភាពមានវ័យ

ចំណាស់ ជាសហមិត្តដែលល្អ។ គាត់ជាអ្នកដែលរៀបចំនៃភាពជាបងប្អូន ជាមនុស្សធ្វើការ នៅរថភ្លើងនៅតាមផ្លូវរថភ្លើង រកចំនូលបាន៥០០ដុល្លាក្នុងមួយខែនាសម័យ នោះ។ ហើយ ខ្ញុំរកលុយបាន២០សេនក្នុងមួយម៉ោង ដើម្បីរៀបការជាមួយកូនស្រីរបស់គាត់។ អូ! ខ្ញុំដឹងថាតាមរបៀបនេះមិនងាយដំណើរការ។ ហើយម្តាយរបស់ នាងពិតជា...ឥឡូវ នាងជាស្រីស្អាតម្នាក់។ នាង—នាងមានលក្ខណៈជាម្នាក់នៃ សង្គមខ្ពង់ខ្ពស់នេះ អ្នកដឹងទេពិបាកផ្គាប់ចិត្ត អ្នកដឹងហើយ ដូច្នេះខ្ញុំដូចជា មិនមាន ប្រយោជន៍ដល់នាងដោយរបៀបណាឡើយ។ ខ្ញុំគ្រាន់តែជាក្មេងចំការម្នាក់ ហើយនាងគិតថា ហូប គួរតែត្រូវទៅរស់នៅជាមួយក្មេងប្រុសកម្លោះដែលមានឋានៈខ្ពស់ជាងនេះបន្តិច ហើយខ្ញុំ—ខ្ញុំ—ខ្ញុំគិតថានាងត្រូវតែដូច្នេះ។ ហើយដូច្នេះ...ប៉ុន្តែខ្ញុំ—ខ្ញុំមិនបានគិតទៀតឡើយ។

109 ដូច្នេះខ្ញុំគិតថា "ល្អ ឥឡូវ ខ្ញុំមិនដឹងថាជាយ៉ាងណាទេ។ ខ្ញុំ—ខ្ញុំមិនអាចសួរ ឪពុកនាង ហើយខ្ញុំ—ខ្ញុំពិតជាមិនសួរម្តាយនាងជាប្រាកដ។ ដូច្នេះខ្ញុំត្រូវតែសួរ នាងជាមុនសិន។" ដូច្នេះខ្ញុំសរសេរសំបុត្រដោយខ្លួនឯងមួយច្បាប់។ ហើយនៅព្រឹកនោះ ពេលទៅធ្វើការខ្ញុំបានទម្លាក់វានៅក្នុងប្រអប់សំបុត្រ។ សារ...យើងបាន ទៅ ព្រះវិហារនៅយប់ថ្ងៃពុធ ហើយនៅថ្ងៃនោះជាព្រឹកថ្ងៃច័ន្ទ។ ខ្ញុំព្យាយាមពេញ មួយថ្ងៃអាទិត្យដើម្បីប្រាប់នាងថាខ្ញុំចង់រៀបការជាមួយនាង ប៉ុន្តែខ្ញុំមិនអាចងើបរួច ដោយចិត្តក្លាហាន។

110 ដូច្នេះខ្ញុំទម្លាក់វាក្នុងប្រអប់សំបុត្រ។ ហើយនៅកន្លែងធ្វើការថ្ងៃនោះ ខ្ញុំចាប់ផ្តើមគិត "ចុះបើសិនជាម្តាយរបស់នាងចាប់បានសំបុត្រនោះ?" អូ! ខ្ញុំអើយ បន្ទាប់មកខ្ញុំដឹងថាខ្ញុំរលាយហើយបើសិន—បើសិនជាគាត់ទទួលបានសំបុត្រនោះព្រោះគាត់មិនគិតយកចិត្តទុកដាក់ជាមួយខ្ញុំឡើយ។ ល្អខ្ញុំក៏បានត្រឹមបែកញើសខ្លាយ។

111 ហើយនៅយប់ថ្ងៃពុធពេលខ្ញុំមកដល់ អូ ខ្ញុំគិត "តើខ្ញុំអាចឡើងទៅទីនោះយ៉ាងម៉េច? បើសិនជាម្តាយនាងចាប់បានសំបុត្រនោះ គាត់នឹងធ្វើទុក្ខបុកម្នេញខ្ញុំហើយ ដូច្នេះខ្ញុំសង្ឃឹមថានាងទទួលសំបុត្រ។" ខ្ញុំបានដាក់បញ្ជាក់អាសយដ្ឋានទៅ "ហូប។" ដែលជាឈ្មោះរបស់នាង ហូប។ ដូច្នេះខ្ញុំនិយាយ "ខ្ញុំនឹងសរសេរនៅទីនេះថាអោយទៅហូប។" ហើយ វាដូច្នេះ...ហើយខ្ញុំគិតថានាងមិនទទួលបានសំបុត្រនោះទេ។

112 ដូច្នេះ ខ្ញុំដឹងថាជាការល្អដែលខ្ញុំឈប់នៅ ខាងក្រៅហើយផ្លុំស៊ីផ្លេអោយនាងចេញមក។ អូ! ខ្ញុំអើយ ហើយមានក្មេងប្រុសណាមិនក្លាហានគ្រប់គ្រាន់ ក្នុងការដើរទៅផ្ទះ ហើយគោះទ្វានិងសុំយកក្មេងស្រី មិនមានការអ្វីត្រូវធ្វើជាមួយនាង។ នោះគឺត្រូវណាស់។ នោះពិតជាឆ្កួត។ ថោកទាប។

113 ហើយខ្ញុំឈប់ ហ្វដ ចាស់របស់ខ្ញុំ អ្នកដឹងទេ ខ្ញុំលាងវាឡើងភ្លឺ។ ហើយខ្ញុំដើរទៅគោះទ្វា។ មីស៊ី ជាម្តាយរបស់នាងបានចេញមកមាត់ទ្វា! ខ្ញុំដកដង្ហើមស្ទើរ មិន ដល់គ្នា ខ្ញុំនិយាយ "តើ—តើ—តើអ្នកសុខសប្បាយទេ លោកស្រីប្រាំបាឆ?" យេ។

114 គាត់និយាយ "តើអ្នកសុខសប្បាយទេ វិល្លៀម។"

ខ្ញុំគិត "អះ អូ 'វិល្លៀម'!"

ហើយ—ហើយគាត់និយាយ "ចូលមកក្នុងទេ?"

115 ខ្ញុំនិយាយ "អរគុណ។" ខ្ញុំឈានចូលទៅតាមទ្វា។ ខ្ញុំនិយាយ "តើហូបរួច រាល់ហើយឬនៅ?"

116 ហើយភ្លាមនោះ ហូបចេញមកដើរកាត់ល្វែងផ្ទះ ជាក្មេងស្រីអាយុ ប្រហែល ១៦ឆ្នាំ។ ហើយនាងនិយាយ "សួស្តី ប៊ីលលី!"

117 ហើយខ្ញុំនិយាយ "សួស្តី ហូប។" ហើយខ្ញុំនិយាយ "តើអ្នកត្រៀមរួចរាល់ ដើម្បីទៅព្រះវិហារហើយ?"

នាងនិយាយ "ចាំមួយភ្លែត។"

118 ខ្ញុំគិត "អូ! នាងមិនទទួលវាឡើយ។ នាងមិនទទួលបានឡើយ។ ល្អ ល្អ ល្អ។ ហូបក៏មិនទទួលបានដែរ ដូច្នេះ វាគ្មានរឿងអ្វីទេ ព្រោះនាងហៅឈ្មោះខ្ញុំ" ដូច្នេះខ្ញុំមានអារម្មណ៍ស្រួលវិញ។

119 ហើយបន្ទាប់មកពេលខ្ញុំទៅព្រះវិហារខ្ញុំបានគិត "ចុះបើនាងទទួល បានវិញ?" ឃើញទេ? ហើយខ្ញុំបានស្តាប់ឮពីដុកទ័រដេវីសនិយាយពីអ្វីទេ។ ខ្ញុំសម្លឹងមើល នាងហើយខ្ញុំគិត "ប្រហែលជានាងដកខ្លួន ហើយនាងនឹងប្រាប់អោយខ្ញុំ ចាកចេញពេលខ្ញុំចេញពីទីនេះទៅ ដោយព្រោះខ្ញុំសុំដល់នាង។" ហើយខ្ញុំមិនបានឮ ពីអ្វីដែលលោកដេវីសកំពុងនិយាយអ្វីឡើយ។ ហើយ—ហើយ ខ្ញុំបានមើលទៅគាត់ ហើយ

ខ្ញុំគិតថា "ឱខ្ញុំអើយ ខ្ញុំពិបាកបោះបង់ចោលនាងណាស់ ប៉ុន្តែ ខ្ញុំ—ខ្ញុំ...ភាពអាប់អោនពិតជាកើតមាន។"

120 ដូច្នេះបន្ទាប់ពីទៅព្រះវិហារយើង បានដើរតាមផ្លូវជាមួយគ្នា ត្រឡប់មកផ្ទះហើយ—ហើយយើងដើរឆ្ពោះទៅកាន់ ហ្វដចាស់។ ហើយពេលនោះ ព្រះច័ន្ទកំពុងតែបញ្ចេញពន្លឺភ្លឺចិញ្ចាចអ្នកដឹងទេ ខ្ញុំសម្លឹងមើល ហើយនាងពិតជាស្អាតណាស់។ ក្មេងប្រុស ខ្ញុំសម្លឹងមើលនាងហើយខ្ញុំគិត "តើខ្ញុំអាចយកនាងយ៉ាង ណា ប៉ុន្តែខ្ញុំទាយថាខ្ញុំមិនអាចឡើយ។"

121 ដូច្នេះខ្ញុំដើរបន្តទៀត អ្នកដឹងទេ ខ្ញុំសម្លឹងមើលនាងម្តងទៀត។ ខ្ញុំនិយាយ "តើ—អ្នកមានអារម្មណ៍យ៉ាងណាដែរយប់នេះ?"

នាងនិយាយ "អូ ខ្ញុំមិនអីទេ។"

122 ហើយយើងឈប់នៅ ហ្វដចាស់ ឡើងជិះហើយចេញទៅ អ្នកដឹងទេ ជុំវិញនោះ ដើរជុំវិញផ្លូវកាច់ជ្រុងនិងនៅផ្ទះរបស់នាង។ ហើយខ្ញុំដើរទៅកាន់មាត់ទ្វាជាមួយនាង។ ខ្ញុំគិត "អ្នកដឹងទេនាងប្រហែលជាមិនទទួលបានសំបុត្រទេ ដូច្នេះខ្ញុំគួរ បំភ្លេចចោលល្អជាង។ ខ្ញុំក៏អាចមានសប្តាហ៍មួយដ៏ល្អដែរយ៉ាងហោចណាស់។" ដូច្នេះខ្ញុំចាប់ផ្តើមមានអារម្មណ៍ល្អ។

នាងនិយាយ "ប៊ីលលី?"

ខ្ញុំនិយាយ "យេ។"

នាងនិយាយ "ខ្ញុំទទួលបានសំបុត្រហើយ។" អូ! ខ្ញុំអើយ

ខ្ញុំនិយាយ "អ្នកទទួល?"

123 នាងនិយាយ "អាហា។" ល្អ នាងបន្តដើរទៅមុខទៀត មិននិយាយអ្វី ទៀតឡើយ។

124 ខ្ញុំគិត "មនុស្សស្រីប្រាប់ខ្ញុំពីអ្វីមួយ។ ទុកខ្ញុំចោល ឬប្រាប់ខ្ញុំថា គិតយ៉ាងណាពីរឿងនោះ។" ហើយខ្ញុំនិយាយ "តើអ្នក—តើអ្នកអានវាទេ?"

នាងនិយាយ "អា ហា។"

125 ខ្ញុំអើយ អ្នកដឹងទេស្រីៗអាចទុកអោយអ្នកមានចិត្តសង្ស័យ។ អូ ខ្ញុំ—ខ្ញុំ មិនមានន័យតែដូច្នោះទេ អ្នកឃើញទេ។ ឃើញ? ប៉ុន្តែ ទោះជាយ៉ាងណា អ្នកដឹងទេ ខ្ញុំ

—ខ្ញុំគិត "ហេតុអ្វីបានជាអ្នកមិននិយាយ អ្វីខ្លះទៅ?" ឃើញ ហើយខ្ញុំបន្តទៅ ទៀត។ ខ្ញុំនិយាយ "តើអ្នកអានវាទាំងអស់ទេ?"

ហើយនាង...[ថេបកាសែតស្ងាត់—Ed.] "អា ហា។"

126 ដូច្នេះពេលយើងទៅជិតមាត់ទ្វា ខ្ញុំគិត "ក្មេងប្រុសអើយ កុំនាំខ្ញុំទៅកាន់ វានហាល ព្រោះខ្ញុំមិនអាចបន្តទៅមុខទៀតបាន ដូច្នេះប្រាប់ខ្ញុំឥឡូវមក។" ហើយខ្ញុំ នៅតែចាំ។

127 ហើយនាងនិយាយ "ប៊ីលលី ខ្ញុំចង់ធ្វើបែបនោះដែរ។" នាងនិយាយ "ខ្ញុំ ស្រឡាញ់អ្នក។" ព្រះជាម្ចាស់ប្រទានពរដល់ព្រលឹងនាង ឥឡូវនេះនាងកំពុងនៅ ក្នុងសិរីរុងរឿង។ នាងនិយាយ "ខ្ញុំស្រលាញ់អ្នក។" និយាយ "ខ្ញុំគិតថាយើងត្រូវទៅ ប្រាប់ឳពុកម្តាយរបស់យើង ប្រាប់ពុកម្តាយពីរឿងនេះ។ តើអ្នកគិតដូច្នេះទេ?"

128 ហើយខ្ញុំនិយាយ "អូនសម្លាញ់ ស្តាប់ ចូរយើងចាប់ផ្តើមជាមួយ ហាសិប-ហាសិបភាគរយម្នាក់។" ខ្ញុំនិយាយ "ខ្ញុំនឹងប្រាប់ឳពុករបស់អ្នក បើសិន អ្នកប្រាប់ ម្តាយ របស់អ្នក។" គឺដាក់ឬសដែលពិបាកអោយនាងធ្វើអោយនាង ចាប់ផ្តើម។

នាងនិយាយ "មិនអីទេ សូមអោយអ្នកប្រាប់លោកពុកមុន។"

ខ្ញុំនិយាយ "បាន ខ្ញុំនឹងប្រាប់គាត់នៅ យប់ថ្ងៃអាទិត្យ។"

129 ដូច្នេះយប់ថ្ងៃអាទិត្យមកដល់ ខ្ញុំនាំនាងចេញពីព្រះវិហារ ត្រឡប់ទៅផ្ទះវិញ ហើយខ្ញុំ...នាងនៅសម្លឹងមើលខ្ញុំ។ ហើយខ្ញុំសម្លឹងមើលទៅ ម៉ោងប្រាំបួន-កន្លះ យប់ វាជា ពេលដែលខ្ញុំត្រូវទៅវិញ។ ដូច្នេះ ឆាលីគាត់កំពុងអង្គុយនៅតុរបស់គាត់ កំពុងវាយ អត្ថបទ។ ហើយអ្នកស្រី ប្រាំបាឆ កំពុងអង្គុយនៅជ្រុងម្ខាង កំពុងតែចាក់ ប៉ាក់ អ្នកដឹងទេ មានវត្ថុមូលតូចមួយ គេដាក់អ្វីៗនោះក្នុងនោះ អ្នកស្គាល់ ហើយ។ ខ្ញុំមិនស្គាល់ថាគេហៅថាជាអ្វីនោះទេ។ ដូច្នេះគាត់កំពុងតែធ្វើអ្វីជាមួយឧបករណ៍ នោះ។ ហើយហូបបន្តសម្លឹងមើលមុខខ្ញុំ ហើយនាងជ្រួញចិញ្ចើមដាក់ខ្ញុំ អ្នកដឹង ហើយ បង្ខិតទៅជិតពុករបស់នាង។ ហើយខ្ញុំ...អូ!ខ្ញុំអើយ ខ្ញុំគិត "តើយ៉ាងម៉េចវិញ បើគាត់និយាយថា 'ទេ'?" ដូច្នេះខ្ញុំចាប់ផ្តើមទៅមាត់ទ្វា ខ្ញុំនិយាយ "ខ្ញុំគិតស្មាន ខ្ញុំ គួរតែចេញទៅល្អជាង។"

130 ហើយខ្ញុំដើរទៅមាត់ទ្វា ហើយ—ហើយនាងចាប់ផ្ដើមទៅមាត់ទ្វាដែរជាមួយខ្ញុំ។ នាងតែងតែទៅមាត់ទ្វា ហើយប្រាប់ខ្ញុំថា "រាត្រីសួស្ដី។" ដូច្នេះខ្ញុំចាប់ចេញ ទៅមាត់ទ្វា រួចនាងនិយាយ "អ្នកមិនប្រាប់គាត់ទេរឺ?"

131 ហើយខ្ញុំនិយាយ "ហះ!" ខ្ញុំនិយាយ "ខ្ញុំពិតណាស់នឹងព្យាយាម ប៉ុន្តែខ្ញុំ—ខ្ញុំ—ខ្ញុំមិនដឹងថាធ្វើម៉េច របៀបដែលនឹងចាប់ផ្ដើមធ្វើ។"

132 ហើយនាងនិយាយ "ខ្ញុំនឹងត្រឡប់ទៅវិញ ហើយអ្នកហៅគាត់ចេញមក។" ដូច្នេះនាងដើរទៅវិញ ទុកអោយខ្ញុំឈរនៅទីនោះ។

ហើយខ្ញុំនិយាយ "ឆាលី។"

គាត់បែរ មករួចឆ្លើយ "យេ ប៊ីល?"

ខ្ញុំនិយាយ "តើខ្ញុំអាចនិយាយជាមួយអ្នកមួយភ្លែតបានទេ?"

133 គាត់និយាយ "ប្រាកដណាស់។" គាត់ងាកចេញពីតុរបស់គាត់។ អ្នកស្រី ប្រាំបាធ សម្លឹងទៅគាត់ មើលទៅហួប រួចមើលមកខ្ញុំ។

ហើយខ្ញុំនិយាយ "តើលោកអាចចេញមករានហាលបានទេ?"

ហើយគាត់និយាយ "បាទ ខ្ញុំនឹងទៅក្រៅ។" ដូច្នេះគាត់ចេញទៅក្រៅនៅរានហាលខាងមុខ។

ខ្ញុំនិយាយ "ជាការពិត នេះជាយប់ល្អណាស់មែនទេ?"

គាត់ឆ្លើយ "បាទ វាល្អមែន។"

ខ្ញុំនិយាយ "ពិតជាកក់ ក្ដៅមែន។"

"ពិតជាមានមែន" គាត់មើលមុខខ្ញុំ។

134 ខ្ញុំនិយាយ "ខ្ញុំបានធ្វើការលំបាក" ខ្ញុំនិយាយ "អ្នកដឹងទេសូម្បីតែដៃខ្ញុំ ក្លាយជាក្រិនទៅហើយ។"

គាត់និយាយ "អ្នកអាចយកនាងបាន ប៊ីល។" អូ! ខ្ញុំអើយ "អ្នកអាចយកនាងបាន។"

135 ខ្ញុំគិត "នោះគឺប្រសើរណាស់។" ខ្ញុំនិយាយ "លោកពិតជាមានន័យដូច្នេះ មែនរឺ ឆាលី?" គាត់និយាយ...ខ្ញុំនិយាយ "ឆាលី មើល ខ្ញុំដឹងថានាងជាកូនស្រី របស់លោក ហើយអ្នកមានលុយ។"

136 ហើយគាត់លើកដៃមកកាន់ខ្ញុំ។ គាត់និយាយ "ប៊ីលស្តាប់ លុយមិន មែនជាអ្វីៗទាំងអស់របស់មនុស្សទេ" គាត់និយាយ...

137 ខ្ញុំនិយាយ "ឆាលី ខ្ញុំ—ខ្ញុំរកបានត្រឹមតែ២០សេនក្នុងមួយម៉ោង ប៉ុន្តែខ្ញុំស្រឡាញ់នាងហើយនាងស្រឡាញ់ខ្ញុំ។ ហើយខ្ញុំសន្យានឹងលោកឆាលី ខ្ញុំនឹងប្រឹងធ្វើការរហូតដល់...ស្បែកក្រិនសឹកអស់ពីដៃខ្ញុំ ដើម្បីចិញ្ចឹមនាង។ ខ្ញុំពិតជាស្មោះត្រង់នឹងនាងតាមតែខ្ញុំអាចធ្វើបាន។"

138 គាត់និយាយ "ខ្ញុំជឿ ប៊ីល។" គាត់និយាយ "ស្តាប់ ប៊ីល ខ្ញុំចង់និយាយជា មួយអ្នក។" និយាយ "អ្នកដឹងទេសេចក្តីសុខមិនមែនរួមជាមួយលុយដើម្បីបានសុខនោះទេ។" និយាយ "ចូរធ្វើល្អជាមួយនាង។ ខ្ញុំដឹងថាអ្នកនឹងធ្វើ។"

ខ្ញុំនិយាយ "អរគុណ ឆាលី ខ្ញុំប្រាកដជាធ្វើអញ្ចឹង។"

139 បន្ទាប់មកជាពេលដែលនាងប្រាប់ ម្តាយរបស់នាង។ មិនដឹងថានាងធ្វើយ៉ាងម៉េចទេ ប៉ុន្តែយើងបានរៀបការរួចហើយ។

140 ដូច្នេះពេលយើងរៀបការ យើងមិនមានអ្វីឡើយមិនមានអ្វីប្រើប្រាស់ ក្នុងផ្ទះ។ ខ្ញុំគិតថាយើងមានពីរទៅបីដុល្លា។ ដូច្នេះយើងក៏ជួលផ្ទះ វាត្រូវអោយ យើងបង់ថ្លៃ៤ដុល្លារក្នុងមួយខែ។ វាមានកន្លែងបន្ទប់តូចៗ-ពីរ។ ហើយមានគេ អោយគ្រែបត់មកយើង។ ខ្ញុំឆ្ងល់ថាមាននរណាធ្លាប់ឃើញគ្រែបត់ទេ? ហើយពួកគេ អោយមក យើង។ ហើយខ្ញុំទៅ សៀនិងរ៉ូបាក់ និងមានតុដែលមានកៅអី៤ ហើយ វា—វាមិនបានលាបថ្នាំឡើយ អ្នកដឹងទេ យើងមានទាំងអស់ហ្នឹងនៅពេល នោះ។ ហើយដូច្នេះខ្ញុំទៅជួបលោក វិបប៊ី ជាអ្នកប្រមូលសម្រាម ហើយទិញចង្ក្រាន មួយ។ ខ្ញុំចំណាយចិតសិប-ប្រាំសេនលើរបស់នោះ និងចំណាយមួយដុល្លា សម្រាប់ បន្ទះដែលនៅ ខាងក្នុង។ យើងក៏បានតម្លើងរបស់របរក្នុងផ្ទះ។ ខ្ញុំចាំថាបានយកនិងលាបពណ៌ កៅអីគូ សេមរ៉ក ពេលខ្ញុំលាបថ្នាំលើកៅអី។ ហើយ អូ យើងរីករាយណាស់ ទោះ បីដូច្នោះ ក៏ដោយ។ យើងជួយគ្នាទៅវិញទៅមក ដូច្នេះនោះជារឿងចាំបាច់។ ហើយ ព្រះជាម្ចាស់ដោយក្តីមេត្តានិងសេចក្តីល្អរបស់ទ្រង់ យើងក្លាយជាគូរដែល សប្បាយ បំផុតនៅលើផែនដី។

141 ខ្ញុំរកឃើញថា សេចក្តីសុខមិនមែនជារបស់ លោកកិយ៍ទាំងប៉ុន្មាន ដែលអ្នកមាននោះទេប៉ុន្តែតើអ្នករីករាយប៉ុនណាជាមួយចំណែកដែលចែកអោយ អ្នក។

142 បន្ទាប់ពីនោះមួយរយៈ ព្រះជាម្ចាស់យាងចុះមក ហើយប្រទានពរដល់ ផ្ទះតូចរបស់យើង យើងក៏មានកូនប្រុសតូចមួយ។ ឈ្មោះរបស់គាត់គឺ ប៊ីល ប៉ុល នៅក្នុងកម្មវិធីនេះ ឥឡូវនេះដែរ។ ហើយបន្ទាប់ពីនោះ ប្រហែល១១ខែ ទ្រង់បាន ប្រទានពរអោយយើងម្តងទៀតគឺក្មេងស្រីតូចមួយ ឈ្មោះ សារ៉ុន រ៉ូស យកមកពី ពាក្យ "ដឺរ៉ូស អហ្វ សារ៉ុន។"

143 ហើយខ្ញុំចាំបានថាថ្ងៃមួយ ខ្ញុំបានសន្សំលុយ ហើយយើងមានវិស្សមកាលតូចមួយ ទៅកន្លែងមួយបឹងផាវ ផាវឡេក ដើម្បីស្ទូចត្រី។ ហើយតាមផ្លូវត្រឡប់មក វិញ...

144 នៅពេលនោះ...ខ្ញុំចាប់ផ្តើមចាកចេញដោយការកែប្រែជាថ្មី។ ខ្ញុំត្រូវបាន ផ្លាស់ប្រែ។ ហើយខ្ញុំត្រូវបានចាក់ប្រេងតាំងដោយដុកទ័រ៉យដេវីស ក្នុងព្រះវិហារបេស កកម្មបាបទីស្ទ ហើយបានក្លាយជាអ្នកដឹកនាំ និងមានរោងឧបោសថ ដែល បច្ចុប្បន្នខ្ញុំ កំពុងតែអធិប្បាយនៅក្នុងជេហ្វឺសាន់វីល។ ហើយខ្ញុំធ្វើជាគ្រូគង្វាល នៅព្រះវិហារតូចមួយ។ ហើយខ្ញុំ...

145 គ្មានលុយ ខ្ញុំធ្វើជាគ្រូគង្វាលនៅព្រះវិហារ១៧ឆ្នាំនិងមិនទទួលបានប្រាក់មួយផេននីឡើយ។ ខ្ញុំមិនជឿលើការយក-...ក៏មិនមានការដាក់ដង្វាយនៅក្នុងនោះដែរ។ ហើយតង្វាយ១០ភាគរយដែលខ្ញុំទទួលបានពីការងារ និងអ្វីទៀត គឺមានប្រអប់ តូចមួយនៅក្រោយអាគារ និយាយ មានសញ្ញាលើនោះ "អ្វីដែលអ្នកបានធ្វើទោះបីប៉ុណ្ណាក្តីចំពោះកូនតូចជាងគេរបស់ខ្ញុំ អ្នកបានធ្វើការនោះចំពោះខ្ញុំដែរ។" ហើយនោះហើយជារបៀបដែលក្រុមជំនុំ បានអោយថ្លៃឈ្នួល។ យើងមានចំនួនជំពាក់ ត្រូវសង១០ឆ្នាំ ហើយយើងសងក្នុងរយៈពេលតិចពីរឆ្នាំប៉ុណ្ណោះ។ ហើយខ្ញុំមិន ដែលទទួលដង្វាយដែលមិនដោយសប្បុរសនោះទេ។

146 បន្ទាប់មកខ្ញុំមាន អូ មានលុយបីបួនដុល្លា ខ្ញុំសន្សំសម្រាប់ការឈប់ សម្រាកលំហែរ។ នាងក៏ធ្វើការដែរ នៅរោងចក្រខោអាវ។ ជាក្មេងស្រីគួរអោយ ស្រឡាញ់។ ហើយផ្ទះរបស់នាង អាចមានព្រិលផងសព្វថ្ងៃនេះ ប៉ុន្តែនាងនៅក្នុងចិត្តខ្ញុំនៅឡើយ។ ហើយខ្ញុំចាំថាពេលនាងខំប្រឹងធ្វើការដើម្បីជួយខ្ញុំអោយមាន លុយគ្រប់គ្រាន់ដើម្បីចេញទៅបឹងស្ទូចត្រី។

147 ហើយពេលខ្ញុំត្រឡប់មកពីបឹងវិញ ខ្ញុំចាប់ផ្តើមឃើញ ចូលទៅមីសាវ៉ាកា និងសៅបិន អិនឌៀអាយណា ហើយខ្ញុំចាប់ផ្តើមកត់សម្គាល់ ពីរថយន្តដែលមាន

សញ្ញានៅពីក្រោយនិយាយថា "ព្រះយេស៊ូវតែមួយគត់។" ហើយខ្ញុំគិត "សម្លេងដូច ជាចម្លែក 'ព្រះយេស៊ូវតែមួយគត់។'" ហើយខ្ញុំចាប់ផ្តើមកត់សម្គាល់ពីសញ្ញានោះ។ ហើយវា ជាកន្លែងមួយនៅពេលជិះទោចក្រយាន ហ្វដ កាឌីឡលេស និងអ្វីទៀត "ព្រះយេស៊ូវតែមួគត់។" ហើយខ្ញុំក៏ទៅតាមពួកគេ ហើយពួកគេក៏ចូលទៅព្រះវិហារ ធំមួយ។ ខ្ញុំរកឃើញថា ពួកគេជាក្រុម ពេនទីកុស្ត។

148 ខ្ញុំឮពីពេនទីកុស្ត ប៉ុន្តែពួកគេជាក្រុមមនុស្ស "ហូលី-រ៉ូលឡឺ ដេកលើកម្រាលប៉ុណ្ណោះ ហើយបែកពពុះមាត់" និងគ្រប់រឿងដែលគេប្រាប់ខ្ញុំពីនោះ។ ដូច្នេះខ្ញុំមិនចង់ធ្វើអ្វីជាមួយវាឡើយ។

149 ដូច្នេះខ្ញុំឮពួកគេមានលក្ខណៈបែបនោះហើយខ្ញុំគិត "ជឿថាគ្រាន់តែដើរចូលក្នុង។" ខ្ញុំឈប់ហ្វដចាស់របស់ខ្ញុំ ហើយដើរចូលទៅក្នុង ហើយទាំងអស់គ្នាកំពុងតែច្រៀងដែលអ្នកមិនធ្លាប់ឮពីមុនមកក្នុងជីវិតអ្នក! ហើយខ្ញុំចូលទៅរកអោយឃើញ ខ្ញុំឃើញមានក្រុមជំនុំពីរនៅទីនោះ មួយនៃចំនោមនោះគឺហៅថា ភី.អេ នៃ ជេ.ស៊ី និងភី.អេ នៃដបបលយូមានអ្នកជាច្រើនចងចាំពីរអង្គភាព-...នោះ ខ្ញុំគិតថា ពួកគេរួបរួមគ្នាឥឡូវហៅ ហៅថាសហព្រះវិហាពេនតេកុស្ត។ ល្អ ខ្ញុំស្តាប់គ្រូខ្លះ របស់ពួក គេ។ ហើយពួកគេកំពុងឈរនៅទីនោះ អូ ពួកគេកំពុងតែអធិប្បាយ ពីព្រះយេស៊ូវ និងទ្រង់អស្ចារ្យប៉ុណ្ណា ហើយពីការអស្ចារ្យផ្សេងៗ និងពី "ការជ្រមុជដោយ ព្រះវិញ្ញាណបរិសុទ្ធ។" ខ្ញុំគិត "តើពួកគេកំពុងនិយាយពីអ្វី?"

150 ហើយបន្ទាប់មួយស្របក់ មានមនុស្សម្នាក់លោតឡើង ហើយចាប់និយាយភាសាដទៃ។ ល្អ ខ្ញុំមិនដែលឃើញអ្វីដូច្នោះក្នុងជីវិតរបស់ខ្ញុំឡើយ។ ហើយនៅទីនេះ មានស្ត្រីម្នាក់ឡើងមករត់ពេញទីនោះតាមតែគាត់អាចធ្វើទៅបាន។ ហើយពួកគេទាំងអស់គ្នាក្រោកឡើង ហើយចាប់ផ្តើមរត់។ ហើយខ្ញុំគិតថា "ល្អ បងប្អូនពួកគេមិនមានអ្វីដែលជាក្ខណៈព្រះវិហារទេ!" ស្រែក ដង្ហោយ និងបន្តរហូត ខ្ញុំគិត "តើក្រុមនេះជាអ្វី!" ប៉ុន្តែអ្នកដឹងទេ មានអ្វីមួយអំពីនោះ ខ្ញុំអង្គុយទីនោះកាន់តែយូ ខ្ញុំកាន់តែមានអារម្មណ៍ថាចូលចិត្ត។ គឺមានអ្វីហាក់ដូចជា ពិតជាល្អណាស់។ ហើយខ្ញុំផ្តើមមើលពួកគេ។ ហើយវានៅតែបន្ត។ ខ្ញុំគិត"ខ្ញុំនៅទ្រាំជាមួយពួកគេមួយស្របក់ ព្រោះខ្ញុំនឹង...ខ្ញុំនឹងចូលទៅជិតមាត់ទ្វាហើយ។ បើមានអ្វី ចាប់ផ្តើម ខ្ញុំនឹងរត់ចេញពីទ្វា។ ខ្ញុំស្គាល់កន្លែងដែលឡានរបស់ខ្ញុំចត គឺនៅកាច់ជ្រុង។"

151 ហើយខ្ញុំបានឮពួកគេខ្លះដែលជាអ្នកអធិប្បាយ ជាគ្រូនិងជាសិស្ស។ ហេតុអ្វី "នោះមិនអីទេ។"

ដូច្នេះវាជាពេលដែលគួរភ្ញាក់ផ្អើលនិងនិយាយ "គ្រប់គ្នាឈានដល់ភាពខ្លាំងក្លា។"

152 ប៉ុន្តែខ្ញុំគិត "ចាំមួយភ្លែត។ ខ្ញុំមានលុយមួយដុល្លានិងចិត-ប្រាំសេន ត្រឡប់ទៅ ផ្ទះវិញ ហើយខ្ញុំ..." នោះជាលុយដែលខ្ញុំមានសម្រាប់សាំង។ មានទាំងអស់នោះ សម្រាប់ខ្ញុំត្រលប់ទៅផ្ទះវិញ។ ហើយខ្ញុំមានហ្វដចាស់របស់ខ្ញុំ វាជាហ្វដចាស់យ៉ាងល្អ។ វាមិនដែលខូចទេ វាដូចជាអាមួយនៅខាងក្រៅ រូបរាងដូចគ្នា។ ហើយវា...ខ្ញុំជឿថាហ្វដអាចធ្វើដំនើរ បាន៣០ម៉ាយក្នុងមួយម៉ោង ប៉ុន្តែសភាពដែលមាន១៥ របៀបនេះ និង១៥របៀបនេះ។ អ្នកឃើញទេដាក់វាបញ្ចូលគ្នាអ្នកអាចមាន៣០។ ហើយដូច្នេះវា...ខ្ញុំគិត "ល្អ យប់នោះខ្ញុំគិតថាខ្ញុំចេញទៅក្រៅ ហើយបន្ទាប់ពី..." ខ្ញុំបាននៅក្នុងកម្មវិធីពេលយប់។

153 ហើយ អូ គាត់និយាយ "អ្នកអធិប្បាយទាំងអស់ មិនគិតថានិកាយ ណាទេ អាចមកវេទិការ។" ល្អ ហើយពួកយើងមានគ្នាប្រហែល២០០នាក់ ខ្ញុំឡើង ទៅ។ ហើយ គាត់និយាយ "ឥឡូវយើងមិនមានពេលអោយអ្នកទាំងអស់គ្នា អធិប្បាយនោះទេ។" គាត់និយាយ "គ្រាន់តែដើរមក ហើយនិយាយថាអ្នកជានរណា មកពីណា។"

154 ល្អ ដល់វេនខ្ញុំ ខ្ញុំនិយាយ "វិល្លៀមប្រាណហាំបាបទីស្ទ។ ជេហ្វឺសាន់វីល អិនឌៀអាយណា។" ដើរទៅ។

155 ខ្ញុំឮពួកគេហៅខ្លួនឯងថា "ពេនតេកុស ពេនតេកុស ពេនតេកុស ភីអេ នៃ ដាប់បលយូ ភីអេជេស៊ី ភីអេដាប់បលយូ ភី..."

156 ខ្ញុំដើរទៅ។ ខ្ញុំគិត "ល្អ ខ្ញុំយល់ថាខ្ញុំជាកូនទាគគ្រិចហើយ" ដូច្នេះខ្ញុំ អង្គុយចុះ រងចាំ។

157 ហើយថ្ងៃនោះ ពួកគេនៅជាសុខស្ងប់ អ្នកអធិប្បាយវ័យក្មេងចេញមក ហើយអធិប្បាយយ៉ាងមានអំណាច។ ហើយពួកគេនិយាយ "អ្នកដែលនឹងនាំសារ នៅយប់នេះគឺ..." ខ្ញុំជឿថាគេហៅគាត់ថា "ចាស់ទុំ។" និងព័ន្ធកិច្ចរបស់ពួកគេ ជំនួសអោយ "លោកគ្រូ" វាគឺជា "ចាស់ទុំ"។ ហើយពួកគេនាំបុរសចាស់ជនជាតិស្បែក

ខ្មៅម្នាក់ចេញមក ហើយគាត់មានអាវ-ធំជាអ្នកអធិប្បាយបែបបុរាណ។ ខ្ញុំមិនគិត ស្មានថាអ្នកធ្លាប់បានឃើញនោះទេ។ មានកន្ទុយ-ព្រាបវែងនៅពីក្រោយ អ្នកស្គាល់ទេ មានកអាវកម្ពី ហើយគាត់មានចុងសក់ពណ៌សជុំវិញក្បាល។ ជាសហមិត្តគួរ អោយអាណិត គាត់ចេញមកដោយរបៀបនេះ។ អ្នកដឹងទេគាត់ឈរនៅទីនោះហើយគាត់បែរជុំវិញ។ នៅកន្លែងដែលគ្រប់ អ្នកអធិប្បាយគេអធិប្បាយ ពីព្រះយេស៊ូវនិងការអស្ចារ្យ...ពីទ្រង់អស្ចារ្យយ៉ាងណា និងផ្សេងទៀត ហើយបុរសចាស់ក៏ទាញអត្ថបទ ពីក្នុងគម្ពីយ៉ូប "តើអ្នកនៅឯណាពេលដែលយើងបានដាក់គ្រឹះផែនដី ឬពេលដែល ផ្កាយព្រឹករះទាំងអស់មកហើយបុត្ររបស់ព្រះជាម្ចាស់ស្រែកដោយអំណរ?"

158 ជាមិត្តវ័យចាស់គួរអោយអាណិត ខ្ញុំគិត "ហេតុអ្វីបានជាគេមិនដាក់អ្នកដែលជាសហមិត្តក្មេងៗអធិប្បាយនៅទីនោះ?" អស្ចារ្យ...កន្លែងនោះណែនណាន់កកកុញ។ ហើយខ្ញុំគិត "ហេតុអ្វីបានជាពួកគេធ្វើដូច្នេះ?"

159 ដូច្នេះ មិត្តចាស់នេះ ជំនួសអោយការអធិប្បាយអ្វីដែលកើតមានលើ ផែនដី គាត់និយាយពីអ្វីដែលនៅស្ថានសួគ៌គ្រប់ពេលវិញ។ ល្អ គេយកទ្រង់ទៅ ពេលដំបូងបង្អស់ ហើយនាំទ្រង់មកវិញ ការយាងមកជាលើកទីពីរ ដោយឥន្ទធនូដេក។ ហេតុអ្វី ខ្ញុំមិនដែលឮការអធិប្បាយបែបនេះក្នុងជីវិតឡើយ! នៅពេលនោះវិញ្ញាណក៏វាយគាត់ គាត់ក៏លោតឡើងកម្ពស់*នោះ* ហើយចុចកែងជើងផ្គុំគ្នាបោះស្មាមកវិញ ហើយទៅចុងវេទិការនិយាយថា និយាយ "អ្នកមិនមានកន្លែងគ្រប់គ្រាន់នៅទីនេះអោយខ្ញុំអធិប្បាយឡើយ។" គាត់មានកន្លែងមួយដែលធំជាងដែលខ្ញុំមាននៅទីនេះ។

160 ខ្ញុំគិត "បើសិនជានោះនាំអោយបុរសវ័យចាស់ សម្តែងឡើងយ៉ាងនោះទៅហើយ តើវានឹងកើតជាយ៉ាងណាបើធ្លាក់មកលើខ្ញុំ?" ខ្ញុំ—ខ្ញុំ គិត "ប្រហែលជាខ្ញុំត្រូវការបែបនោះខ្លះហើយ" ហេតុអ្វីបានជាគាត់ចេញមកទីនេះ ខ្ញុំមានអារម្មណ៍អាណិតដល់មិត្តវ័យចាស់នោះណាស់។ ប៉ុន្តែពេលគាត់ចេញទៅខ្ញុំមានអារម្មណ៍សោកស្តាយចំពោះខ្លួនឯងវិញ។ ហើយខ្ញុំសម្លឹងមើលគាត់ចេញពីទីនោះ។

161 ខ្ញុំចេញទៅក្រៅយប់នោះហើយខ្ញុំគិត "ឥឡូវ ព្រឹកបន្ទាប់ខ្ញុំមិនអោយ នរណាដឹងថា ខ្ញុំមកពីណា ជានរណាឡើយ" ដូច្នេះខ្ញុំចេញទៅហើយយប់នោះខ្ញុំ សង្កត់ខោរបស់ខ្ញុំ។ ខ្ញុំយក...ចេញទៅក្រៅចំការពោតដើម្បីដេក ហើយចុះទៅទិញ នំប៉័ង

ចាស់មួយសម្រាប់បរិភោគ។ អ្នក...ខ្ញុំទិញកញ្ចប់នំទាំងមូលតម្លៃមួយនីកកែល។ មានក្បាលទឹកម៉ាស៊ីននៅទីនោះ ខ្ញុំយកទឹកនៅទីនោះ។ ដូច្នេះខ្ញុំដឹងថា ខ្ញុំអាចនៅទីនោះយូបន្តិច ដូច្នេះខ្ញុំយកទឹកប្រើនិងផឹកវា ហើយចេញទៅបរិភោគនំប៉័ងរបស់ខ្ញុំ។ ហើយត្រឡប់មកវិញនិងយកទឹកម្តងទៀត។ ចេញទៅជ្រុងចំការ ពោតយកកៅអីពីរ ដាក់ខោសៀសាក់ខីតូចរបស់ខ្ញុំ សង្កត់ញាត់វានៅលើកៅអី។

162 ហើយនៅយប់នោះ ខ្ញុំអធិស្ឋានស្ទើរពេញមួយយប់។ ខ្ញុំនិយាយ "ព្រះអម្ចាស់ តើនេះជាអ្វីដែលទូលបង្គំកំពុងតែចូលរួមនេះ? ខ្ញុំមិនដែលឃើញពួក អ្នកកាន់សាសនាបែបនេះក្នុងជីវិតទូលបង្គំឡើយ។" ហើយខ្ញុំនិយាយ "សូមជួយទូលបង្គំអោយយល់ពីរឿងនេះផង។"

163 ហើយនៅព្រឹកបន្ទាប់ខ្ញុំចុះទៅ។ អញ្ជើញ ពួកយើងបរិភោគអាហារពេលព្រឹក។ លក្ខណៈខ្ញុំមិនបានចូលទៅបរិភោគ ជាមួយគេឡើយ ព្រោះខ្ញុំមិនបានដាក់ប្រាក់តង្វាយ។ ហើយខ្ញុំត្រឡប់មកវិញ។ ហើយនៅព្រឹកបន្ទាប់ ពេលដែលខ្ញុំចេញទៅហេតុអ្វី(ខ្ញុំបរិភោគនំប៉័ងមូលរបស់ខ្ញុំ)និងអង្គុយនោះទីនោះ។ ហើយពួកគេក៏មានមីក្រូហ្វូន។ ហើយខ្ញុំមិនធ្លាប់ឃើញមីក្រូហ្វូនពីមុនឡើយ ហើយខ្ញុំខ្លាចវត្ថុនោះ។ ដូច្នេះពួកគេ...វាមានខ្សែព្យួរនៅទីនោះហើយវាព្យួរទម្លាក់ចុះ។ ម្នាក់ក្នុងចំណោមពួកគេទម្លាក់មីក្រូហ្វូនដូចនោះ។ ហើយគាត់និយាយ "កាលពី យប់មិញនៅលើវេទិការមានអ្នកអធិប្បាយវ័យក្មេងម្នាក់នៅទីនេះ ជាអ្នកបាបទីស្ទ។"

ខ្ញុំគិត "អះ អូ ខ្ញុំល្អត្រូវអោយគេធ្វើទុកហើយឥឡូវ។"

164 រួចគាត់និយាយ "គាត់ជាអ្នកអធិប្បាយ ដែលក្មេងបំផុតនៅលើវេទិការ។ ឈ្មោះរបស់គាត់គឺប្រានហាំ។ តើនរណាដឹងថាគាត់នៅឯណាទេ?ប្រាប់គាត់អោយមកយើងចង់អោយគាត់នាំសារពេលព្រឹក។"

165 អូ! ខ្ញុំពាក់អាវយឺតតូចមួយ និងខោសៀសាក់ខី អ្នកដឹងទេ។ យើងជាអ្នក បាបទីស្ទជឿថាអ្នកត្រូវតែ មានឈុតពាក់ ក្នុងការដែលឈរនៅលើវេទិការ អ្នកដឹងហើយ។ ដូច្នេះ...ហើយខ្ញុំ—ខ្ញុំអង្គុយនៅស្ងៀម។ ហើយនៅពេលនោះ...ពួកគេមាន កម្មវិធីនៅខាងជើង ហើយដោយព្រោះ (សន្និបាតអន្តរជាតិរបស់ពួកគេ) ពួក មនុស្សស្បែកខ្មៅមិនអាចចូលរួមទេ បើសិនជាពួកគេធ្វើនៅខាងត្បូង។ ពួកគេមានពួកស្បែកខ្មៅនៅទីនោះ ហើយខ្ញុំជាអ្នកខាងត្បូង មានម្សៅជាប់នៅនឹង កអាវនៅឡើយ អ្នកឃើញទេ ហើយខ្ញុំទំនងជាងអ្នកខ្លះទៀតបន្តិច។ ហើយវាកើត ឡើង

នៅព្រឹកនោះ ហើយអ្នកអង្គុយជិតខ្ញុំជាអ្នក—អ្នកស្បែកខ្មៅ ដូច្នេះខ្ញុំអង្គុយ មើលទៅគាត់។ ខ្ញុំគិត "ល្អគាត់ជាបងប្រុស។"

166 ហើយគាត់និយាយ "មានអ្នកដឹងទេ វិល្លៀមប្រាណហាំនៅទីណាទេ?" ខ្ញុំនៅជាប់នឹងកៅអីដូចនេះ។ ដូច្នេះគាត់និយាយ ប្រកាសជាលើកទីពីរ និយាយ "អ្នកណាដែលនៅខាងក្រៅ"(គាត់ទាញមេក្រូតូចចូល) "ស្គាល់វិល្លៀមប្រាណហាំនៅ ទីណាទេ? ប្រាប់គាត់ថាយើងចង់ងោយគាត់មក លើវេទិការដើម្បីនាំសារនៅព្រឹក នេះ។ គាត់ជាអ្នកអធិប្បាយនៅបាបទីស្ទ ជាអ្នកអៀនខ្មៀអាយណាខាងត្បូង។"

167 ខ្ញុំអង្គុយនៅយ៉ាងស្ងៀមហើយ ឱនចុះ អ្នកដឹងហើយ។ គ្មាននរណាម្នាក់ស្គាល់ខ្ញុំ ដោយរបៀបណាឡើយ។ក្មេងប្រុសស្បែកខ្មៅនៅក្បែរនោះសម្លឹងមើលខ្ញុំនិយាយ "អ្នកដឹងថាគាត់នៅឯណាទេ?"

168 ខ្ញុំគិតថា។ ខ្ញុំ—ខ្ញុំត្រូវកុហកឬយ៉ាងណា។ ដូច្នេះខ្ញុំនិយាយ "ចាំនៅទីនេះ។"

គាត់និយាយ "បាទ លោក?"

ខ្ញុំនិយាយ "ខ្ញុំចង់ប្រាប់អ្នករឿងខ្លះ។" ខ្ញុំនិយាយ "ខ្ញុំ—ខ្ញុំគឺជាគាត់ហើយ។"

គាត់និយាយ "ល្អ ឡើងទៅអញ្ចឹង។"

169 ហើយខ្ញុំនិយាយ "ទេខ្ញុំមិនអាច ឃើញទេ។" ខ្ញុំនិយាយ "ខ្ញុំស្លៀក ខោសៀសាក់ខីចាស់តូចនេះ ជាមួយអាវយឺតតូចមួយ។" ខ្ញុំនិយាយ "ខ្ញុំមិនអាចឡើងទៅទីនោះទេ។"

170 គាត់និយាយ "ពួកគេជាមនុស្សមិនខ្វល់ពី ពីរបៀបអ្នកស្លៀកបែបណាទេ។ ឡើងទៅទីនោះទៅ។"

ខ្ញុំនិយាយ "ទេ ទេ។" ខ្ញុំនិយាយ "នៅអោយស្ងៀម កុំនិយាយ អ្វីឥឡូវនេះ។"

171 ហើយពួកគេត្រឡប់ទៅមេក្រូមួយភ្លែត និយាយ "នរណាដឹងថា វិល្លៀម ប្រាណហាំនៅឯណាទេ?"

172 គាត់និយាយ "គាត់នៅទីនេះ! គាត់នៅទីនេះ! គាត់នៅទីនេះ!" អូ! ខ្ញុំអើយ ខ្ញុំត្រូវងើបចេញទៅជាមួយអាវយឺតតូច អ្នកដឹងទេ។ ហើយ នៅទីនេះ...

173 គាត់និយាយ "មកលោកប្រាណហាំ យើងចង់អោយអ្នកនាំសារមកអោយយើង។" អូ ខ្ញុំអើយ នៅមុខអ្នកអធិប្បាយ អាំ នៅមុខពួកគេទាំងអស់គ្នា! ហើយខ្ញុំ

ទៅទាំង រអិល។ អ្នកដឹងទេ មុខខ្ញុំឡើងក្រហម ហើយត្រចៀកខ្ញុំឆេះក្តៅ។ ហើយខ្ញុំ រអិល ខោសៀសាក់ខី និងអាវយឺត អ្នកអធិប្បាយ អ្នកអធិប្បាយបាបទីស្ទ ឡើងទៅមុខ មីក្រូហ្វូន មិនធ្លាប់ឃើញពីមុនមកទេ អ្នកឃើញទេ។

174 ហើយខ្ញុំឈរឡើងទីនោះ ខ្ញុំនិយាយ "ល្អ ខ្ញុំ—ខ្ញុំ—ខ្ញុំមិនដឹងពីរឿងនេះទេ។" រារែកដោយភ័យពិតៗ អ្នកដឹងទេ។ ហើយ—ហើយខ្ញុំចាប់ផ្ដើដោយមើលនៅលូកា ជំពូក១៦ រួចខ្ញុំគិត "ល្អ ឥឡូវ..." ហើយខ្ញុំ—ខ្ញុំរកបានប្រធានបទ "រួចគាត់ងើបភ្នែកឡើងនៅស្ថាននរករួចយំ។" រួចខ្ញុំ...ដូច្នេះខ្ញុំ—ខ្ញុំចាប់ផ្ដើម អធិប្បាយ អ្នកដឹងទេ ខ្ញុំចាប់ ផ្ដើមអធិប្បាយហើយមានអារម្មណ៍ល្អឡើងបន្តិច។ ហើយខ្ញុំនិយាយ "បុរសអ្នកមានគាត់នៅក្នុងស្ថាននរក រួចគាត់យំ។" ពាក្យតូចៗបីនោះ ខ្ញុំមានពាក្យអធិប្បាយ យ៉ាងច្រើនបែបនោះ "ជឿថាអ្នកបែបនេះ" ហើយ "និយាយទៅកាន់ដុំថ្ម" អ្នកធ្លាប់ឮខ្ញុំអធិប្បាយរឿងទាំងនោះ។ រួចខ្ញុំបាន "បន្ទាប់មកគាត់យំ។" រួចខ្ញុំនិយាយ "គ្មានក្មេងនៅទីនោះ មិនមកក្នុងស្ថាននរក។ បន្ទាប់មកគាត់យំ។" ខ្ញុំនិយាយ "គ្មានផ្កានៅទីនោះ។ រួចគាត់យំ។ គ្មានព្រះនៅទីនោះទេ។ រួចគាត់យំ។ គ្មានព្រះគ្រីស្ទនៅទីនោះទេ។ រួចគាត់យំ" ហើយខ្ញុំយំ។ មានអ្វីដែលមកក្ដោបខ្ញុំ។ ខ្ញុំអើយ! អូ! បន្ទាប់មក ខ្ញុំមិនដឹងថាអ្វីកើតឡើងនៅទេ។ ពេលខ្ញុំដូចជាត្រឡប់ មកខ្លួនឯងវិញ ខ្ញុំកំពុងតែឈរនៅខាងក្រៅ។ មនុស្សទាំងនោះពួកគេស្រែក ដង្ហោ យំ និងខ្ញុំ យើងមានពេលមួយដ៏ធុញថប់។

175 ពេលខ្ញុំមកក្រៅ ក៏មានមិត្តម្នាក់ដើរមករកខ្ញុំ ជាមួយមួកតិចសាសធំមួយស្បែកជើងប៊ូតធំ ដើរមក និយាយ "ខ្ញុំជាចាស់ទុំ នេះ-និង-នេះ។" អ្នកអធិប្បាយស្បែក ជើងប៊ូតខៅបយ ពាក់សម្លៀកបំពាក់ខៅបយ។

ខ្ញុំគិត "ល្អ ខោសៀសាក់ខីរបស់ខ្ញុំ មិនមែនអាក្រក់ប៉ុន្មានអីណា"។

176 និយាយ "ខ្ញុំចង់អោយអ្នកទៅតិចសាស ដឹកនាំការរីកផុសផុលមួយ។"

177 "អះ ហះ ចូរអោយខ្ញុំទុកវាសិន។" រួចខ្ញុំទុកវាបែបនោះ។

178 ទីនេះមានមិត្តម្នាក់ទៀតជាមួយនឹងខោលេងហ្គោល កន្លែង ដែលគេលេងហ្គោល អ្នកដឹងទេ មានខោជាប់អាវបន្តិច។ គាត់និយាយ "ខ្ញុំជាចាស់ទុំ នេះ-និង-ដូចនេះ មកពីម៉ាយអាមី។ ខ្ញុំចូលចិត្ត..."

179 "ខ្ញុំអើយ ប្រហែលជាការស្លៀកពាក់មិនមែនជាអ្វីសំខាន់ច្រើននោះទេ។" ខ្ញុំសម្លឹងមើលវា និងគិត "មិនអីទេ។"

180 ដូច្នេះក្តោបយកអ្វីទាំងអស់នោះ រួចខ្ញុំទៅផ្ទះវិញ។ ប្រពន្ធបានមកជួបខ្ញុំ នាងនិយាយ "ហេតុអ្វី ស្តាប់សូររបស់បងដូចជារីករាយម្ល៉េះ ប៊ីលលី?"

181 ខ្ញុំនិយាយ "អូ ខ្ញុំបានជួបរបស់មួយល្អបំផុត។ ខ្ញុំអើយ វាជាភាពល្អបំផុត ដែលអ្នកបានឃើញ។ ពួកគេទាំងនោះមិនអាម៉ាស់ចំពោះសាសនារបស់ពួកគេឡើយ។" ហើយ អូ ខ្ញុំ ប្រាប់នាងពីរឿងទាំងអស់។ រួចខ្ញុំនិយាយ "មើលនៅទីនេះ អូនសម្លាញ់ ជាខ្សែរនៃ ការអញ្ជើញ។ របស់ពួកគេ!"

នាងនិយាយ "ពួកគេមិនមែនជាហូលីរ៉ូលឡឺទេ មែនទេ?"

182 ខ្ញុំនិយាយ "ខ្ញុំមិនដឹងថាពួកគេជាពួកហូលីរ៉ូលឡឺយ៉ាងណាទេ ប៉ុន្តែពួកគេមានអ្វីដែលខ្ញុំចង់បាន។" ឃើញ? ខ្ញុំនិយាយ "នោះគឺ—នោះគឺអ្វីមួយដែលខ្ញុំប្រាកដប្រជា។" ខ្ញុំនិយាយ "ខ្ញុំបានឃើញបុរសចាស់ម្នាក់អាយុ៩០ឆ្នាំក្លាយ ជាក្មេងសាជាថ្មី។" ខ្ញុំនិយាយ "ខ្ញុំមិនដែលឮការអធិប្បាយបែបនោះក្នុងជីវិតខ្ញុំឡើយ។ ហេតុអ្វីខ្ញុំ មិនដែលឃើញបាបទីស្ទអធិប្បាយបែបនោះ។" ខ្ញុំនិយាយ "ពួកគេអធិប្បាយរហូតដល់មិនអាចចាប់ដង្ហើមបាន ហើយបត់ជង្គង់អធិស្ឋានលើកម្រាលមកសារជាថ្មីចាប់ ដង្ហើមវិញ។ អូនអាចឮពួកគេទោះ ចំងាយ ពីរប្លុក ក៏ដោយនៅតែអធិប្បាយ។" ខ្ញុំនិយាយ "បង—បងមិនដែលឮបែបនេះក្នុងជីវិត ឡើយ។" ហើយខ្ញុំនិយាយ "ពួកគេ និយាយភាសាដទៃ ហើយម្នាក់ទៀតប្រាប់ពីអ្វីដែលពួកគេកំពុងនិយាយ។ មិនដែលឮបែបនោះក្នុងជីវិតរបស់បងឡើយ!" ខ្ញុំ និយាយ "តើអូននឹងទៅជាមួយបងទេ?"

183 នាងនិយាយ "បងសម្លាញ់ ខ្ញុំរៀបការជាមួយបង ខ្ញុំនឹងនៅជាប់ជាមួយ បងរហូតដល់សេចក្តីស្លាប់មកបំបែកយើង។" នាងនិយាយ "អូននឹងទៅ។" នាងនិយាយ "ឥឡូវ យើងនឹងប្រាប់ពួកគេ។"

184 ហើយខ្ញុំនិយាយ "ល្អ អូនប្រាប់ម៉ែរបស់អូន បងនឹងប្រាប់ម្តាយរបស់បង។" ដូច្នេះយើង...ក៏ទៅប្រាប់អ្នកម៉ែ។

185 អ្នកម៉ែនិយាយ "ល្អ ពិតណាស់ ប៊ីលលី។ អ្វីដែលព្រះជាម្ចាស់ហៅអ្នកអោយធ្វើ ទៅធ្វើចុះ។"

186 ហើយដូច្នេះ អ្នកស្រី ប្រាំបានឆស្នើរខ្ញុំអោយមកជួបៗ ឡើងទៅ។ គាត់និយាយ "អ្នកកំពុងនិយាយពីអ្វី?"

187 ហើយ ខ្ញុំនិយាយ "អូ អ្នកស្រីប្រាំបាន" ខ្ញុំនិយាយ "អ្នកមិនធ្លាប់ឃើញ មនុស្សបែបនោះទេ។"

គាត់និយាយ "ស្ងាត់! នៅអោយស្ងាត់!"

ខ្ញុំនិយាយ "បាទ ម៉ែ" ខ្ញុំនិយាយ "ខ្ញុំសូមទោស។"

ហើយគាត់និយាយ "តើអ្នកដឹងទេថានោះជា ក្រុម ហូលលីរ៉ូលឡឺ?"

188 ខ្ញុំនិយាយ "ទេ ម៉ែ ខ្ញុំមិនដឹងទេ។" ខ្ញុំនិយាយ "ពួកគេ—ពួកគេជាមនុស្សត្រឹមត្រូវ។"

189 គាត់និយាយ "ជាគំនិត! តើអ្នកដឹងទេថាអ្នកកំពុងទាញកូនស្រីរបស់ខ្ញុំ ចូលទៅរបស់អញ្ចឹងហើយ!" និយាយ "កំប្លែងមែន! គ្មានអ្វីទេគ្រាន់តែជាសម្រាម ដែលក្រុមជំនុំផ្សេងទៀតគេបោះចោល។" គាត់និយាយ "ជាការពិត! អ្នកកុំនាំកូនស្រី ខ្ញុំទៅដូច្នោះ។"

190 ហើយខ្ញុំនិយាយ "ប៉ុន្តែអ្នកដឹងទេ អ្នកស្រី ប្រាំបាន នៅក្នុងចិត្តរបស់ខ្ញុំ ខ្ញុំមានអារម្មណ៍ថាព្រះជាម្ចាស់ចង់អោយខ្ញុំទៅជាមួយពួកមនុស្សទាំងនោះ។"

191 គាត់និយាយ "អ្នកត្រឡប់ទៅកាន់ក្រុមជំនុំរបស់អ្នក រហូតដល់ពួកគេ អាចផ្តត់ផ្តត់ភាពជាសង្ឃរបស់អ្នក ហើយសម្តែងកាយវិកា ជាមនុស្សមានសតិចុះ។" និយាយ "អ្នកកុំយកកូនស្រីរបស់ខ្ញុំទៅតាមរបៀបនោះ។"

ខ្ញុំនិយាយ "បាទ ម៉ែ។" ខ្ញុំ បែរ រួចដើរចេញ។

192 ហើយ ហូបចាប់ផ្តើមយំ។ នាងចេញមក នាងនិយាយ "ប៊ីលលីកុំយក ចិត្តទុកដាក់ជាមួយអ្វីដែលម៉ែនិយាយចុះ អូននឹងនៅជាមួយបង។" ចិត្តនាងមានពរណាស់!

រួចខ្ញុំនិយាយ "អូ នោះជាការត្រឹមត្រូវ អូនសម្លាញ់។"

193 ហើយខ្ញុំទុកអោយវាកន្លងទៅ។ គាត់មិនអនុញ្ញាតិអោយកូនស្រីរបស់ គាត់ទៅតាមមនុស្សទាំងនោះឡើយ ព្រោះ "វាមិនមែនជាអ្វី ក្រៅពីសម្រាមឡើយ។" ហើយខ្ញុំគ្រាន់តែទុកអោយវាកន្លងទៅប៉ុណ្ណោះ។ វាជាកំហុសដ៏អាក្រក់បំផុត ដែលខ្ញុំបានធ្វើក្នុងជីវិត គឺក្នុងចំនោមភាពអាក្រក់បំផុត។

194 ក្រោយបន្តិចមក បីបួនឆ្នាំក្រោយមក កូនចេះតែបន្តមាន ហើយនៅ ថ្ងៃមួយ យើងក៏...មានទឹកជំនន់កើតឡើងក្នុងឆ្នាំ១៩៣៧។ មានទឹកជំនន់ កើតឡើង។ ហើយរបស់យើង...ខ្ញុំនៅកន្លែងល្បាតនៅពេលនោះ ហើយខ្ញុំបានធ្វើអ្វី ដែលល្អ បំផុតដើម្បីជួយប្រជាជនយើងពីទឹកជំនន់ ផ្ទះជាច្រើនត្រូវបានបាក់បែក។ ហើយប្រពន្ធរបស់ខ្ញុំមានជំងឺ នាងឈឺធ្ងន់ នាងរលាកសួត។ ហើយពួកគេនាំនាងចេញទៅ...ពេទ្យអចិន្ត្រៃគឺពេញហើយដូច្នេះយើងមិនអាចទុកនាង នៅទីនោះ ដូច្នេះយើងនាំនាងទៅ—រដ្ឋាភិបាលដែលគេមានកន្លែងនៅទីនោះ។ ហើយរួចមកគេ ក៏ហៅខ្ញុំអោយត្រឡប់មកវិញ។ ហើយខ្ញុំតែងស្នាក់នៅតាមទន្លេ ជាអ្នកទូកដរម្នាក់ ដូច្នេះខ្ញុំតែងជួយប្រជាជន សង្គ្រោះគេពីទឹកជំនន់។ ហើយខ្ញុំ...ពេលមួយ...

195 ពួកគេហៅខ្ញុំ និយាយ "មានផ្ទះមួយនៅ ឆេសណាត់ ស្ទ្រីត ត្រៀមរួច ហើយថានឹងចូលទៅ។ មានម្ដាយម្នាក់និងកូនៗមួយក្រុមនៅទីនោះ" និយាយ "បើអ្នកគិតថាទូករបស់អ្នក ម៉ាស៊ីនរបស់អ្នកអាចទៅដល់នោះបានទេ។"

ខ្ញុំនិយាយ "ល្អខ្ញុំនឹងធ្វើគ្រប់យ៉ាងដែលអាចធ្វើបាន។"

196 ហើយ ខ្ញុំឆ្លងកាត់រលក។ ទំនប់ទឹកនៅទីនោះកំពុងតែដាច់ ហើយអូ...វាបំផ្លាញក្រុង។ ហើយខ្ញុំប្រឹងអស់កម្លាំងដែលខ្ញុំអាចធ្វើ ទីបំផុតក៏ចូលដល់ ច្រកទៅ កាន់កន្លែងនោះ។ ហើយខ្ញុំទៅជិតកន្លែងដែលទំនប់ទឹក ជាកន្លែងដែលទឹកកំពុងបង្ហូរមក។ រួចខ្ញុំឮមនុស្សស្រែក ហើយខ្ញុំឃើញម្ដាយម្នាក់កំពុងតែឈរនៅ រានហាល។ ហើយមានពួកគេមានដុំរលោងនៅទីនោះ។ ល្អ ខ្ញុំឡើងទៅរបៀបនេះ តាមតែអាចធ្វើបាន ហើយខ្ញុំដើរកាត់ស្ទឹងត្រឡប់មកវិញមកត្រើយម្ខាងទៀត។ ខ្ញុំមានទូកដែលទុកនៅពេលនោះចងជុំវិញសសរ បង្គោល បង្គោលទ្វារានហាល។ ហើយខ្ញុំរត់ទៅនិងចាប់ទាញម្ដាយនោះរួចទាញនាងមកដាក់នៅទីនោះ និងរួមទាំងកូនពី ឬបីនាក់ផង។ រួចខ្ញុំស្រាយទូករួចយកគាត់...ត្រលប់មកវិញ។ ចុះមកនៅទិសខាងក្រោម និងដាក់គាត់នៅតាមឆ្នេរ ប្រហែលចំម្ងាយ១ម៉ាយកន្លះកាត់ តាមក្រុងនោះ រហូតដល់ខ្ញុំយកគាត់ទៅដាក់មាត់ច្រាំង ហើយពេលខ្ញុំទៅដល់ ទីនោះគាត់ក៏ សន្លប់។ រួចគាត់ផ្ដើម...គាត់ផ្ដើមស្រែក "កូនខ្ញុំ! កូនខ្ញុំ!"

197 ល្អខ្ញុំគិតថាគាត់មានន័យថាគាត់បានទុកកូនតូចរបស់គាត់ចោលនៅក្នុងផ្ទះ។ អូ! ខ្ញុំអើយ ខ្ញុំត្រឡប់ទៅម្ដងទៀត កាលមានគេកំពុងមើលថែរគាត់។ ហើយ ខ្ញុំចូល

មករក វា...ឬគាត់ចង់ដឹងថាកូនគាត់នៅឯណានៅទីនោះ។ មានកូនតូច មួយមក តាមអាយុ៣ឆ្នាំ ខ្ញុំគិតថាគាត់មានន័យថាកូនតូចបំបៅឬអ្វីមួយ។

198 ដូច្នេះ ខ្ញុំត្រឡប់ទៅទីនោះវិញ។ ហើយពេលខ្ញុំទៅដល់ទីនោះ ខ្ញុំចូល ទៅក្នុង ហើយមិនឃើញមានកូនតូចអ្វីទេ ហើយរានហាលក៏មិនមាន ចូលក្នុងផ្ទះ ទៀត។ រួចខ្ញុំរត់យ៉ាងលឿនដើម្បីទាញ—បំណែកមួយដែលទូកខ្ញុំកំពុងអណ្តែត ចូលទៅក្នុងទូកហើយ ទាញរបស់នោះនឹងស្រាយវាចេញ។

199 ហើយវាក៏ទាញខ្ញុំចេញចូលចរន្តទឹកទន្លេធំ។ ពេលនោះម៉ោងប្រហែលជា១១កន្លះយប់មានភ្លៀងមានព្រិល។ រួចខ្ញុំចាប់ទាញខ្សែរបញ្ឆេះហើយព្យាយាម ទាញ ទូកហើយវាមិនឆេះ ហើយខ្ញុំព្យាយាមទៀត វាមិនឆេះ ហើយខ្ញុំព្យាយាមទៀត។ កាន់តែធ្វើទៀតវាក៏ធ្លាក់ចុះមក។ ហើយខ្ញុំព្យាយាមប្រឹងហើយ ខ្ញុំគិតថា "អូ ខ្ញុំអើយ នេះ—ខ្ញុំចប់ហើយ! វាដូចនេះ!" ហើយខ្ញុំប្រឹងយ៉ាងខ្លាំង។ ហើយខ្ញុំនិយាយថា "ព្រះជាម្ចាស់ សូមកុំឱ្យខ្ញុំស្លាប់ដូច្នេះ" ហើយខ្ញុំទាញ ទាញ ទាញ។

200 ហើយវាចូលមកខ្ញុំ "ចុះពំនូកសម្រាម ដែលនៅទីនោះ?" ឃើញទេ? អូហូ។

201 ខ្ញុំដាក់ដៃខ្ញុំនៅលើទូក ហើយខ្ញុំនិយាយ "ឱព្រះអើយសូមមេត្តាដល់ទូលបង្គំ។ កុំឱ្យខ្ញុំចាកចេញពីប្រពន្ធនិង កូន របស់ខ្ញុំដូចនេះ ហើយមេត្តា! សូម បញ្ចៀសជំងឺ ពួកគេ!" ហើយខ្ញុំបន្តទាញវា ហើយវានៅតែមិនឆេះ។ ហើយខ្ញុំអាច ឮសម្លេងគ្រហឹម នៅទីនោះ ព្រោះខ្ញុំ...ប៉ុន្មាននាទីហើយ អូ ប្រហែលវាហើយ។ ហើយខ្ញុំ និយាយ "ព្រះអម្ចាស់ បើទ្រង់អត់ទោសឱ្យទូលបង្គំ ទូលបង្គំ នឹងធ្វើអ្វីៗទាំងអស់។" លត់ជង្គង់នៅទីនោះ ហើយភ្លៀងលាយព្រិលបាន វាយមុខរបស់ខ្ញុំ។ ខ្ញុំនិយាយ "ទូលបង្គំនឹងធ្វើអ្វីៗដែលទ្រង់សព្វព្រះទ័យអោយ ទូលបង្គំធ្វើ។" រួចខ្ញុំទាញម្តងទៀត រួចវាក៏ឆេះ។ រួចខ្ញុំដកដង្ហើមចូលតាមតែអាចធ្វើ បាន ហើយទីបំផុតខ្ញុំមកដល់មាត់ឆ្នេរ។

202 រួចខ្ញុំត្រឡប់មកវិញស្វែងរកឡាន ឡានយាមល្បាត។ រួចខ្ញុំគិតពី...មានអ្នកខ្លះនិយាយថា "និយាយថា រដ្ឋាភិបាលទើបតែបានប្រមូលសំអាត។" ប្រពន្ធ និង កូនខ្ញុំនៅក្នុងនោះ កូនទាំងពីរ។

203 ហើយខ្ញុំចេញទៅរកក្រុមរដ្ឋាភិបាល តាមតែអាចធ្វើទៅបាន ហើយទឹកមានជម្រៅ១៥ហ្វីតជុំវិញ។ ហើយមានវីរៈសេនីត្រីនៅទីនោះ ហើយខ្ញុំនិយាយ "លោកវីរៈសនីត្រីមានរឿងអ្វីកើតឡើងនៅមន្ទីរពេទ្យ?"

និយាយ "ឥឡូវកុំបារម្ភ។ អ្នកមាន នរណាម្នាក់នៅទីនោះទេ?"

ខ្ញុំនិយាយ "បាទ—ប្រពន្ធមានជំងឺនិងកូនតូចពីរនាក់។"

204 គាត់និយាយ "ពួកគេទាំងអស់ត្រូវបានយកចេញហើយ។" និយាយ "ពួកគេនៅក្នុងរថយន្តដឹកជញ្ជូន និងកំពុងឆ្ពោះទៅ ឆាលេសថោន។"

205 ខ្ញុំរត់ទៅឡើងទូករបស់ខ្ញុំ...ឬឡើងឡាន ទូកនៅក្រោយនោះ រួចរត់ទៅ...មានព្រែកតូចចូលកាត់ទំហំ ប្រហែលពីរកន្លះទៅបីម៉ាយ។ ហើយពេញមួយយប់ ខ្ញុំព្យាយាម...មានអ្នកខ្លះនិយាយថា "រថយន្ត រថយន្តដឹកទំនិញត្រូវបានខូច នៅលើ ជើងគ្រោងខាងក្រៅ។"

206 ល្មមឃើញថាខ្លួនខ្ញុំដូចត្រូវគេបោះបង់ចោលក្នុងកោះតូចមួយនៅទីនោះបីថ្ងៃ។ ខ្ញុំមានពេលគ្រប់គ្រាន់ដើម្បីគិតថា តើនោះជាសម្រាមមែនឬក៏មិនមែន។ គ្រាន់តែទទួលរង "ប្រពន្ធខ្ញុំនៅឯណា?"

207 ទីបំផុត ពេលដែលខ្ញុំបានរកនាងឃើញ គឺប៉ុន្មានថ្ងៃបន្ទាប់ ខ្ញុំបានឆ្លងទន្លេ នោះ នាងបានទៅកូឡំប៊ីស អិនឌៀអាយណា នៅសាលប្រជុំបាបទីស្ទ ដែល ពួកគេបានធ្វើ—មន្ទីរពេទ្យបែបនោះ បន្ទប់អ្នកជំងឺនៅខ្ទមប្រក់ស្លឹករបស់រដ្ឋាភិបាល។ ហើយខ្ញុំរត់ទៅរកនាងយ៉ាងលឿន តាមតែអាចធ្វើទៅបាន ព្យាយាមស្វែងរកថានាងនៅទីណា ស្រែក "ហូប! ហូប! ហូប!" រួចខ្ញុំស្វែងរក នាងកំពុងតែដេកលើគ្រែតូចមួយ ដែលជាកន្លែងជំងឺរបេង។

នាងលើកដៃស្គមឆ្អឹងរបស់នាង រួចនិយាយ "ប៊ីលលី។"

ហើយខ្ញុំរត់ទៅរកនាង រួចនិយាយ "ហូប អូនសម្លាញ់។"

នាងនិយាយ "ខ្ញុំមើលទៅគួរអោយពិបាកណាស់មែនទេ?"

ខ្ញុំនិយាយ "ទេ អូនសម្លាញ់ អ្នកមើលទៅមិនអីទេ។"

208 ប្រហែលជា៦ខែ យើងបានធ្វើការនូវរាល់អ្វីយើងមានក្នុងខ្លួន ដើម្បី ព្យាយាមសង្គ្រោះជីវិតរបស់នាង ប៉ុន្តែនាងនៅប្រែកាន់តែខ្សោយទៅៗ។

209 ថ្ងៃមួយខ្ញុំកំពុងនៅយាមល្បាត ហើយខ្ញុំឮវិទ្យុបើកឡើង ហើយខ្ញុំគិតថា ខ្ញុំបានឮគេផ្សាយ ការហៅតាមវិទ្យុនិយាយ "ជូន វិល្លៀមប្រាណហាំត្រូវទៅមន្ទីរពេទ្យភ្លាម ប្រពន្ធកំពុងតែជិតស្លាប់។" ខ្ញុំរត់ទៅកាន់មន្ទីរពេទ្យយ៉ាងលឿនតាមតែ អាចធ្វើទៅបាន បើកភ្លើងពណ៌ក្រហមនិងពាទ័សារ៉ែន ហើយចេញទៅ។

ហើយ ខ្ញុំ—ខ្ញុំទៅដល់មន្ទីរពេទ្យរួចក៏ឈប់ រត់ចូលក្នុង។ ចូលទៅក្នុង—មន្ទីរពេទ្យ ខ្ញុំឃើញ មិត្ត ជាទីស្រឡាញ់របស់ខ្ញុំដែលធ្លាប់ទៅ ស្ទូចត្រីជាមួយគ្នាយើងរត់លេង ជាមួយ គ្នា កាលនៅជាក្មេងប្រុសៗ គឺ សេម អាឌៀ។

210 ដុកទ័រ សេមអាឌៀ គាត់ជាមនុស្សម្នាក់ដែលនិមិត្តបានចេញមកមិន យូរប៉ុន្មាន ហើយប្រាប់គាត់អំពីគ្លីនិក។ រួចគាត់និយាយ បើអ្នកណាសង្ស័យពីនិមិត្ត ចូរទៅរកគាត់ប្រមូលយកចុះ បើអ្នកចង់ដឹងថាវាពិតឬក៏អត់។

211 ហើយដូច្នេះគាត់ចេញមករបៀបនេះ គាត់កាន់មួកក្នុងដៃ។ គាត់សម្លឹង មក ខ្ញុំហើយបានត្រឹមតែយំ។ ហើយខ្ញុំរត់ទៅរកគាត់បោះដៃអោបគាត់។ គាត់ដាក់ដៃ អោបខ្ញុំ និយាយ "ប៊ីលលី នាងទៅហើយ។" គាត់និយាយ "ខ្ញុំសូមទោស។ ខ្ញុំបាន ប្រឹងអស់ពីសមត្ថភាពហើយ ខ្ញុំមានអ្នកឯកទេសនិងគ្រប់យ៉ាង។"

ខ្ញុំនិយាយ "សេម ពិតណាស់ នាងនឹងមិនចេញទៅឡើយ!"

និយាយ "បាទនាង ចេញទៅហើយ។" រួចគាត់និយាយ "កុំចូលទៅក្នុងប៊ីល។"

ហើយ ខ្ញុំនិយាយ "ខ្ញុំត្រូវចូល ទៅ សេម។"

រួចគាត់និយាយ "កុំធ្វើអញ្ចឹង កុំ សូមកុំ។"

ខ្ញុំនិយាយ "ឱ្យខ្ញុំចូលទៅ។"

និយាយ "ខ្ញុំនឹងទៅជាមួយអ្នក។"

212 ខ្ញុំនិយាយ "ទេ អ្នកនៅខាងក្រៅនេះហើយ។ ខ្ញុំចង់នៅជាមួយនាងនៅនាទី ចុងក្រោយ។"

និយាយ "នាងមិនដឹងខ្លួនទេ។"

213 ខ្ញុំដើរចូលក្នុងបន្ទប់។ ហើយពេទ្យនៅទីនោះ នាងកំពុងតែយំ ព្រោះនាងនិង ហូបជាមិត្តរួមថ្នាក់ទាំងអស់គ្នា។ ដូច្នេះខ្ញុំមើលឃើញទាំងអស់ រួច នាងចាប់យំដែរ លើកដៃឡើង។ ហើយចាប់ផ្ដើមដើរចេញ។

214 ហើយខ្ញុំចូលមើល អង្រួននាង។ នាងមាន នាងបានស្រកទម្ងន់ពី១២០ផោន មកត្រឹម៦០ផោន។ ហើយខ្ញុំ—ខ្ញុំអង្រួននាង។ ហើយបើខ្ញុំរស់នៅ១០០ឆ្នាំ ខ្ញុំភ្លេច អ្វី ដែលកើតឡើងនោះទេ។ នាងបែរមក ហើយភ្នែកដែលស្អាតសម្លឹងមើលមកខ្ញុំ។ នាងញញឹម។ នាងនិយាយ "ហេតុអ្វីអ្នកហៅខ្ញុំមកវិញ ប៊ីលលី?"

ខ្ញុំនិយាយ "អូន សម្លាញ់ បងទើបទទួលបានលុយ..."

215 ខ្ញុំត្រូវធ្វើការ។ យើងកំពុងតែជំពាក់បំណុល និងមានវិក័យបត្រត្រូវសង ១០០ដុល្លារ ហើយយើងមិនមានលុយទៀយ។ ដូច្នេះខ្ញុំត្រូវទៅធ្វើការ។ ហើយខ្ញុំបានទៅមើលនាងពីរទៅបីដងក្នុងមួយថ្ងៃនិងរាល់យប់ ហើយនាងនៅស្ថានភាពនោះ។

ខ្ញុំនិយាយ "តើអ្នកមានន័យយ៉ាងម៉េច 'ហៅ' អ្នក 'ត្រឡប់'?"

216 នាងនិយាយ "ប៊ីលបងបានអធិប្បាយពីសេចក្ដីនោះបងនិយាយពីវា តែបងមិនមានគំនិតអំពីវា។"

ខ្ញុំនិយាយ "តើអ្នកកំពុងនិយាយអំពីអ្វី?"

217 នាងនិយាយ "ស្ថានសួគ៌។" នាងនិយាយ "មើល" នាងនិយាយ "ខ្ញុំត្រូវបានហែរជូនត្រឡប់ទៅផ្ទះដោយមនុស្សមួយចំនួន មនុស្សប្រុស ឬស្រីឬអ្វី។ ពួកគេស្លៀកពាក់ពណ៌ស។" ហើយនាងនិយាយ "ខ្ញុំកំពុងនៅក្នុងភាពសុខស្រួល និងសុខសាន្ត។" និយាយ "បក្សីធំៗ ហើរពីដើមឈើមួយទៅដើមឈើមួយ។" នាងនិយាយ "មិនគិតថាខ្ញុំនៅក្នុងខ្លួនខ្ញុំឡើយ។" នាងនិយាយ "ប៊ីលលី ខ្ញុំនឹងប្រាប់អ្នកពីកំហុសរបស់ពួកយើង។" នាងនិយាយ "អង្គុយចុះមក។ ខ្ញុំមិនអង្គុយលត់ ជង្គង់ចាប់ដៃនាងទេ។" នាងនិយាយ "អ្នកដឹងទេថា នៅឯណាកំហុសរបស់ ពួកយើង?"

ហើយខ្ញុំនិយាយ "បាទ អូនសម្លាញ់ បងដឹង។"

218 នាងនិយាយ "យើងមិនគួរស្ដាប់អ្នកម៉ែឡើយ។ ពួកមនុស្សទាំងនោះ ពិតជាត្រឹមត្រូវ។"

រួចខ្ញុំនិយាយ "បងដឹង។"

219 នាងនិយាយ "សន្យានឹងអូនរឿងនេះ បងនឹងទៅរកពួកគេទាំងនោះ" និយាយ "ពួកគេជាមនុស្សត្រឹមត្រូវ។" ហើយនិយាយ "ចូរចិញ្ចឹមកូនរបស់ខ្ញុំ តាមរបៀបនោះ។" ហើយ ខ្ញុំ...នាងនិយាយ "អូនចង់ប្រាប់បងរឿងខ្លះ។" នាងនិយាយ "ខ្ញុំនឹងស្លាប់ ប៉ុន្តែ" និយាយ "វាគឺជា...ខ្ញុំមិន—ខ្ញុំមិនមែនទៅឈឺចាប់ទេ។" និយាយ "វា—វាគឺស្រស់ស្អាតណាស់។" នាងនិយាយ "ជាអ្វីតែមួយ ខ្ញុំមិនចង់ចាកចេញពីអ្នក ប៊ីល។ ហើយបងមានកូនពីរនាក់ត្រូវចិញ្ចឹម។" នាងនិយាយ "សន្យានឹងអូនថា

—ថាបងមិននៅពោះម៉ាយ និងទុកអោយកូនរបស់អូនត្រូវទាញចេញពី សសរទៅបង្គោល ឡើយ។៉ នោះជាអ្វីដែលជាគំនិតរបស់ម្ដាយអាយុ២១ឆ្នាំ។

ហើយខ្ញុំនិយាយ ៉ខ្ញុំមិនអាចសន្យាបែបនោះឡើយ ហូប។៉

220 នាងនិយាយ ៉សូមសន្យាជាមួយអូន។៉ និយាយ ៉រឿងមួយដែលអូនចង់ប្រាប់បង៉ និយាយ ៉បងចាំពីរកាំភ្លើងរ៉ាវហ្វលទេ?៉ ខ្ញុំកំពុងតែរក់រីជាមួយ កាំភ្លើងនោះ។ ហើយនាងនិយាយ ៉បងចង់ទិញកាំភ្លើងនៅថ្ងៃនោះ ហើយបងមិន មាន លុយគ្រប់គ្រាន់ដើម្បីចំណាយ។៉

ខ្ញុំនិយាយ ៉បាទ។៉

221 នាងនិយាយ ៉អូនបានសន្សំលុយអូន លុយនីកកែលរបស់អូន ដើម្បី បន្ថយការចំនាយលើកាំភ្លើងរ៉ាវហ្វលសម្រាប់បង។៉ នាងនិយាយ ៉ឥឡូវពេលរឿងនេះបានចប់ទៅ ហើយបងត្រឡប់ទៅផ្ទះវិញរបស់បត់...ឬគ្រែបត់នៅក្រោម ចម្រៀកក្រដាសដាក់នៅពីលើ បងនឹងឃើញលុយនៅទីនោះ។៉ នាងនិយាយ ៉សន្យានឹងអូនថា បងនឹងទិញកាំភ្លើង រ៉ាវហ្វល។៉

222 អ្នកមិនដឹងពីអារម្មណ៍របស់ខ្ញុំមាន ជាយ៉ាងណាពេកខ្ញុំបានឃើញលុយដុល្លារ៧៥សេន(ជានីកកែល)នៅកន្លែងនោះទេ។ ខ្ញុំក៏មានរ៉ាវហ្វល។

223 ហើយនាងនិយាយ ៉បងចាំទេថាពេលមួយ បងទៅក្រុង ដើម្បីទិញស្រោមជើងវែងអោយអូន ហើយយើងទៅ ហ្វតវ៉ាយ?៉

ខ្ញុំនិយាយ ៉បាទ។៉

224 ខ្ញុំមកពីស្ទូចត្រី ហើយនាងនិយាយ...យើងត្រូវទៅ ហ្វតវ៉ាយ ខ្ញុំត្រូវទៅអធិប្បាយនៅយប់នោះ។ ហើយនាងនិយាយ ៉បងដឹងទេ ខ្ញុំប្រាប់បង 'មានពីរប្រភេទ។'៉ មួយហៅថា ៉ឈីហ្វុន។៉ និងមួយទៀតគឺអ្វី រ៉ាយយ៉ុន? ត្រូវទេ? រ៉ាយយ៉ុន និងឈីហ្វុន។ ល្អ មួយណាក៏ដោយ ឈីហ្វុនគឺល្អបំផុត។ ត្រូវទេ? ហើយនាងនិយាយ ៉ឥឡូវ អ្នកទៅទិញឈីហ្វុនអោយខ្ញុំមក ម៉ូដពេញ។៉ អ្នកដឹងទេថារបស់ដែលមានអ្វីបន្តិចនៅពីក្រោយស្រោមជើងវែង នៅខាងលើ? ហើយខ្ញុំ មិនស្គាល់អ្វីអំពីសម្លៀកបំពាក់ស្រីឡើយ ដូច្នេះខ្ញុំ...

225 ហើយខ្ញុំទៅតាមផ្លូវ ហើយនិយាយ ៉ឈីហ្វុន ឈីហ្វុន ឈីហ្វុន ឈីហ្វុន៉ ព្យាយាមគិតពីវា ៉ឈីហ្វុន ឈីហ្វុន ឈីហ្វុន។៉

មានអ្នកនិយាយ "សួស្តី ប៊ីលលី!"

226 ខ្ញុំនិយាយថា "អូ សួស្តី សួស្តី។" "ឈីហ្វុន ឈីហ្វុន ឈីហ្វុន ឈីហ្វុន។"

227 ហើយខ្ញុំទៅកាច់ជ្រុងហើយជួបលោក ស្បុន។ លោកនិយាយ "ហេ ប៊ីលលី អ្នកដឹងទេថា បង្គងត្រូវបានគេវាយនៅផ្នែកម្ខាងទៀតទេ?"

ខ្ញុំនិយាយ "ពិត ណាស់ ត្រូវហើយ?"

"យេ។"

ខ្ញុំគិតថាឥឡូវ ពេលខ្ញុំចេញពីគាត់ "របស់នោះជាអ្វី?" ខ្ញុំ ភ្លេចវា។

228 ដូច្នេះ ថេល ម៉ា ហ្វដ ជាក្មេងស្រីដែលខ្ញុំស្គាល់ ធ្វើការនៅហាង ដប់-សេន។ ហើយខ្ញុំដឹងថាពួកគេលក់ស្រោមជើង របស់ស្ត្រីនោះទីនោះ។ ដូច្នេះខ្ញុំ ទៅ។ និយាយ "សួស្តី ថេលម៉ា។"

ហើយនាងនិយាយ "សួស្តីប៊ីលលី។ តើអ្នកសុខ សប្បាយជាទេ? ចុះហូប វិញ?"

229 ហើយខ្ញុំនិយាយ "សុខ។" ខ្ញុំនិយាយ "ថេលម៉ាខ្ញុំត្រូវការស្រោមជើង ពីរ អោយ ហូប។"

នាងនិយាយ "ហូបមិនត្រូវការស្រោមជើងទេ។"

ខ្ញុំនិយាយ "បាទ នាងត្រូវការ។"

និយាយ "អ្នកចង់និយាយពី ស្រោមជើងវែង។"

230 "អូ ពិតណាស់" ខ្ញុំនិយាយ "នោះគឺវាហើយ។" ខ្ញុំគិត "អូ ហូខ្ញុំធ្វើជាមិន ដឹងអ្វី។"

ហើយនាងនិយាយ "តើនាងត្រូវការប្រភេទណា?"

ខ្ញុំគិត "អូ ហូ!" ខ្ញុំនិយាយ "អ្នកមានប្រភេទអ្វី?"

នាងនិយាយ "ល្អ ខ្ញុំមាន រ៉ាយ៉ុន។"

231 ខ្ញុំមិនស្គាល់ពីភាពខុសគ្នាទេ។ រ៉ាយយ៉ុន ឈីហ្វុន ទាំងអស់សូរស្រដៀងគ្នា។ ខ្ញុំនិយាយ "ខ្ញុំចង់បានវានោះហើយ។" នាងនិយាយ...ខ្ញុំនិយាយ "ខ្ចប់មួយគូអោយ ខ្ញុំ ម៉ូដពេញ។" ហើយនាង...ខ្ញុំយល់ខុស។ វាជាអ្វីទៅ? ម៉ូដ ពេញ។ "ម៉ូដ ពេញ។" ហើយដូច្នេះខ្ញុំនិយាយ "ខ្ចប់អោយខ្ញុំមួយគូមក។"

232 ហើយពេលនាងអោយវាមកខ្ញុំ ពួកវាតម្លៃប្រហែល៣០សេន តម្លៃពាក់កណ្តាល។ ល្អ ខ្ញុំនិយាយ "អោយខ្ញុំពីរគូមក។" ឃើញទេ?

233 ហើយត្រឡប់មកផ្ទះវិញ ហើយខ្ញុំនិយាយ "អូនដឹងទេ អូន អូនជាស្រីដើរ ទិញពេញក្រុងទៅដើម្បីតថ្លៃ។" អ្នកដឹងទេថា ពេលអ្នកចូលចិត្តធ្វើជាសត្វក្អែក។ ហើយខ្ញុំនិយាយ "ប៉ុន្តែនៅទីនេះ មើលនេះបងបានទិញ២គូក្នុងតម្លៃតែមួយដែល អូនបានទិញ។ ឃើញ?" ខ្ញុំនិយាយ "អូនោះ នោះជាសម្ថភាពផ្ទាល់ខ្លួនរបស់បង" ឃើញ ខ្ញុំនិយាយ—ខ្ញុំនិយាយ "អូនដឹងទេ ថេលម៉ាលក់អោយបងអញ្ចឹង" ខ្ញុំ និយាយ "នាងអោយបងទិញតម្លៃតែពាក់កណ្តាលប៉ុណ្ណោះ។"

នាងនិយាយ "តើបង យកឈើហ្មុនទេ?"

234 ខ្ញុំនិយាយ"បាទ។" វាមានសូរដូចគ្នាសម្រាប់ខ្ញុំ ខ្ញុំមិនដឹងថាវាខុសគ្នា ឡើយ។

235 ហើយនាងប្រាប់ខ្ញុំ នាងនិយាយ "ប៊ីលលី។" ខ្ញុំគិតថាចម្លែកណាស់ពេល នាងទៅ ហ្វតវ៉ាយ នាងត្រូវតែយកគូផ្សេងទៀត។ នាងនិយាយ "ខ្ញុំនឹងអោយវាទៅ ម្តាយរបស់បង" និយាយ "ពួកវាសម្រាប់ស្ត្រីមានវ័យច្រើន" និយាយ "ខ្ញុំសូមទោស ដែលធ្វើអញ្ចឹង។"

ហើយខ្ញុំនិយាយ "អូ មិនអីទេ អូន។"

236 ហើយនាងនិយាយ "ឥឡូវ កុំ—កុំរស់នៅម្នាក់ឯង។" ហើយនាងនិយាយ និយាយ...នាងមិនដឹងថាអ្វីនឹងកើតឡើងនៅបីបួនម៉ោងទៀតឡើយ។ ដូច្នេះខ្ញុំកាន់ដៃជាទីស្រឡាញ់របស់នាងពេលទេវតារបស់ព្រះជាម្ចាស់កំពុងយកនាងទៅ។

237 ខ្ញុំទៅផ្ទះ។ ខ្ញុំមិនដឹងថាត្រូវធ្វើអ្វីឡើយ។ ខ្ញុំដេកនៅទីនោះពេលយប់ ហើយក៏ឮ...ខ្ញុំគិតថាវាជាសត្វកណ្តុរ នៅដែកប្រទាសចាស់ កាលយើងមាន ក្រដាសខ្លះនៅទីនោះ។ ហើយខ្ញុំបិទទ្វាដោយប្រើជើង នៅទីនោះនាងបានព្យួរអាវ គីមុណុរបស់នាងនៅខាងក្រោយ (ក៏ដាក់នៅទីនោះជាកន្លែងដាក់សព)។ ហើយនៅ បន្តិចមកមានអ្នកហៅខ្ញុំ និយាយ "ប៊ីលលី!" ហើយនោះជាបងប្រុស ហ្វ្រេងប្រូយ។ គាត់និយាយ "កូនរបស់អ្នកកំពុងតែជិតស្លាប់។"

ខ្ញុំនិយាយ "កូនខ្ញុំ?"

238 និយាយ "បាទ សារ៉ុនរ៉ូស។" និយាយ "ដុកទ័រនៅទីនោះ ហើយនិយាយថា 'នាងឈឺរបេងរលាកស្រោមខួរនាងត្រូវគេដាក់មើលថៃឆ្ងាយពីម្តាយនាងហើយ។'"ហើយនិយាយថា "នាងកំពុងតែជិតស្លាប់។"

239 ខ្ញុំឡើងរថយន្តទៅទីនោះ។ ហើយនាងនៅទីនោះគឺជាក្មេងតូចគួរឲ្យស្រឡាញ់មួយ។ ហើយពួកគេនាំនាងប្រញាប់ទៅមន្ទីរពេទ្យ។

240 ខ្ញុំចេញទៅមើលគាត់។ សេមចេញមករួចនិយាយ "ប៊ីលលីកុំចូលទៅក្នុងបន្ទប់នោះ អ្នកត្រូវតែគិតពី ប៊ីលលី ប៉ុល។" និយាយ "នាងកំពុងតែជិតស្លាប់។"

ខ្ញុំនិយាយ "ដុកទ័រ ខ្ញុំ—ខ្ញុំត្រូវទៅមើលកូនរបស់ខ្ញុំ។"

241 គាត់និយាយ "ទេ អ្នកមិនអាចទៅបានទេ។" និយាយ "នាងមានជំងឺរលាកស្រោមខួរ ប៊ីលលី ហើយអ្នកនឹងនាំឆ្លងដល់ប៊ីលលីប៉ុល។"

242 ហើយខ្ញុំរង់ចាំរហូតដល់គាត់ចេញមកក្រៅ។ ខ្ញុំមិនអាចឈរមើលនាងស្លាប់បានឡើយ ហើយម្តាយរបស់នាងកំពុងដេកនៅទីនោះក្នុងកន្លែងអ្នករៀបចំសព។ ខ្ញុំសូមប្រាប់អ្នកថាការប្រព្រឹត្តរំលងនោះលំបាកណាស់។ ហើយខ្ញុំ—ខ្ញុំចេញទៅរអិលនៅមាត់ទ្វា ហើយពេលសេមចេញទៅ ហើយគិលានុបដ្ឋាកយិកាចេញទៅខ្ញុំចុះទៅបន្ទប់ក្រោមដី។ វាជាមន្ទីរពេទ្យតូចបន្តិច។ នាងនៅកន្លែងដែលដាច់ ស្រយាល ហើយរុយនៅក្នុងភ្នែកតូចៗរបស់នាង។ ហើយពួកគេមាន តូច...យើងហៅថាអ្វី "វនាំង មូស" សំនាញ់តូចគ្រប់ភ្នែកតូចៗរបស់នាង។ ហើយ នាង...មានការកន្ទ្រាក់សាច់ដុំតិចៗ ជើងធាត់តូចរបស់នាងកម្រើកឡើងចុះដូចនេះ និងដៃតូចរបស់នាងក៏កន្ទ្រាក់សាច់ដុំដែរ។ ហើយខ្ញុំសម្លឹងមើលទៅនាង ហើយនាងធំ ល្មមអោយមានភាពស្អាត ប្រមាណអាយុ៨ខែ។

243 ហើយម្តាយរបស់នាងធ្លាប់ដាក់នាងក្រៅជាមួយ ប្រដាប់បីជ្រុងរបស់នាង អ្នកស្គាល់ហើយ នៅក្នុងសួនចំការ ពេលខ្ញុំចេញមក។ ហើយខ្ញុំផ្លុំស្នែង រួចនាង "ហ្គូ-ហ្គូ ហ្គូ-ហ្គូ" ទោមករកខ្ញុំអ្នកដឹងហើយ។

244 ហើយនៅទីនោះ អ្នកជាទីស្រឡាញ់របស់ខ្ញុំកំពុងតែស្លាប់។ ខ្ញុំសម្លឹង មើលទៅនាង ហើយខ្ញុំនិយាយ "សារី កូនស្គាល់ពុកទេ? កូនស្គាល់ពុកទេ សារី?" ហើយពេលនាងសម្លឹងមើល...នាងកំពុងឈឺចាប់ខ្លាំងណាស់ រហូតដល់ភ្នែកខៀវ ស្អាត

តូចរបស់នាងបានបិទខ្ទៃងទៅហើយ។ វាហាក់ដូចជាការហែកបេះដូងខ្ញុំមក ក្រៅដែរ។

245 ខ្ញុំលុតជង្គង់ចុះ ខ្ញុំនិយាយ "ព្រះអម្ចាស់ តើទូលបង្គំបានធ្វើអ្វី? តើទូលបង្គំមិនបានអធិប្បាយដំណឹងល្អនៅផ្លូវកាច់ជ្រុងទេវី? ទូលបង្គំបានធ្វើអ្វី ដែលទូលបង្គំចេះធ្វើ។ សូមកុំយកវាមកទាស់នឹងទូលបង្គំឡើយ។ ទូលបង្គំមិន បានហៅគេថាជាមនុស្ស 'សម្រាម។' ឡើយ គឺជាគាត់ដែលហៅពួកគេថាជា 'សម្រាម។'" ខ្ញុំនិយាយ "ទូលបង្គំសូមទោសអ្វីទាំងអស់ដែលកើតឡើង។ សូមអត់ ទោសអោយទូលបង្គំផង។ កុំ—កុំយកកូនរបស់ទូលបង្គំឡើយ។" ហើយពេលខ្ញុំកំពុង អធិស្ឋានមើលទៅដូចជា ខ្មៅ...ដូចជាក្រណាត់ឬខោអាវធ្លាក់មកខ្ញុំដឹងថាទ្រង់បានបដិសេធដល់ខ្ញុំ។

246 ឥឡូវ មានការលំបាកណាស់និងពេលវេលាដ៏ពិបាកនៃជីវិត។ ពេលខ្ញុំងើបឡើងសម្លឹងមើលនាង ហើយខ្ញុំគិត...សាតាំងបានដាក់ក្នុងគំនិតរបស់ ខ្ញុំ "ល្អអ្នកមានន័យថាអ្នកខំអធិប្បាយ និងរបៀបដែលអ្នករស់នៅ និងឥឡូវវា បានចូលមកកូនរបស់អ្នក ទ្រង់បានទំលាក់អ្នកចុះ?"

247 ហើយខ្ញុំនិយាយ "នោះត្រឹមត្រូវណាស់។ បើទ្រង់មិនអាចសង្គ្រោះកូន របស់ខ្ញុំដូច្នេះ ខ្ញុំក៏មិនអាចដែរ..." ខ្ញុំឈប់។ ខ្ញុំ—ខ្ញុំមិនដឹងថាត្រូវធ្វើអ្វីឡើយ។ ហើយ ខ្ញុំនិយាយបែបនេះ ខ្ញុំនិយាយ "ព្រះអម្ចាស់ ទ្រង់ប្រទាននាងមកទូលបង្គំ រួចទ្រង់យកនាងទៅវិញ ចូរអោយព្រះនាមទ្រង់ប្រកបដោយព្រះពរ! បើទ្រង់យកទូលបង្គំទៅទៀត ទូលបង្គំនៅតែស្រឡាញ់ទ្រង់។"

248 ហើយខ្ញុំដាក់ដៃរបស់ខ្ញុំលើនាង ខ្ញុំនិយាយ "សូមព្រះប្រទានពរដល់អ្នកកូនសម្លាញ់ពុកចង់ប្រោសអ្នកឡើងវិញចេញអស់ពីចិត្តពុកគឺពុកចង់ប្រោសអ្នកអោយ រស់វិញ ហើយចិញ្ចឹមកូនអោយស្រឡាញ់ដល់ព្រះអម្ចាស់។ ប៉ុន្តែទេវតាបានមកព្រោះអ្នកហើយ កូនជាទីស្រឡាញ់។ ពុកនឹងយករាងកាយតូចរបស់កូនដាក់ចុះទៅក្នុងដៃម្តាយរបស់កូន។ ពុកនឹងកប់កូនជាមួយគាត់។ ថ្ងៃណាមួយពុកនឹងជួបអ្នក អ្នកចាំពុកនៅទីនោះជាមួយម៉ែចុះ។"

249 ពេលម្តាយរបស់នាងកំពុងតែជិតស្លាប់គាត់ និយាយ ពាក្យចុងក្រោយគាត់និយាយ គាត់និយាយថា "ប៊ីល ចូរនៅក្នុងទីលានចុះ។"

250 ខ្ញុំនិយាយ "ខ្ញុំនឹង..." នាងនិយាយ...ខ្ញុំនិយាយ "បើខ្ញុំនៅក្នុងទីលាន ពេលដែលទ្រង់យាងមក ខ្ញុំនឹងទទួលបានកូនៗនិងជួបគ្នាដែរ។ បើខ្ញុំមិនធ្វើ។ ខ្ញុំនឹងត្រូវបានកប់ដោយអ្នក។ ហើយអ្នកនឹងចេញទៅខាងស្តាំដៃនៃក្លោងទ្វាធំ ហើយជាពេលអ្នកឃើញគ្រប់គ្នាចូលមក ឈរទីនោះហើយចាប់ផ្តើម ស្រែក 'ប៊ីល! ប៊ីល! ប៊ីល!' ឮខ្លាំងតាមតែអ្នកអាចធ្វើបាន។ ពុកនឹងជួបកូននៅទីនោះ។" ខ្ញុំថើបនាងនិងលាចេញ។ ខ្ញុំកំពុងតែនៅសមរភូមិនៅថ្ងៃនេះ។ គឺជិត២០ឆ្នាំកន្លង ទៅហើយ។ ខ្ញុំបានណាត់ជួបប្រពន្ធខ្ញុំ ខ្ញុំនឹងទៅជួបនាង។

251 ហើយខ្ញុំយកកូនតូច ពេលនាងស្លាប់ ហើយដាក់នាងក្នុងដៃរបស់ម្តាយនាង ហើយយើងយកទៅទីស្មសាន។ ហើយខ្ញុំឈរនៅទីនោះដើម្បីស្តាប់បងប្រុស ស្មីតដែលជាអ្នកអធិប្បាយនៅមេតូឌីសបានអធិប្បាយនៅពិធីបុណ្យសព "ផេះទល់នឹងផេះ ធូលីទល់នឹងធូលី។" (ហើយខ្ញុំគិត "ចិត្តទល់នឹងចិត្ត។") នេះជាអ្វី នាងចេញទៅ។

252 មិនយូប៉ុន្មានពីនោះមក ខ្ញុំបានយកប៊ីលលីតូចទៅជាមួយខ្ញុំ នៅព្រឹក មួយ។ ហើយគាត់គ្រាន់តែជាសហាមិត្តតូចមួយប៉ុណ្ណោះ។ គាត់គឺ...

253 នោះជាហេតុផលដែលគាត់នៅជាប់ជាមួយខ្ញុំហើយខ្ញុំនៅជាប់ជាមួយគាត់ ខ្ញុំត្រូវធ្វើទាំងពីរមុខគឺជាពុកនិងជាម្តាយ (ទាំងពីរ) ចំពោះ គាត់។ ខ្ញុំយកដបតូចរបស់ខ្ញុំ។ យើងមិនអាចរកភ្លើងបាននៅពេលយប់ដើម្បីរក្សាទឹកដោះគោរបស់គាត់អោយក្តៅឡើយ ហើយខ្ញុំដាក់វាលើខ្នងរបស់ខ្ញុំ ដូចនេះ ដើម្បីរក្សាវាអោយនៅក្តៅឧណ្ឌៗ ដោយកំដៅរាងកាយរបស់ខ្ញុំ។

254 យើងនៅជាប់ជាមួយគ្នាដូចជាមិត្តភ័ក្ត មានថ្ងៃមួយក្នុងចំនោមថ្ងៃទាំង នោះពេល ខ្ញុំចេញទៅទីលាន ខ្ញុំចង់ហុចពាក្យមួយអោយគាត់ និង និយាយ "បន្តទៅ មុខ ប៊ីលលី។ អ្នកនៅជាមួយវាចុះ។" មានមនុស្សខ្លះឆ្ងល់ថាហេតុអ្វី ខ្ញុំយកគាត់ ទៅជាមួយគ្រប់ពេល។ ខ្ញុំមិនអាចបោះបង់គាត់ចោលបានឡើយ។ ទោះបីគាត់ រៀបការហើយក៏ដោយ ប៉ុន្តែខ្ញុំនៅចងចាំពីអ្វីដែលនាងប្រាប់ដល់ខ្ញុំ "នៅជាមួយ គាត់" ហើយយើងនៅជាប់ជាមួយគ្នាដូចជាមិត្តភ័ក្តអញ្ចឹងដែរ។

255 ខ្ញុំចាំថាពេលដើរនៅជុំវិញទីក្រុង មានដបនៅក្រោមក្លៀករបស់ខ្ញុំ គាត់យំ។ យប់មួយគាត់...យើងកំពុងដើរចេញទៅក្រៅនៅ ចំការខាងក្រោយដែលជាកន្លែងទើបតែ...(ពេលនាងកំណត់ថានឹងបង្កើតគាត់ នាងថ្នាក់ថ្នមខ្លាំងពេក ហើយខ្ញុំ...

ត្រឹមជាក្មេងស្រី អ្នកដឹងហើយ។) ហើយខ្ញុំដើរមកវិញចេញពីដើមសែនចាស់មួយនៅចំការខាងក្រោយ។ ហើយគាត់ស្រែកយំសួររកម្តាយ ហើយខ្ញុំមិនមានម្តាយអោយគាត់ឡើយ។ ខ្ញុំទះលួងគាត់តិចៗខ្ញុំនិយាយ "អូកូនសម្លាញ់។" ខ្ញុំនិយាយ...

256 គាត់និយាយ "ពុក ម៉ែនៅឯណា? តើពុកដាក់គាត់នៅក្នុងដីនោះហើយមែនទេ?"

ខ្ញុំនិយាយ "ទេ កូន។ គាត់មិនអីទេ គាត់ទៅស្ថានសួគ៌បាត់ហើយ។"

257 ហើយគាត់និយាយអ្វីមួយអំពីនោះ ប្រៀបបីដូចជាសម្លាប់ខ្ញុំដូច្នេះដែរ គឺវេលារសៀលមួយ។ គាត់កំពុងតែយំ នៅល្ងាចមែនទែនហើយ ខ្ញុំកាន់គាត់ដាក់ លើខ្នងបែបនេះ ដាក់គាត់លើស្មា ហើយទះតិចៗបែបនេះ។ រួចគាត់និយាយ "ពុកទៅ យកម៉ែ ហើយនាំគាត់មកទីនេះមក។"

ហើយខ្ញុំនិយាយ "កូនសម្លាញ់ ពុកមិន អាចយកម៉ែមកទេ។ ព្រះយេស៊ូវ..."

និយាយ "ល្អ ប្រាប់ព្រះយេស៊ូវ អោយបញ្ជូន ម៉ែមកខ្ញុំមក។ ខ្ញុំត្រូវការគាត់។"

258 រួចខ្ញុំនិយាយ "ល្អកូនពុក...ខ្ញុំហើយកូននឹងទៅ ឃើញគាត់នៅពេលណាមួយ។"

រួចគាត់ឈប់ ហើយនិយាយ "ពុក!"

ខ្ញុំនិយាយ "បាទ?"

និយាយ "ខ្ញុំឃើញម៉ែឡើងទៅលើនោះនៅក្នុងពពក។"

259 ខ្ញុំ ដូចជាសម្លាប់ខ្ញុំ! ខ្ញុំគិត "ខ្ញុំអើយ! 'ខ្ញុំឃើញម៉ែឡើងទៅលើពពក។'" ខ្ញុំស្ទើរតែសន្លប់។ ខ្ញុំអោបដៃគូតូចដាក់លើទ្រូងដូចនេះ ហើយឈ្ងោកក្បាលចុះ បន្ត ទៅ។

260 ពេលវេលាកន្លងទៅ។ ខ្ញុំមិនអាចភ្លេចបានឡើយ។ ខ្ញុំព្យាយាមធ្វើការនេះ។ មិនអាចទៅផ្ទះ វាមិនមែនជាផ្ទះទៀតទេ។ ហើយខ្ញុំចង់ស្នាក់នៅ។ យើងមិនមានអ្វីទាំងអស់ក្រៅពីរគ្រឿងសង្ហារឹមបែកបាក់ ប៉ុន្តែវាជាអ្វីដែលនាងនិងខ្ញុំបានរីករាយជាមួយគ្នា។ វាជាផ្ទះ។

261 ហើយខ្ញុំចាំថា ថ្ងៃមួយខ្ញុំកំពុងប្រឹងប្រែងធ្វើការនៅសេវាសាធារណៈ។ ខ្ញុំត្រូវទៅជួសជុលដុំភ្លើងទីពីរ កំពុងតែព្យួរនៅទីនោះ។ វាជាពេលព្រឹកព្រហាម។ ខ្ញុំបានឡើងលើឈើឆ្កាងនេះ។ (ហើយខ្ញុំមិនអាចយកកូនតូចឡើងទៅទេ។ ខ្ញុំអាចមើល

ឃើញប្រពន្ធខ្ញុំ ប៉ុន្តែប្រពន្ធកំពុងតែបន្ត ជារបស់តូចមួយ។) ហើយខ្ញុំនៅទីនោះ ហើយខ្ញុំក៏ច្រៀង "នៅលើភ្នំសែនឆ្ងាយមានឈើឆ្កាងពុកផុយ។" ហើយភ្លើងទីមួយបានរត់កាត់ចូលត្រង់ស្វរ៍ ហើយបន្ត (អ្នកដឹងហើយ)ចូលដុំភ្លើងទីពីរ។ ហើយខ្ញុំត្រូវបានព្យួរនៅទីនោះ។ ហើយខ្ញុំចាប់ផ្តើមមើលឃើញ ព្រះអាទិត្យនៅពី ក្រោយខ្ញុំ។ ហើយនៅទីនោះ ដៃរបស់ខ្ញុំលាជាសញ្ញាឈើឆ្កាងលើ—លើភ្នំ។ ខ្ញុំគិត "ត្រូវហើយ វាជាបាបរបស់ខ្ញុំដែលនាំអោយដាក់ទ្រង់នៅទីនោះ។"

262 ខ្ញុំនិយាយ "សារ៉ុនជាទីស្រឡាញ់ពុកចង់ឃើញកូនខ្លាំងណាស់កូនសម្លាញ់។ ពុកពិតជាចង់អោបកូន នឹងដៃម្តងទៀតណាស់ អ្នកជារបស់តូចមួយ ជាទីស្រឡាញ់។" ខ្ញុំនៅម៉្លឹនោះ។ ខ្ញុំនៅជាច្រើនសប្តាហ៍។ ខ្ញុំទាញស្រោមដៃ កៅស៊ូចេញ។មានកម្លាំងអគ្គិសនី២៣០០វ៉ុលនៅក្បែរខ្ញុំ។ ខ្ញុំទាញស្រោមដៃកៅស៊ូចេញ។ ខ្ញុំនិយាយ "ព្រះជាម្ចាស់ ទូលបង្គំមិនចង់ធ្វើដូច្នេះទេ។ ទូលបង្គំកំសាក មែន។""ប៉ុន្តែសារីពុកនឹងទៅជួបកូននិងម្តាយរបស់កូនតែពីរបីនាទីទៀតប៉ុណ្ណោះ។" ចាប់ ទាញស្រោមដៃខ្ញុំចេញ ដាក់ដៃលើចរន្ត២៣០០នោះ។ វានឹងបែកខ្ទេច...ហេតុអ្វី អ្នកនឹង មិនមានសូម្បីតែឈាមក្នុងខ្លួនផង។ ហើយដូច្នេះ ខ្ញុំ—ខ្ញុំ—ខ្ញុំ ចាប់ ផ្តើមទាញស្រោមដៃចេញ ហើយមានអ្វីមួយកើតឡើង។ ពេលខ្ញុំមកវិញខ្ញុំកំពុង តែអង្គុយលើដីជាមួយ ដៃ*បែបនេះ* មុខខ្ញុំយំ។ វាជាព្រះគុណរបស់ព្រះ បើមិនដូច្នេះ ខ្ញុំមិនមានកម្មវិធីប្រោសជំងឺនៅទីនេះឡើយ ខ្ញុំជឿជាក់ដូច្នេះ។ នោះគឺជាទ្រង់ដែល ការពារ អំណោយទានរបស់ទ្រង់ មិនមែនការពារខ្ញុំឡើយ។

263 ខ្ញុំទៅផ្ទះវិញ។ ខ្ញុំបោះបង់វាចោល ទុកសម្ភារៈចោល។ ហើយត្រឡប់ទៅវិញ ខ្ញុំនិយាយ "ខ្ញុំទៅផ្ទះវិញហើយ។"

264 ខ្ញុំចាប់ផ្តើមទៅជុំវិញផ្ទះ ហើយយកសំបុត្រនៅក្នុងផ្ទះ រាងត្រជាក់បន្តិច ហើយខ្ញុំដើរចូលទៅ។ យើងមានបន្ទប់តូចមួយ ខ្ញុំកំពុងតែដេកនៅក្នុងបន្ទប់ តូចនោះ ហើយកំណកក៏កើតមានឡើង ហើយនៅទីនោះមានចង្ក្រានចាស់មួយ។ ខ្ញុំយកសំបុត្រមករួចអានសំបុត្រ ហើយអ្វីជាដំបូងនៅទីនោះ គឺជាការសន្សំ គ្រីស្ទម៉ាសតូចមួយ ៨០សេន "កញ្ញាសារ៉ុន រ៉ូសប្រាណហាំ។" វាគឺអញ្ចឹង គ្រប់យ៉ាង ចាប់ផ្តើមម្តងទៀត។

265 ខ្ញុំធ្វើជាអ្នកយាមព្រៃ។ ខ្ញុំឈោងចាប់កាំភ្លើងដៃ ដកចេញពីស្រោម។ ខ្ញុំនិយាយ "ព្រះអម្ចាស់ ទូលបង្គំ—ទូលបង្គំមិនអាចបន្តបែបនេះទៅទៀតបានឡើយ

ទូលបង្គំនឹងស្លាប់—ទូលបង្គំនឹងស្លាប់។ ទូលបង្គំ—ទូលបង្គំរងទារុណកម្មពេកណាស់។៉ ខ្ញុំដាក់ញញួរចុះ កាន់កាំភ្លើងភ្ជង់មកលើក្បាលរបស់ខ្ញុំ លុតជង្គង់នៅក្នុងបន្ទប់ដែលងងឹតនោះ។ ខ្ញុំនិយាយ ៉ព្រះបិតាដែគង់នៅស្ថានសួគ៌ សូមព្រះនាមទ្រង់បានថ្កើងឡើង សូមព្រះរាជទ្រង់បានមកដល់ នឹងបានសម្រេច។៉ ហើយខ្ញុំ ព្យាយាម ខ្ញុំទាញកៃយ៉ាងខ្លាំងអស់ពីកម្លាំង ហើយនិយាយ ៉នៅលើផែនដីដូចនៅស្ថានសួគ៌ដែរ។ សូមប្រទានអាហារប្រចាំថ្ងៃដល់ទូលបង្គំ។៉ ហើយក៏ចេញទៅ!

266 ហើយខ្ញុំគិត ៉ឱ ព្រះអើយ តើទ្រង់កំពុងហែកទូលបង្គំជាចំរៀករឺ? តើទូលបង្គំបានធ្វើអ្វី? ទ្រង់មិនអនុញ្ញាតិអោយទូលបង្គំស្លាប់ដូច្នេះ។៉ រួចខ្ញុំបោះ កាំភ្លើងចោល វាក៏បាញ់ពេញបន្ទប់។ ខ្ញុំនិយាយ ៉ព្រះជាម្ចាស់ ហេតុអ្វីទូលបង្គំមិន អាចស្លាប់បាន ហើយចេញពីរឿងទាំងនេះ? ទូលបង្គំមិនអាចបន្តទៅមុខទៀត បានឡើយ។ ទ្រង់ត្រូវតែធ្វើអ្វីមួយដល់ទូលបង្គំ។៉ ហើយខ្ញុំក៏ដួលហើយយំតិចៗ មានគ្រែតូចមួយទីនោះ។

267 ហើយខ្ញុំត្រូវដេកលក់។ ខ្ញុំមិនដឹងថាតើជាការដេកលក់ ឬអ្វីកើតឡើងឡើយ។

268 ខ្ញុំតែងមានចិត្តចង់ទៅភាគខាងលិច។ ខ្ញុំចង់បានមួកមួយរបស់ពួកគេ។ ឪពុក របស់ខ្ញុំបានជិះសេះនៅវ័យក្មេងរបស់គាត់ ដូច្នេះខ្ញុំតែងចង់បានមួករបស់ពួកគេ មួយ។ ហើយបងប្រុស ឌេម៉ុន សាកាវៀន ទិញអោយខ្ញុំមួយកាលពីម្សិលមិញ ជាមួកដំបូងដែលខ្ញុំ(ធ្លាប់មាន)មិនធ្លាប់មានម៉ូដនោះ ជាប្រភេទរបស់ពួកលោកខាងលិច។

269 ហើយខ្ញុំគិត ខ្ញុំកំពុងដើរចុះទៅសេះមួយនឹម ច្រៀងចម្រៀង ៉មានកង់ រទេះបាក់បែក មានសញ្ញានៅលើសត្វដាក់ថា ៉សម្រាប់លក់។៉៉ ហើយពេលខ្ញុំ ដើរបន្តទៀត ខ្ញុំមើលឃើញរទេះចាស់មួយមានដំបូលពីលើដូចជាទូកក្តោងចាស់ ហើយកង់រទេះបានបាក់ហើយ។ នេះជាការប្រៀបធៀបជាមួយគ្រួសារខ្ញុំដែលបែក បាក់។ ហើយពេលខ្ញុំទៅកាន់តែជិត ខ្ញុំឃើញ មាន—ក្មេងស្រីស្អាតម្នាក់នៅឈរទីនោះ អាយុប្រហែល២០ឆ្នាំ សក់ទម្លាក់ពណ៌សភ្នែកពណ៌ខៀវ ស្លៀកពាក់ ពណ៌ ស។ ខ្ញុំមើលទៅនាង ខ្ញុំនិយាយ ៉តើអ្នកសុខសប្បាយទេរឺ?៉ បន្តទៅ។

នាង និយាយ ៉សួស្តីពុក។៉

270 ហើយខ្ញុំបែរមក ខ្ញុំនិយាយ "ពុក?" "ហេតុអ្វី" ខ្ញុំនិយាយ "ដូចម្ដេច កញ្ញា អ្នកអាច...អាចអោយខ្ញុំជាឪពុករបស់អ្នកកាលអ្នកមានអាយុដូចខ្ញុំដែរ?"

271 នាងនិយាយ "ពុក អ្នកមិនដឹងថាអ្នកកំពុងនៅទីណាទេ។"

ហើយខ្ញុំ និយាយ "តើអ្នកមានន័យយ៉ាងណា?"

272 នាងនិយាយ "នេះជាស្ថានសួគ៌។" និយាយ "នៅលើផែនដីខ្ញុំគ្រាន់តែជា សារ៉ុន តូចម្នាក់ប៉ុណ្ណោះ។"

"ហេតុអ្វី" ខ្ញុំនិយាយ "កូនសម្លាញ់ កូនគ្រាន់តែជាក្មេង តូចមួយប៉ុណ្ណោះ។"

273 និយាយ "ពុកក្មេងតូចមិនមែនជាក្មេង នៅតែតូចនៅទីនេះឡើយ ពួកគេ ជាអមតៈ។ ពួកគេមិនចាស់ហើយក៏មិនធំធាត់ដែរ។"

274 ហើយខ្ញុំនិយាយ "ល្អ សារ៉ុន កូនសម្លាញ់ អ្នក—អ្នកស្អាតមែន ជាស្ត្រីវ័យក្មេងម្នាក់។"

នាងនិយាយ "ម៉ែកំពុងរង់ចាំពុកហើយ។"

ខ្ញុំនិយាយ "នៅឯណា?"

នាងនិយាយ "នៅក្នុងផ្ទះថ្មី។"

275 ហើយខ្ញុំនិយាយ "ផ្ទះថ្មី?" ប្រាណហាំគឺជាជនអនាថាពួកគេមិនមានផ្ទះឡើយ ពួកគេ...ពួកគេគ្រាន់តែ...ហើយខ្ញុំនិយាយ "ពុកមិនដែលមានផ្ទះទេកូនសម្លាញ់។"

276 នាងនិយាយ "ប៉ុន្តែពុកមានផ្ទះមួយនៅទីនេះ ពុក។" ខ្ញុំមិនមានន័យថាជាក្មេងតូចទេ ប៉ុន្តែវាពិតចំពោះខ្ញុំ។ [បងប្រុសប្រាណហាំយំ—Ed.] ពេលខ្ញុំចាប់ផ្ដើមគិតពីវា វានឹងមកម្ដងទៀត។ និយាយ "អ្នកមានផ្ទះមួយនៅទីនេះ ពុក។" ខ្ញុំដឹងថាខ្ញុំមានផ្ទះមួយនៅទីនោះថ្ងៃណាមួយខ្ញុំនឹងទៅរកវា។ នាងនិយាយ "ប៊ីលលីប៉ុលបងប្រុសរបស់ខ្ញុំនៅឯណា?"

277 ហើយខ្ញុំនិយាយ "ល្អ ពុកបានទុកគេជាមួយអ្នកស្រីប្រូយ កាលប៉ុន្មាន នាទីមុននេះ។"

និយាយ "អ្នកម៉ែចង់ជួបពុក។"

278 ហើយខ្ញុំបែរងាក មើលមានវាំងដ៏ធំមួយ ហើយសិរីរុងរឿងរបស់ព្រះនៅជុំវិញនោះ។ ហើយខ្ញុំឮសំលេងចម្រៀងទេវតាច្រៀង "ផ្ទះរបស់ខ្ញុំ ផ្ទះផ្អែមល្ហែម។" ខ្ញុំ

ចាប់ ឈានជំហានវែងៗ រត់យ៉ាងលឿនតាមតែអាចធ្វើទៅបាន។ ហើយពេលខ្ញុំទៅ ដល់មាត់ទ្វា នាងឈរនៅទីនោះ ស្លៀកពាក់ពណ៌ស និងមានសក់ខ្មៅ វែងចង ទម្លាក់ទៅក្រោយ។ នាងលើកដៃរបស់នាងដូចដែលនាងធ្លាប់ធ្វើពេលដែលខ្ញុំមាន ការនឿយហត់ពេលចេញពីការងារឬអ្វីមួយ។ ខ្ញុំចាប់ដៃនាង ហើយនិយាយ "អូន សម្លាញ់ បងឃើញសារ៉ុននៅទីនោះ។" ខ្ញុំនិយាយ "នាងបានក្លាយជា ក្មេងស្រីស្អាតម្នាក់ មែនទេ?"

279 នាងនិយាយ "មែនហើយ ប៊ីល។" នាងនិយាយ "ប៊ីល។" ដាក់ដៃនាងជុំវិញខ្ញុំ(រួចនាងនិយាយ) ជុំវិញស្មារបស់ខ្ញុំ នាងចាប់ផ្ដើមទះខ្ញុំតិចៗ នាងនិយាយ "ឈប់បារម្ភពីអូន និងសារ៉ុន។"

ខ្ញុំនិយាយ "អូនសម្លាញ់ បងមិនអាចធ្វើបានទេ។"

280 នាងនិយាយ "ឥឡូវ សារ៉ុន និងអូនគឺប្រសើរជាងបងឆ្ងាយណាស់។" ហើយនិយាយ "កុំបារម្ភពីពួកយើងទៀតអី។ តើបងសន្យាជាមួយខ្ញុំបានទេ?"

281 ហើយខ្ញុំនិយាយ "ហូប" ខ្ញុំនិយាយ "បងពិតជារសាប់រសល់ចំពោះ អូន និងសារ៉ុនណាស់ ហើយប៊ីលលីយំគ្រប់ពេលរកអូន។" ខ្ញុំនិយាយ "បងមិនដឹង ថាធ្វើយ៉ាងណាទេជាមួយគាត់។"

282 ហើយនាងនិយាយ "វាមិនអីទេ ប៊ីល។" នាងនិយាយ "ចូរសន្យាជាមួយអូនថាកុំបារម្ភទៀតអី។" ហើយនាងនិយាយ "តើបងអាចអង្គុយសិនបានទេ?" ខ្ញុំមើលជុំវិញហើយឃើញកៅអីធំមួយ។

283 ហើយខ្ញុំចាំថា ខ្ញុំបានព្យាយាមទិញកៅអីមួយ។ ឥឡូវ បានមកជិតវា ហើយ។ ខ្ញុំព្យាយាមទិញកៅអីម្ដង។ យើងមានតែកៅអីចាស់ធម្មតាក្រាល–ឈើ ប៉ុណ្ណោះ។ ហើយយើងអាចទិញកៅអីមួយធំនេះ ដែលអ្នកអាចផ្អែកខ្នងទៅក្រោយ បាន ដូចជា...ខ្ញុំភ្លេចហើយពីប្រភេទកៅអី-ស្រួលសម្រាក។ ហើយវាមានតម្លៃ ១៧ដុល្លារ ហើយអ្នកអាចបង់៣ដុល្លារមុន និង ១ដុល្លាក្នុងមួយសប្ដាហ៍។ ហើយ យើងទិញមួយ។ ហើយ អូ ពេលខ្ញុំចូលមក...ខ្ញុំធ្វើការពេញមួយថ្ងៃ ហើយខ្ញុំ អធិប្បាយ រហូតដល់កណ្ដាលយប់តាមផ្លូវ និងគ្រប់កន្លែងដែលអាចអធិប្បាយ បាយ។

284 ហើយ—ហើយ ថ្ងៃមួយខ្ញុំមិនអាចបង់បានទាន់ពេល។ យើងមិនអាចធ្វើ បាន ហើយវាចេះតែបន្តមួយថ្ងៃទៅមួយថ្ងៃ ហើយទីបំផុតពួកគេបានមកហើយ យក

កៅអីទៅ។ យប់នោះ ខ្ញុំមិនដែលភ្លេចឡើយ នាងបានធ្វើនំផៃផ្លែឆឺរីមួយ អោយខ្ញុំ។ ជារបស់ក្រីក្រតូចមួយ នាង—នាង—នាងដឹងថាខ្ញុំនឹងខូចចិត្ត។ ហើយ បន្ទាប់ពីអាហារពេលយប់ ខ្ញុំនិយាយ "អូនពិតជាចិត្តល្អណាស់នៅយប់នេះ អូនសម្លាញ់?"

285 ហើយនាងនិយាយ "និយាយ អូនបានសុំអោយក្មេងប្រុសនៅជិតខាង ដឹកជន្លេន ស្ទូចត្រីអោយបង។ តើបងមិនគិតថាយើងគួរតែទៅទន្លេស្ទូចត្រីមួយ ពេលទេរឺ?"

ហើយខ្ញុំនិយាយ "បាន ប៉ុន្តែ..."

286 ហើយនាងចាប់ផ្តើមយំ។ ខ្ញុំដឹងថាមានរឿងអ្វីមួយមិនល្អហើយ។ ខ្ញុំមានគំនិតដែរព្រោះពួកគេបានផ្ញើរកំណត់សម្គាល់អោយខ្ញុំរួចមកហើយ ពីការដែលគេនឹងមកយកកៅអី។ ហើយយើងមិនអាចរកបានមួយដុល្លាក្នុងមួយសប្តាហ៍ដើម្បីបង់ថ្លៃ។ យើងមិនអាច មិន...មិនអាចរកបានដើម្បីចំណាយ។ នាងដាក់ដៃជុំវិញខ្ញុំ ហើយខ្ញុំទៅមាត់ទ្វាកៅអីរបស់ខ្ញុំបានទៅបាត់ហើយ។

នាងប្រាប់ខ្ញុំអោយទៅទីនោះ នាងនិយាយ "បងចាំពីកៅអីនេះទេ ប៊ីល?"

ហើយខ្ញុំនិយាយ "បាទ អូនសម្លាញ់ បងចាំ។"

និយាយ "នោះជាអ្វីដែលបងគិតពីវា វាឬមិនមែន?"

"បាទ។"

287 និយាយ "ល្អ ពួកគេនឹងមិនយកទៀតទេ មួយនេះបង់ថ្លៃរួចហើយ។" នាងនិយាយ "អង្គុយចុះមួយនាទីមក អូនចង់និយាយជាមួយបង។"

ហើយខ្ញុំនិយាយ "អូនសម្លាញ់ បងមិនយល់រឿងនេះឡើយ។"

288 ហើយនាងនិយាយ "សន្យានឹងខ្ញុំ ប៊ីលលី សន្យានឹងខ្ញុំថាបងមិនបារម្ភ ទៀតឡើយ។ បងនឹងទៅវិញឥឡូវនេះ។" ហើយនិយាយ "សន្យានឹងអូន បងមិន បារម្ភទៀតឡើយ។"

ហើយខ្ញុំនិយាយ "បងមិនអាចធ្វើបានទេ ហូប។"

289 ហើយបន្ទាប់មកខ្ញុំក៏មកវិញ វាងងឹតនៅក្នុងបន្ទប់។ ខ្ញុំមើលជុំវិញ ហើយ ខ្ញុំមានអារម្មណ៍ថាដៃរបស់នាងនៅជុំវិញខ្ញុំ។ ខ្ញុំនិយាយ "ហូប អូននៅទីនេះ ក្នុងបន្ទប់រឺ?"

290 រួចនាងទះខ្ញុំតិចៗ។ នាងនិយាយ "បងសន្យាជាមួយអូនបានទេ ប៊ីល? សន្យាជាមួយអូនបងមិនបារម្ភ...ឈប់បារម្ភទៀត។"

ខ្ញុំនិយាយ "បងសន្យា។"

291 នៅពេលដែលនាងគោះខ្ញុំតិចៗពីបីដង នាងក៏ចាកចេញទៅ។ ខ្ញុំក៏លោតឡើង និង បើកភ្លើងមើលគ្រប់ទីកន្លែង ប៉ុន្តែនាងបានចេញទៅក្រៅ។ ប៉ុន្តែនាងមិនចេញពីបន្ទប់ទេ។ នាងមិនទៅណាឆ្ងាយទេ នាងនៅ មានជីវិតរស់នៅ នាងគឺជាគ្រីស្ទាន។

292 ប៊ីលលីនិងខ្ញុំទៅផ្នូរទីនេះពេលមួយយូហើយ យកបាច់ផ្កាអោយម្តាយ និងបងស្រីរបស់គាត់ គឺនៅព្រឹកថ្ងៃអ៊ីសស្ទឺ ហើយយើងឈប់។ សហមិត្តតូចនេះចាប់ផ្តើមយំហើយនិយាយ "ពុក ម៉ែរបស់ខ្ញុំនៅទីនោះ។"

293 ខ្ញុំនិយាយ "ទេ កូនសម្លាញ់។ ទេ គាត់មិននៅទីនោះទេ។ បងស្រីក៏មិននៅទីនោះដែរ។ យើងមានគំរបនៅលើផ្នូរទីនេះ ប៉ុន្តែនៅឆ្ងាយឆ្លងសមុទ្រទៅ មានផ្នូរបើកចំហរមួយដែលជាកន្លែងព្រះយេស៊ូវរស់ឡើងវិញ។ ហើយថ្ងៃណាមួយទ្រង់នឹងយាងមក ទ្រង់នឹងនាំបងស្រីនិងអ្នកម៉ែមកជាមួយដែរ។"

294 ខ្ញុំកំពុងនៅក្នុងទីលានសង្គ្រាមសព្វថ្ងៃនេះ មិត្តអើយ។ ខ្ញុំ—ខ្ញុំមិនអាចប្រាប់បន្តទៀតបានទេ។ ខ្ញុំ...[បងប្រុសប្រាណហាំយំ—Ed.] សូមព្រះប្រទានពរ។ ចូរអោយ យើងអោនក្បាលមួយនាទី។

295 អូ ព្រះអម្ចាស់! មានពេលជាច្រើន ព្រះអម្ចាស់ ទូលបង្គំជឿជាក់ថា មនុស្ស មិនយល់ ពេលពួកគេគិតថាការនេះកើតមកងាយៗ។ ប៉ុន្តែនឹងមានថ្ងៃ អស្ចារ្យចូលមក ពេលព្រះយេស៊ូវនឹងយាងមកហើយអស់ទាំងទុក្ខព្រួយ នឹងរលាយ ទៅ។ ទូលបង្គំអធិស្ឋាន ព្រះបិតាគង់នៅស្ថានសួគ៌ សូមទ្រង់ជួយអោយទូលបង្គំ បាន ប្រុងប្រៀបជាស្រេច។

296 ហើយការសន្យា ចុងក្រោយនោះពេលទូលបង្គំ ថើបថ្ពាល់នាងនៅព្រឹកនោះទូលបង្គំនឹងជួបនាងនៅថ្ងៃនោះ។ ទូលបង្គំជឿថានាងនឹងឈរនៅបង្គោលស្រែកហៅឈ្មោះរបស់ទូលបង្គំ។ ទូលបង្គំរស់នៅ ដោយពិតតាមសេចក្តីសន្យានោះតាំងពីពេលនោះមក ព្រះអម្ចាស់នៅគ្រប់ទីកន្លែង ជុំវិញពិភពលោក នឹងព្យាយាមនាំដំណឹងល្អទៅ។ ឥឡូវដែលចាស់ហើយ មានការនឿយហត់ ទូលបង្គំបាន

អស់កម្លាំងទៅ។ នៅថ្ងៃណាមួយទូលបង្គំនឹងបិទព្រះគម្ពីរនេះជាចុងក្រោយ។ សូមព្រះជាម្ចាស់រក្សាទូលបង្គំអោយនៅតែស្មោះត្រង់ចំពោះសេចក្ដីសន្យា។ រក្សាព្រះគុណ ទ្រង់នៅជុំវិញទូលបង្គំ ព្រះអម្ចាស់។ សូមកុំអោយទូលបង្គំមើលអ្វីជារបស់នៃជីវិត នេះឡើយ ប៉ុន្តែរស់នៅសម្រាប់អ្វីដែលលើសពីនេះវិញ។ សូមជួយទូលបង្គំអោយ មានភាពស្មោះត្រង់។ ទូលបង្គំមិនបានទូលសូមគ្រែផ្កានៃសេចក្ដីស្រណុកឡើយ មិនឡើយ ព្រះអម្ចាស់ នៅពេលដែលព្រះគ្រីស្ទរបស់ខ្ញុំសុគតដោយការឈើចាប់។ ហើយអ្នកដទៃទៀតស្លាប់ដូច្នេះ។ ខ្ញុំមិនសុំអ្វីដែលស្រួលៗនោះទេ។ សូមឲ្យខ្ញុំស្មោះត្រង់ ព្រះអម្ចាស់ ជាទីទុកចិត្ត។ សូមអោយមនុស្សស្រឡាញ់ ទូលបង្គំដូច្នេះ ទូលបង្គំ អាចនាំគេទៅចំពោះទ្រង់។ ហើយនៅថ្ងៃមួយពេលគ្រប់យ៉ាងបានបញ្ចប់ ទូលបង្គំទាំងឡាយនឹងបានជួបជុំគ្នានៅក្រោមដើមឈើបៃតងជានិច្ច ទូលបង្គំយក នាងមកដោយចាប់ដៃ និងបណ្ដើរនាងដើរទៅដើម្បីបង្ហាញដល់មនុស្សនៅព្រះវិហារ អេនជីលឡឺស និងមនុស្សដទៃទៀត។ វានឹងជាពេលវេលាអស្ចារ្យ។

297 ទូលបង្គំអធិស្ឋាន សូមសេចក្ដីប្រោសមេត្តារបស់ទ្រង់កើតមានលើទូល បង្គំម្នាក់ៗនៅទីនេះ។ ហើយអស់អ្នកណាដែលនៅទីនេះ ព្រះអម្ចាស់ ទោះបីគេ មិនទាន់ស្គាល់ទ្រង់ក៏ដោយ។ ហើយសូមអោយគេមានអ្នកជាទីស្រឡាញ់តូចនៅនាយសមុទ្រ។ បើពួកគេមិនទាន់បំពេញសេចក្ដីសន្យា សូមអោយពួកគេចាប់ ផ្ដើមពីឥឡូវនេះទៅ ព្រះអម្ចាស់។

298 កាលនៅអោនក្បាលនៅឡើយ ខ្ញុំចង់សួរថាតើនៅសាលដ៏ធំនៅរសៀលនេះ តើបងប្អូនប៉ុន្មាននាក់ដែលនិយាយ "បងប្រុសប្រាណហាំ ខ្ញុំចង់ជួបអ្នកជាទី ស្រឡាញ់របស់ខ្ញុំដែរ។ ខ្ញុំ—ខ្ញុំ—ខ្ញុំមានសេចក្ដីឡាញ់នៅឆ្លងត្រើយទន្លេ"? អ្នកអាចធ្វើការសន្យាថាអ្នកនឹងជួបពួកគេ ប្រហែលជាពេលអ្នកប្រាប់ម្ដាយរបស់ អ្នក "លាហើយ។" នៅទីនោះនៅឯផ្ទះនាថ្ងៃនោះ ប្រហែលជាអ្នកប្រាប់ប្អូនស្រីតូច របស់អ្នក "លា-ហើយ។" ឬ ឪពុក ឬមានអ្នកខ្លះទៀតនៅឯផ្ទះ សន្យាថាអ្នកនឹងជួបពួកគេហើយអ្នក—អ្នកមិនទាន់ធ្វើការរៀបចំខ្លួននៅឡើយ។ តើអ្នកមិនគិតថានេះជាពេលល្អធ្វើកាសន្យាទេ?

299 សូមទោសដែលខ្ញុំឈប់។ ប៉ុន្តែ អូ ខ្ញុំអើយ អ្នកមិនដឹងទេ មិត្តអើយ។ អ្នកមិនស្គាល់អ្វី—អ្វីជាការលះបង់ឡើយ! នោះមិនមែនជាចំនុចមួយទេពិបាកណាស់ គឺ

រឿងជីវិតរបស់ខ្ញុំ។

300 តើមានអ្នករាល់គ្នាប៉ុន្មាននាក់ក្រោកឡើង ឥឡូវ ហើយដើរមករកសេចក្តីអធិស្ឋាន និយាយ "ខ្ញុំចង់ជួបអ្នកជាទីស្រឡាញ់របស់ខ្ញុំ"? ងើបឡើងចេញពីអ្នកចូលរួមទស្សនាហើយចុះមកនេះ។ តើអ្នកនឹងធ្វើអីទេ? បើសិនជាមាននរណាមិនដែលធ្វើការរៀបចំខ្លួននៅឡើយ។ ព្រះប្រទានពរដល់ លោក។ ខ្ញុំឃើញបុរសជនជាតិស្បែកខ្មៅចេញមក មានអ្នកផ្សេងទៀតមកដែរ។ ចូរធ្វើចលនារបស់អ្នក អ្នកដែលនៅរានយ៉រខាងនោះ សូមធ្វើដំណើរចេញទៅស្តាំតាមច្រកផ្លូវដើរ។ ឬក្រោកឈរឡើង អ្នកដែលចង់ចងចាំពីពាក្យអធិស្ឋានឥឡូវ។ គឺអញ្ចឹងហើយ។ ក្រោកឈរឡើង។ ជាការល្អ។ ក្រោកឈរឡើង គ្រប់កន្លែង អ្នកដែលនិយាយ "ខ្ញុំមានឪពុកដែលនៅត្រើយឆ្ងាយ ខ្ញុំមានម្តាយ ឬអ្នកជាទីស្រលាញ់នៅត្រើយឆ្ងាយ។ ខ្ញុំចង់ជួបពួកគេ ខ្ញុំចង់ជួបពួកគេដោយសុខសាន្ត។" អ្នកនឹងក្រោកឡើង ចូរ ក្រោកឡើង នៅទីណាក៏ដោយនៅក្នុងសាលប្រជុំ។ ចូរក្រោកឡើង ហើយនិយាយ "ខ្ញុំចង់ទទួល។"

301 សូមព្រះប្រទានពរ ស្ត្រីនេះ។ ព្រះប្រទានពរអ្នកនៅទីនោះ។ ព្រះប្រទានពរនៅ លើនោះ។ ព្រះអម្ចាស់ប្រទានពរអ្នកទីនេះ លោក។ នោះត្រូវហើយ។ នៅលើ រានហាល សូមព្រះអម្ចាស់ប្រទានពរអ្នក។ ទាំងអស់នៅជុំវិញ គ្រប់កន្លែងក្រោក ឈរឡើងឡើងឥឡូវ ដើម្បីធ្វើពាក្យអធិស្ឋាន កាលបើព្រះវិញ្ញាណបរិសុទ្ធនៅ ទីនេះ កំពុងធ្វើចលនាក្នុងចិត្តរបស់អ្នក ដើម្បី—ដើម្បី—ដើម្បីបញ្ចប់។

302 អ្នកដឹងទេថាអ្វីដែលក្រុមជំនុំត្រូវការសព្វថ្ងៃនេះគឺជាការបញ្ចប់។ យើង ត្រូវតែត្រឡប់ទៅផ្ទះជាងស្នូន។ ទេវកសាស្រ្តដែលជាប់នៅពីការបង្កើតដោយផ្ទាល់ពេលខ្លះមិនបានផលល្អឡើយ។ អ្វីដែលយើងត្រូវការគឺបំបែកអ្វីរបៀបចាស់ កែប្រែចិត្តចុះចូលអោយមានភាពទុំជោរនៅចំពោះព្រះជាម្ចាស់។ តើគ្រប់គ្នាត្រៀមខ្លួន ក្នុងការឈរតាំងរឺនៅ?

សូមអោយយើងអោនក្បាលដើម្បីអធិស្ឋាន។

303 ឱ ព្រះអម្ចាស់ដែលនាំព្រះយេស៊ូវមកសម្រាប់...ពីសេចក្តីស្លាប់ ដើម្បីប្រោសអោយសុចរិតទូលបង្គំទាំងអស់ដោយជំនឿ ដោយជឿ។ ទូលបង្គំសូម អធិស្ឋានព្រះអម្ចាស់ ដែលអ្នកដែលឈរទាំងអស់នេះ ដើម្បីទូលទ្រង់ ទូលបង្គំ អធិស្ឋានសូមអោយការអត់ទោសនឹងមានដល់ពួកគេ។ ហើយ ឱ ព្រះអម្ចាស់ ទូលបង្គំ

អធិស្ឋានឲ្យពួកគេទទួលទ្រង់ជាព្រះសង្គ្រោះ ជាស្តេចនិងជាទី ស្រឡាញ់ ហើយប្រហែលជាពួកគេនឹងជួបម្តាយឬឪពុកឬនរណាទៀតនៅត្រើយដែលឆ្ងាយ។ មានរឿងមួយជាប្រាកដគឺពួកគេនឹងមានអង្គសង្គ្រោះ។ សូមអោយ ពួកគេទទួលបានការអត់ទោសនេះ ហើយរាល់សេចក្តីទុច្ចរិតរបស់ពួកគេ រលាយទៅហើយព្រលឹងរបស់គេនឹងត្រូវបានសំអាតដោយលោហិតរបស់កូនចៀមហើយ ពួកគេនឹងរស់នៅក្នុងសេចក្តីសុខសាន្តពីពេលនេះទៅ។

304 ហើយថ្ងៃនៃសិរីរុងរឿងរបស់ព្រះអម្ចាស់នឹងមកពេលអ្វីៗកន្លងទៅ សូម អោយទូលបង្គំរាល់គ្នាបានជួបជុំគ្នាក្នុងដំណាក់ទ្រង់ ហើយនឹងមិនមានគ្រួសារ បាក់បែកទៀតឡើយ ដើម្បីជួបអ្នកជាទីស្រឡាញ់នៅឯនាយសមុទ្រ។ នេះទូលបង្គំទាំងអស់ដាក់ពួកគេ ចុះចូលនឹងទ្រង់ដែល "ទ្រង់នឹងរក្សាពួកគេ នៅក្នុងសេចក្តីសុខសាន្តឥតខ្ចោះ ដែលមានចិត្តជាប់នៅជាមួយទ្រង់។" សូមអនុញ្ញាតិទទួល ព្រះអម្ចាស់ទូលបង្គំសូមដាក់ពួកគេចុះចូលជាមួយនឹងទ្រង់។ ក្នុងព្រះនាម ព្រះបុត្រារបស់ទ្រង់ព្រះអម្ចាស់ព្រះយេស៊ូវ។ អាម៉ែន។

305 សូមព្រះប្រទានពរដល់អ្នក។ ខ្ញុំជឿជាក់ថា អ្នកធ្វើការដឹងថាអ្នកកំពុងឈរនៅទីណា ហើយពួកគេនឹងទៅជួបអ្នកបីបួននាទីទៀត។

306 ហើយឥឡូវអស់អ្នកដែលទទួលបានកាតអធិស្ឋាន។ ប៊ីលលី កន្លែងជេននិងលីអូ ពួកគេនឹងត្រឡប់មកវិញ? ពួកគេនៅទីនេះដើម្បីចែកកាតនៅតែបីបួននាទីទៀតប៉ុណ្ណោះ។ សូមបងប្អូននឹងជួយធ្វើអោយស្រលះទស្សនិកជនដោយចែកកាត អធិស្ឋាន។ យើងនឹងត្រឡប់មកវិញបន្តិចទៀត ដើម្បីអធិស្ឋានដល់អ្នកជំងឺ។ ត្រូវហើយបងប្អូន។

# រឿងជីវិតរបស់ខ្ញុំ KHM59-0419A

(My Life Story)

សារដែលធ្វើទ្បើងដោយបងប្រុស William Marrion Branham នេះ ត្រូវបានចែកចាយនៅរសៀល ថ្ងៃអាទិត្យ ថ្ងៃទី 19 មេសា1959 នៅ ព្រះវិហារ Agelus, Los Angeles, California, U.S.A។ រាល់ការខិតខំត្រូវបានធ្វើទ្បើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែអាត់ថត ចម្លង និងបោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយ ដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក ។

KHMER

©2018 VGR, ALL RIGHTS RESERVED

Voice Of God Recordings
P.O. Box 950, Jeffersonville, Indiana 47131 U.S.A.
www.branham.org

## ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវែបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG